ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ផ្ទះសហគមន៍ភូមិក្ដុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម

◆ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចេញពីស្រុកអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩៧ ខែកញ្ញា ឆ្នាំ២០២៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ

◆ ផ្ទះសហគមន៍ភូមិគ្គលលើ នៃមជ្ឈមណ្ឌល......... ១

### ផ្នែកឯកសារ

◆ ហេង សោយ ហៅ ម៉ក់ ប្រធានពាណិជ្ជកម្ម........ ៨

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅតាមដងទន្លេមេគង្គនៅខេត្តកំពង់ចាម និងខេត្តស្ទឹងត្រែង រំឭកអំពីព្រឹត្តិការណ៍ទឹកជំនន់ឆ្នាំ១៩៧៨ ........ ១៤
◆ ផ្ទះសហគមន៍ជនជាតិស្ទៀង ភូមិគ្គលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម បើកឱ្យសិស្ស..... ១៧
◆ មជ្ឈមណ្ឌលឯកសារកោះថ្ម ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិត ......... ២០
◆ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចែករទេះរុញ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ......... ២៣
◆ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចែករទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ......... ២៥
◆ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ជូនដល់អ្នករស់រាន ....... ៣៤
◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តចែករទេះរុញចំនួន៨គ្រឿង ជូនដល់អ្នករស់រានមាន..... ៣៧
◆ អតីតកងទ័ពខ្មែរក្រហមម្នាក់ត្រូវបានបញ្ជូនទៅរៀនបើកយន្តហោះចម្បាំងនៅប្រទេសចិន ......... ៤១

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំដំណើរទស្សនកិច្ចសិក្សាស្តីពី«សន្តិភាព និង............៤៦
◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកា... ស្រាវជ្រាវស្តីអំពី«ជីវិតប្រចាំថ្ងៃរបស់ប្រជាជន.. ៤៩



ផ្ទះសហគមន៍ភូមិគ្គលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម នៅក្នុងភូមិគ្គលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលជាភូមិមួយមានជនជាតិស្ទៀងរស់នៅច្រើនជាងគេ ក្នុងចំណោមភូមិទាំង១៣ផ្សេងទៀតនៃឃុំទន្ទឹង។ ពីថ្ងៃទី១១ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ អ្នកភូមិជនជាតិដើមភាគតិចស្ទៀងភូមិគ្គលលើ បានរៀបចំពិធីបុណ្យឡើងផ្ទះសហគមន៍ភូមិគ្គលលើ ដែលទើបនឹងជួសជុលរួចរាល់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

◆ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនស្តីពី«ប្រវត្តិសាស្ត្រកម្ពុជា .................. ៥៣
◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីអំពី«ប្រវត្តិសាស្ត្រកម្ពុជា................. ៥៦

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ កូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)............ ៦១

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ឡុង ដានី, មីន សាណាស់, លី ដេវីត, ស្រេង លីដា, ឈុំ វ៉ា, ដេង ពង្សរ៉ាស៊ី, ភា វស្នី, ថុន ស្រីពេជ្រ, ទូច វណ្ណេត, សាំង ចាន់ធូ, មេក វិន, ស៊ាង ចិន្តា, សន ដីដីង, សួត វិចិត្រ និង ហង្ស ឆាំឆាន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ផ្ទះសហគមន៍ភូមិក្ដុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្មៃ

ផ្សុខ ដានី



ផ្ទះសហគមន៍ភូមិក្ដុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជាន់ខាងក្រោម ដែលជាការិយាល័យធ្វើការផ្សារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកោះថ្ម នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្ដើមជួសជុល និងរៀបចំផ្ទះសហគមន៍ភូមិក្ដុលលើ ចាប់ពីខែមីនា ឆ្នាំ២០២៤ និងបានបញ្ចប់ទាំងស្រុងនៅដើមខែកញ្ញា ឆ្នាំ២០២៤។ ផ្ទះសហគមន៍ភូមិក្ដុលលើនេះ គឺជាអំណោយរបស់យាយ ម៉ែន ប្រាញ់ ជូនមកដល់មជ្ឈមណ្ឌលឯកសារកោះថ្ម ប្រើប្រាស់ក្នុងគោលបំណងបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ជនជាតិស្មៀងប្រមាណ ១៥១គ្រួសារ ស្មើនឹង៧៣៨នាក់ នៅក្នុងភូមិក្ដុលលើ ដែលជាភូមិមួយមានជនជាតិស្មៀងរស់នៅច្រើនជាងគេ ក្នុងចំណោមភូមិទាំង១៣ផ្សេងទៀតនៃឃុំទន្ទុង។

ពីថ្ងៃទី១១ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ អ្នកភូមិជនជាតិដើមភាគតិចស្មៀងភូមិក្ដុលលើ ឃុំទន្ទុង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានរៀបចំពិធីបុណ្យឡើងផ្ទះសហគមន៍ភូមិក្ដុលលើដែលទើបនឹងជួសជុលរួចរាល់នេះ ដោយថ្ងៃទី១) អ្នកភូមិជនជាតិដើមភាគតិចស្មៀងភូមិក្ដុលលើបានរៀបចំពិធីសែនអ្នកតាសុំសេចក្ដីសុខសប្បាយតាមជំនឿតាំងពីដូនតានៅអាស្រមអ្នកតាក្រោមដើមជ្រៃធំនៅមុខផ្ទះសហគមន៍

ភូមិក្តុលលើ។ បន្ទាប់មកអ្នកភូមិរៀបចំសែនព្រេនសុំសេចក្តីសុខសប្បាយនៅខាងលើផ្ទះសហគមន៍ភូមិក្តុលលើបន្តទៀត។ កាលពីដើម ជនជាតិស្ទៀងភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ រួមមាន ក្មេង ចាស់ ប្រុស ស្រី តែងតែយាយីដោយសារជំងឺគ្រុន និងជំងឺរាតត្បាតផ្សេងៗដែលបណ្តាលឱ្យមានមនុស្សស្លាប់ ទើបអ្នកភូមិជនជាតិស្ទៀងជឿលើការបន់ស្រន់អារក្ស និងអ្នកតា។ អ្នកភូមិបានមូលគំនិតរៀបចំពិធីឡើងអ្នកតា។ អ្នកភូមិធ្វើគ្រែស្នែងធំល្មម ហើយដាក់ដុំថ្មចំនួនពីរដុំលើគ្រែស្នែងនោះ។ ចំណែកថ្មទាំងពីរដុំ ត្រូវបានអ្នកភូមិជនជាតិដើមភាគតិចស្ទៀងគូរកំបោរឱ្យដូចទៅនឹងមុខមនុស្ស។ នៅលើគ្រែស្នែងមានគ្រឿងសំណែន ដូចជា ម្លូ ស្លា បារី បាយស បាយក្រហម នំ ចំណី បង្អែម ផ្លែឈើ និងស្រាជាដើម។ សម្រាប់គ្រែស្នែង តម្រូវឱ្យមានមនុស្សប្រុសចំនួន៨នាក់ សែងដង្ហែក្នុងភូមិ។ អ្នកភូមិជនជាតិភាគតិចស្ទៀងដែលចូលរួមដង្ហែត្រូវគូរមុខ គូរមាត់ ឱ្យខុសប្លែកពីមនុស្ស។ ចំណែកឧបករណ៍កាន់តាមខ្លួនរួមមាន ដាវ កាំបិត ធ្នូ ដំបង ដែលធ្វើអំពីឈើ និងឫស្សី។ រីឯសត្វរួមមានសត្វគោ ក្របី ដំរី សេះធ្វើពីដើមចេក។ បន្ទាប់ពីរៀបចំរណ្តាប់បូជាសព្វគ្រប់ហើយ អ្នកភូមិជនជាតិដើមភាគតិចស្ទៀងនាំគ្នាស្រែកខ្លាំងៗ ឱ្យឧបទ្រពចង្រៃចេញពីភូមិស្រុក និងសូមឱ្យអ្នកភូមិមានសេចក្តីសុខចម្រើន។ អ្នកភូមិនាំគ្នាដើរគោះគ្រប់ផ្ទះ ដើម្បីដេញគ្រោះឧបទ្រពចេញពីផ្ទះដែរ។ អ្នកភូមិជនជាតិភាគតិចស្ទៀងបាននាំគ្នាវាយ និងបោះសត្វមាន់ ទា ទៅលើគ្រែស្នែងយកទៅអាស្រមអ្នកតា ឬខ្ទមអ្នកតា។ បន្ទាប់មកអ្នកភូមិចាប់ផ្តើមសែនព្រេន បន់ស្រន់អារក្សអ្នក សុំសេចក្តីសុខម្តងទៀត។ អស់រយៈពេលប្រមាណជាង១០ឆ្នាំកន្លងមកនេះ អ្នកភូមិក្តុលលើលែងធ្វើពិធីឡើងអ្នកតាទៀតហើយ គឺគ្រាន់តែធ្វើពិធីសែនអ្នកតានៅទីអាស្រមក្នុងភូមិ ដើម្បីសុំម្ចាស់ទឹក ម្ចាស់ដី មុនសាងសង់ផ្ទះសម្បែង ឬរៀបចំពិធីអ្វីមួយ។ នៅថ្ងៃទី២) អ្នកភូមិក្តុលលើធ្វើដំណើរទៅវត្តហត្ថិវនរាមក្តុល ហៅ វត្តក្តុល ដើម្បីដង្ហែព្រះពុទ្ធរូបចំនួន៥ព្រះអង្គមកគង់នៅផ្ទះសហគមន៍ភូមិក្តុលលើ។ បន្ទាប់មកព្រះសង្ឃនិមន្តធ្វើបទនមស្ការ ចម្រើនព្រះបរិត្ត និងប្រគេនយាគូព្រះសង្ឃ ជាកិច្ចបង្ហើយបុណ្យ។



អ្នកភូមិជនជាតិដើមភាគតិចស្ទៀងភូមិក្តុលលើរៀបចំពិធីសែនអ្នកតា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នកភូមិជនជាតិដើមភាគតិចស្ទៀងភូមិក្តុលលើរៀបចំរណ្តាប់សម្រាប់ពិធីឡើងផ្ទះសហគមន៍ភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្ទះសហគមន៍ភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម ស្ថិតនៅក្នុងភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលត្រូវបានហៅថាតំបន់កោះថ្ម។ តំបន់កោះថ្មស្ថិតនៅក្នុងស្រុកមេមត់ ដែលកំណត់ក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រភូមិរួមមាន៖ ឃុំទន្លូង ឃុំជាំតាម៉ៅ និងឃុំជាំក្រវៀន គឺជាទីតាំងមួយក្នុងចំណោមទីតាំងផ្សេងទៀតដែលជនជាតិដើមភាគតិចស្ទៀងរស់នៅ និងជាតំបន់មួយដែលទទួលរងផលប៉ះពាល់ចាប់តាំងពីអាណានិគមនិយមបារាំង។ សហគមន៍ជនជាតិដើមភាគតិចស្ទៀងក្នុងស្រុកមេមត់ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ស្រុកស្នួល ខេត្តក្រចេះ និងជនជាតិដើមភាគតិចផ្សេងៗទៀតក្នុងខេត្តមណ្ឌលគិរី ខេត្តរតនគិរី ត្រូវបានបែកខ្ញែកសាច់ញាតិ បងប្អូនកូនចៅ និងទឹកដីដោយមួយផ្នែកត្រូវស្ថិតនៅក្នុងប្រទេសកម្ពុជា និងមួយផ្នែកទៀតត្រូវនៅក្នុងប្រទេសវៀតណាម។ បន្ទាប់មកជនជាតិដើមភាគតិចស្ទៀងនៅតំបន់កោះថ្មបានទទួលរងគ្រោះធ្ងន់ធ្ងរបន្ថែមទៀតដោយសារសង្គ្រាមវៀតណាម ការទម្លាក់គ្រាប់បែក និងអំពើប្រល័យពូជសាសន៍អំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

តំបន់កោះថ្ម គឺជាកន្លែងដែលសម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើមនៃដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងសង្គ្រោះប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឱ្យរស់រានមានជីវិតនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងការផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដែលឈានទៅរកការបង្រួបបង្រួមប្រទេសទាំងមូល និងទទួលបានសន្តិភាពពេញលេញនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។

ផ្ទះសហគមន៍ភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម ត្រូវបានរចនាឡើងដោយនិស្សិតស្ថាបត្យកម្មឆ្នាំទី៥ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈចំនួន២រូប គឺ លោក វនវ័ត្តវិសាល និងកញ្ញា លឹម វណ្ណសូលីហ្សា ដោយយកតាមលំនាំផ្ទះរបស់ជនជាតិដើមភាគតិចស្ទៀងសម័យបុរាណ។ ផ្នែកខាងលើនៃផ្ទះនេះត្រូវសង់អំពីឈើ សម្រាប់សហគមន៍ជនជាតិដើមភាគតិចស្ទៀងតំបន់កោះថ្ម ប្រើប្រាស់ក្នុងការពិភាក្សាលើកិច្ចការងារស្រែចម្ការ ការងារអភិវឌ្ឍន៍សហគមន៍ ការងារយេនឌ័រ បញ្ហាដីធ្លី ការងារបោះឆ្នោត ការងារទាក់ទងនឹងការថែរក្សាទំនៀមទម្លាប់ប្រពៃណីជនជាតិដើមភាគតិច



ព្រះសង្ឃសូត្រមន្តក្នុងពិធីឡើងផ្ទះសហគមន៍ភូមិត្តលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្មៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្មៀង ការប្រារព្ធពិធីបុណ្យប្រពៃណីវប្បធម៌ សាសនា និងការងារផ្សេងៗទៀតនៅក្នុងសហគមន៍ៗ ចំណែកផ្នែកខាងក្រោម (ជាន់ផ្ទាល់ដី) សាងសង់អំពីស៊ីម៉ងត៍ សម្រាប់ប្រើប្រាស់ជាការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្មៗ

មជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ គឺជាសាខាមួយក្នុងចំណោមសាខាតាមខេត្តទាំង១៩ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាៗ មជ្ឈមណ្ឌលឯកសារកោះថ្ម បានបើកដំណើរការជាសាធារណៈ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ត្រូវនឹងខួបលើកទី៤៣ ទិវានៃការចងចាំដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត (ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដល់ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០)ៗ មជ្ឈមណ្ឌលឯកសារកោះថ្មនេះ គឺផ្តើមចេញពីគំនិតរបស់នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ អគ្គនាយកអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសនៃក្រសួងការពារជាតិ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងដំណើរសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រយោធានៅតំបន់កោះថ្ម នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ៗ

មជ្ឈមណ្ឌលឯកសារកោះថ្មមានវត្ថុបំណងធំៗចំនួន៤ដូចខាងក្រោម៖

១) បង្ហាញព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាដែលបានចាប់ផ្តើមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩០ ៗ

២) ពង្រឹងការកសាងសន្តិភាព និងការការពារជម្លោះ តាមរយៈកម្មវិធីអប់រំ ដែលជាឱកាសមួយសម្រាប់យុវជននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលបំផុតក្នុងការចូលរួមរៀនសូត្រៗ

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឱ្យចែករំលែក និងបង្រៀនក្មេងៗជំនាន់ក្រោយពីបទពិសោធន៍របស់ពួកគេក្នុងរបបខ្មែរក្រហមៗ

៤) ប្រមែប្រមូលរឿងរ៉ាវបទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបនោះៗ

ក្នុងរយៈពេលជាង៤ឆ្នាំ ដោយគិតចាប់ពីខែមិថុនា ឆ្នាំ២០២០ រហូតដល់ខែកញ្ញា ឆ្នាំ២០២៤ នេះ មជ្ឈមណ្ឌលឯកសារកោះថ្មបានបំពេញការងារស្នូលរបស់ខ្លួនដូចខាងក្រោម៖

ទី១) មជ្ឈមណ្ឌលឯកសារកោះថ្ម បានជ្រើស



ការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រើសយុវជនស្ម័គ្រចិត្តក្នុងខេត្តត្បូងឃ្មុំ សរុបចំនួន ៤០៥នាក់ មកបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រខ្មែរក្រហម វិធីសាស្ត្រសម្ភាសន៍ប្រវត្តិសាស្ត្រផ្ទាល់មាត់ ត្រៀមសម្ភារ និងឯកសារផ្សេងៗ មុននឹងអនុញ្ញាតឱ្យយុវជនស្ម័គ្រចិត្តទាំងអស់ចុះសួរសុខទុក្ខ ស្តាប់រឿងរ៉ាវដែលអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមជាជនជាតិដើមភាគតិចស្មៀង និងអ្នករានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមផ្សេងទៀតក្នុងខេត្តត្បូងឃ្មុំ ដែលបានចងចាំមិនភ្លេច និងបញ្ហាសុខភាពរបស់ពួកគាត់នៅពេលបច្ចុប្បន្ននេះ។

ទី២) បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម និងអ្នកស្ម័គ្រចិត្តខេត្តត្បូងឃ្មុំ បានប្រមូលរឿងរ៉ាវដែលអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមជាជនជាតិដើមភាគតិចស្មៀង និងអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមផ្សេងទៀតក្នុងខេត្តត្បូងឃ្មុំ សរុបចំនួនជាង ៣១៥៨នាក់។

ទី៣) មជ្ឈមណ្ឌលឯកសារកោះថ្មបានទទួលសិស្សានុសិស្ស និស្សិត និងយុវជនរស់នៅក្នុងខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ចាម និងរាជធានីភ្នំពេញមកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើហិង្សាធ្ងន់ធ្ងរ ចំនួន៤៥លើក ស្មើនឹង ៣០៧០នាក់ នៅបន្ទប់ពិព័រណ៍រូបថតនៃមជ្ឈមណ្ឌលឯកសារកោះថ្ម។ ក្នុងនោះក៏មានមន្ត្រីរាជការ មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា អង្គទូតនានា និងអ្នកស្រាវជ្រាវបានអញ្ជើញចូលមកទស្សនាពិព័រណ៍រូបថត រូបគំនូរ និងផែនទីដែលបានតាំងនៅបន្ទប់ពិព័រណ៍រូបថតនៃមជ្ឈមណ្ឌលឯកសារកោះថ្ម។

ទី៤) មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំដំណើរទស្សនកិច្ចតាមរថភ្លើង លើប្រធានបទ ការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី២ និងទី៣ ក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ចំនួន២លើក ស្មើនឹង១៨៦នាក់។ លើកទី១) ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំដំណើរទស្សនកិច្ចតាមរថភ្លើង លើប្រធានបទ៖ ការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី២ ក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) សម្រាប់យុវជនខេត្តត្បូងឃ្មុំ ចំនួន១០២នាក់ រយៈ

ពេល៤យប់ ៥ថ្ងៃ ដោយធ្វើដំណើរតាមរថភ្លើងពីភ្នំពេញទៅខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។ នៅក្នុងខេត្តបន្ទាយមានជ័យ និងពោធិ៍សាត់យុវជនបានទស្សនកិច្ចសិក្សាតាមទីតាំងឧក្រិដ្ឋកម្មនានា និងជួបសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមនៅតាមទីតាំងនីមួយៗ។ លើកទី២) ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំដំណើរទស្សនកិច្ចតាមរថភ្លើង លើប្រធានបទ៖ ការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី៣ ក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) សម្រាប់យុវជនខេត្តត្បូងឃ្មុំ ចំនួន៤៤នាក់ រយៈពេល៤យប់ ៥ថ្ងៃ ដោយធ្វើដំណើតាមរថភ្លើងពីភ្នំពេញទៅខេត្តកំពត។ នៅក្នុងខេត្តកំពត យុវជនបានទស្សនកិច្ចសិក្សានៅអតីតការដ្ឋានស្រែអំបិលខ្មែរក្រហម និងទីតាំងឧក្រិដ្ឋកម្មនានា។ ក្រុមយុវជនក៏បានជួបសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលធ្លាប់បានធ្វើការងារជាកម្មករស្រែអំបិល លើកទំនប់ និងជីកប្រឡាយ។

ទី៥) មជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាអប់រំសហគមន៍សម្រាប់យុវជន និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) និងការទប់ស្កាត់អំពើហិង្សាធ្ងន់ធ្ងរ ចំនួន៨លើក ស្មើនឹង ៣២៨នាក់ (អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៩៨នាក់ និងយុវជនចំនួន១៣០នាក់) នៅក្នុងឃុំទន្លូង ឃុំជាំតាម៉ៅ ឃុំជាំ និងឃុំចាន់មូលនៃស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ទី៦) មជ្ឈមណ្ឌលឯកសារកោះថ្មបានជូន និងចំណាយរាល់ការធ្វើដំណើរដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចស្មៀង និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀតក្នុងខេត្តត្បូងឃ្មុំ មកពិនិត្យសុខភាពនៅតាមមន្ទីរសម្រាកព្យាបាលដែលជាដៃគូរបស់មជ្ឈមណ្ឌលឯកសារកោះថ្ម នៅតាមស្រុកនានាក្នុងខេត្តត្បូងឃ្មុំ សរុបចំនួន២៩២នាក់។

ទី៧) មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំផ្តល់ការពិនិត្យសុខភាពជាបឋមដោយក្រុមគ្រូពេទ្យមកពីមន្ទីរពេទ្យ KV ខេត្តត្បូងឃ្មុំ ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចស្មៀង និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀតក្នុងខេត្តត្បូងឃ្មុំ ចំនួន៣លើក (លើកទី១) នៅភូមិកូនក្រពើ ឃុំជាំតាម៉ៅ លើកទី២) នៅភូមិក្តុលលើ ឃុំទន្លូង និងលើកទី៣) នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតនៅក្នុងសាសាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែនកោះថ្ម) សរុបស្មើនឹង១៥១នាក់។

ទី៨) មជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាអប់រំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចស្មៀង និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀតក្នុងខេត្តត្បូងឃ្មុំចំនួន២លើក (លើកទី១) នៅភូមិក្តុលលើ ឃុំទន្លូង និងលើកទី២) នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតនៅក្នុងសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែនកោះថ្ម សរុបស្មើនឹង១៥១នាក់។ ក្រុមគ្រូពេទ្យជំនាញ និងក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចូលរួមជាវាគ្មិនក្នុងវេទិកាទាំងពីរខាងលើ។

ទី៩) មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំឱ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាជនជាតិដើមភាគតិចស្មៀងចំនួន៤៧នាក់ បានចូលរួម សន្និសីទលើកទី១៖ អនាគតប្រទេសកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍ចន្លោះពីថ្ងៃទី១៩ ដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ (អតីតសាលាក្តីខ្មែរក្រហម) នៅរាជធានីភ្នំពេញ ដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ខុទ្ទកាល័យនាយករដ្ឋមន្ត្រី បញ្ជាការដ្ឋានកងទ័ពជើងគោក និងមជ្ឈមណ្ឌលឯកសារកម្ពុជា។

ទី១០) មជ្ឈមណ្ឌលឯកសារកោះថ្មបានផ្តល់ម៉ូតូកង់បី (Tuk Tuk) មួយគ្រឿង ដល់សហគមន៍ភូមិកូនក្រពើ ឃុំជាំតាម៉ៅ ស្រុកមេមត់ ដែលជាភូមិមួយដាច់ស្រយាលពីមណ្ឌលសុខភាពឃុំ និងមន្ទីរពេទ្យ

បង្អែកស្រុក ដើម្បីប្រើសម្រាប់ដឹកជញ្ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងស្ត្រីមានផ្ទៃពោះមកកាន់មណ្ឌលសុខភាពឃុំ និងមន្ទីរពេទ្យបង្អែកស្រុកបានងាយស្រួល និងទាន់ពេលវេលា។

ទី១១) មជ្ឈមណ្ឌលឯកសារកោះថ្ម បានផ្តល់រទេះរុញជូនជនពិការចំនួន១២គ្រឿង និងកាសជំនួយត្រចៀកចំនួន១៧គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងកូនចៅដែលជាជនពិការនៅខេត្តត្បូងឃ្មុំ។ មជ្ឈមណ្ឌលឯកសារកោះថ្ម ក៏បានផ្តល់រទេះរុញជនពិការចំនួន៥គ្រឿង និងផ្តល់កាសជំនួយត្រចៀកចំនួន១០០គ្រឿង ជូនអង្គការជនពិការខេត្តត្បូងឃ្មុំ។

នៅចន្លោះពីខែតុលា ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៥ ខាងមុខនេះ មជ្ឈមណ្ឌលឯកសារកោះថ្ម នឹងផ្តោតសំខាន់ទៅលើការងារស្រាវជ្រាវរឿងរ៉ាវប្រវត្តិសាស្ត្រសហគមន៍ជនជាតិដើមភាគតិចស្ទៀងតាមភូមិ ក្នុងតំបន់កោះថ្ម (ឃុំទន្លុង ឃុំជាំតាម៉ៅ ឃុំជាំក្រវៀន) ចាប់តាំងពីជំនាន់អាណានិគមនិយមបារាំង សង្គ្រាមវៀតណាម ការទម្លាក់គ្រាប់បែករបបប្រល័យពូជសាសន៍ខ្មែរក្រហម និងសម័យក្រោយឆ្នាំ១៩៧៩។ មជ្ឈមណ្ឌលឯកសារកោះថ្មនឹងបន្តរៀបចំដំណើរទស្សនកិច្ចសិក្សា វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) និងការទប់ស្កាត់អំពើហិង្សាធ្ងន់ធ្ងរនៅបន្ទប់ពិព័រណ៍រូបថតមជ្ឈមណ្ឌលឯកសារកោះថ្ម។ មជ្ឈមណ្ឌលឯកសារកោះថ្មនឹងបន្តសួរសុខទុក្ខ ស្តាប់ និងចងក្រងរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាជនជាតិដើមភាគតិចស្ទៀងតំបន់កោះថ្ម និងតំបន់ដទៃទៀតក្នុងខេត្តត្បូងឃ្មុំ។



# ហេង សោយ ហៅ ម៉ក់ ប្រធានពាណិជ្ជកម្ម តំបន់២៣ ភូមិភាគបូព៌ា

*មីន សាណាស់*



កម្មករនៅកំពង់ផែក្រុងកំពង់សោមកំពុងផ្ទេរធុងប្រេងចេញពីកប៉ាល់ នៅអំឡុងឆ្នាំ១៩៧៨ ក្នុងរបបខ្មែរក្រហម។ (ហ្គុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ហេង សោយ ហៅ ម៉ក់ ត្រូវជាប្អូនបង្កើតរបស់ ណៃ សារ៉ាន ហៅ យ៉ា លេខាភូមិភាគឦសាន ដែលត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឆ្នាំ១៩៧៦។ ម៉ក់ គឺអតីតគ្រូបង្រៀននៅខេត្តស្វាយរៀង។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ម៉ក់ មានតួនាទីជាប្រធានពាណិជ្ជកម្មនៅតំបន់២៣ ភូមិភាគបូព៌ា ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៨ ពីបទក្បត់អង្គការបដិវត្តន៍។ ខាងក្រោមនេះគឺជាសេចក្តីរាយការណ៍ពីប្រវត្តិសកម្មភាពក្បត់របស់ ហេង សោយ ហៅ ម៉ក់ ពីថ្ងៃទី៩ ខែមីនា ដល់ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៨៖

ខ្ញុំឈ្មោះ ហេង សោយ ហៅ ម៉ក់ ភេទប្រុស អាយុ៤៧ឆ្នាំ (ក្នុងឆ្នាំ១៩៧៨) ជនជាតិខ្មែរកាត់ចិនមានស្រុកកំណើតនៅឃុំគគីសោម ស្រុកប្រសូត្រ តំបន់២៣ ភូមិភាគបូព៌ា។ ខ្ញុំត្រូវជាប្អូនប្រុសរបស់ ណៃ សារ៉ាន ហៅ យ៉ា លេខាភូមិភាគឦសាន។ ឪពុកម្តាយខ្ញុំស្លាប់តាំងពីខ្ញុំអាយុបាន៩ឆ្នាំ ហើយខ្ញុំត្រូវរស់នៅជាមួយបង ដែលមានមុខរបររកស៊ីលក់ម្ហូបស្លា។ នៅឆ្នាំ១៩៤៩ ខ្ញុំបួសនៅវត្តគគីសោម ស្ថិតក្នុងស្រុកកំណើតរបស់ខ្ញុំ។ នៅឆ្នាំ១៩៥៧ ខ្ញុំសឹកពីសង្ឃដើម្បីចូលរៀនត្រៀមប្រឡងធ្វើគ្រូនៅឯភ្នំពេញ។ ក្នុងពេលរៀននោះ ខ្ញុំត្រូវមកស្នាក់នៅផ្ទះបងយ៉ា។ កាលនោះ បងយ៉ា ធ្វើការនៅរោងការសែតប្រជាជនភ្នំពេញ។ ក្នុងរយៈកាលរស់នៅ

ជាមួយបងយ៉ា បងយ៉ាអប់រំខ្ញុំជាហូរហែ ដោយយកលទ្ធិពីរមកវែកញែកគឺ ១) លទ្ធិលោកសេរី និង ២) លទ្ធិកុម្មុយនីស្ត។ លទ្ធិសេរី គឺជាលទ្ធិមួយមានសេរីភាពគ្រប់គ្រាន់ មានសេរីភាពក្នុងការសរសេរ និយាយស្តី និងបន្តឱ្យប្រទេសមានភាពសម្បូរបែបនៅលើសាកលលោក។ ខ្ញុំយល់ថា មានតែប្រទេសលោកសេរីទេដែលត្រូវដើរតាម ពីព្រោះប្រទេសមានសេរីភាពគ្រប់គ្រាន់ និងជាប្រទេសអ្នកមានមួយនៅលើសាកលលោក។

ក្រោយមកបងយ៉ា ក៏រៀបចំបញ្ចូលខ្ញុំជាកម្លាំង សេ-អ៊ី-អា ស្ថិតនៅផ្ទះជួលរបស់គាត់នៅខាងកើតវត្តទួលទំពូង។ បន្ទាប់ពីចូលជា សេ-អ៊ី-អា រួចបងយ៉ាបានអប់រំ និងផ្តល់ភារកិច្ចដែលខ្ញុំត្រូវធ្វើសកម្មភាពមានដូចជា៖ ១) ឃោសនាប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត និងលើកឥទ្ធិពលលោកសេរី។ ២) ត្រូវកសាងកម្លាំងស្នូល សេ-អ៊ី-អា ឱ្យបានច្រើនដើម្បីទប់ទល់នឹងកម្លាំងកុម្មុយនីស្ត។ ៣) ខ្ញុំត្រូវតាមដានចលនាកុម្មុយនីស្តឱ្យជាប់ ដើម្បីងាយស្រួលក្នុងការទប់ទល់។ ៤) ត្រូវរក្សាកម្លាំងឱ្យបានហ្មត់ចត់ ជៀសវាងធ្វើយ៉ាងណាកុំឱ្យបាត់បង់កម្លាំង។ បន្ទាប់មកបងយ៉ា ក៏ខទ្ទេសនាមឈ្មោះ ហង់ សុន ហៅ ហង់ សាកឿន អតីតធ្វើតស្សរជិនាន់៩ឆ្នាំ ដែលធ្លាប់រស់នៅជាមួយបងយ៉ា តាំងពីឆ្នាំ១៩៥៧ កាលពីធ្វើការនៅរោងកាសែតប្រជាជនភ្នំពេញ។ នៅឆ្នាំ១៩៧៣ ហង់ សុន ហៅ សាកឿនបានស្លាប់នៅរតនគិរី ដោយសារគ្រុនចាញ់។ ឈ្មោះ កែវ សុន ហៅ កែវ មាស អតីតធ្វើតស្សរជិនាន់៩ឆ្នាំ និងនៅឆ្នាំ១៩៥៧ ក៏ធ្វើការនៅរោងកាសែតប្រជាជនភ្នំពេញ ដែរ ប៉ុន្តែបច្ចុប្បន្នក្លាប់មិនបាន។

នៅចុងឆ្នាំ១៩៥៧ ខ្ញុំបានប្រឡងគ្រូជាប់ រាជការជិនាន់នោះក៏ចាត់តាំងឈ្មោះខ្ញុំឱ្យទៅបង្រៀននៅខេត្តស្វាយរៀង។ នៅខែមករា ឆ្នាំ១៩៥៨ ខ្ញុំក៏សុំលាបងយ៉ា ទៅខេត្តស្វាយរៀងវិញ។ បងយ៉ា ក៏ខទ្ទេសនាមខ្សែទាក់ទងគាត់នៅខាងខេត្តស្វាយរៀងឱ្យខ្ញុំចំនួន៨នាក់ ដូចជា៖ ឈ្មោះ ទិត ឈុន អតីតគ្រូបង្រៀននៅស្វាយរៀងក្រុង ស្រុកស្វាយរៀង តំបន់២៣។ ឈ្មោះ ប៉ែន សាក់ អតីតគ្រូបង្រៀននៅក្រុងស្វាយរៀង (បច្ចុប្បន្នយួនចាប់បាននៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៧ ពេលដែលយួនចូលខេត្តស្វាយរៀង)។ ឈ្មោះ អន យ៉ុន អតីតធ្វើគ្រូបង្រៀននៅក្រុងស្វាយរៀង អង្គការយកទៅខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៥។ ឈ្មោះ គីម សំ អតីតធ្វើគ្រូបង្រៀននៅក្រុងស្វាយរៀង អង្គការយកទៅខេត្តបាត់ដំបង នៅឆ្នាំ១៩៧៥។ ឈ្មោះ ចាន់ ម៉ៅ អតីតធ្វើគ្រូបង្រៀននៅក្រុងស្វាយរៀង បច្ចុប្បន្នគឺជាប្រជាជននៅភូមិតាណែង ឃុំសង្កែ ស្រុកសំរោង តំបន់២៣។ ឈ្មោះ ចាន់ អោក អតីតធ្វើគ្រូបង្រៀននៅក្រុងស្វាយរៀង បច្ចុប្បន្នគឺជាប្រជាជននៅសហករណ៍ ស្រុកប្រសូត្រ តំបន់២៣។ ឈ្មោះ វ៉ែង ហៅ រ៉ឹក អតីតធ្វើតស្សរជិនាន់៩ឆ្នាំ។ ឈ្មោះ ង៉ាត់ ហៅ សូ អតីតធ្វើតស្សរជិនាន់៩ឆ្នាំ នៅជាមួយបង រ៉ឹក និង បងយ៉ា ហើយពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៨ ធ្វើជាលេខាតំបន់២៣។ ពេលខ្ញុំបានមកដល់ខេត្តស្វាយរៀង ខ្ញុំបានទាក់ទងអ្នកទាំង៨នាក់ខាងលើបានទាំងអស់ ដើម្បីក្តាប់កម្លាំងខាងលោកសេរីខ្លាំងជាងប្ញ ក៏ខាងកុម្មុយនីស្តខ្លាំងជាង។ ប៉ុន្តែខ្សែរបស់ខ្ញុំបានឱ្យការណ៍ថា កម្លាំងលោកសេរីខ្លាំងជាងកុម្មុយនីស្ត។ នៅពេលនោះរាជការក៏ចាត់ចែងឈ្មោះខ្ញុំឱ្យទៅបង្រៀននៅសាលាគគីសោម ស្ថិតក្នុងឃុំគគីសោម ស្រុកប្រសូត្រ តំបន់២៣។ ខ្ញុំក៏ទៅនៅសាលាគគីសោម ដែលជាស្រុកកំណើតរបស់ខ្ញុំ។ ដល់ស្រុកកំណើត ខ្ញុំក៏ចាប់ផ្តើមធ្វើសកម្មភាពកសាងកម្លាំងនៅភូមិត្បែង ដោយឃោសនាអប់រំប្រជាជនអំពីសិទ្ធិសេរីភាព និងលើកពីឥទ្ធិពលលោកសេរីវាយប្រហារបក្សកុម្មុយនីស្ត។

ពីឆ្នាំ១៩៥៨ ដល់ឆ្នាំ១៩៥៩ ខ្ញុំបានកសាងកម្លាំងបានម្នាក់ឈ្មោះ សុខ ជិន អតីតជាអ្នករកស៊ីរត់ពន្ធនៅភូមិត្បែង ឃុំគគីសោម បច្ចុប្បន្នជាអនុប្រធានសហករណ៍ ភូមិត្បែង ឃុំគគីសោម ស្រុកប្រសូត្រ តំបន់២៣។ សុខ ជិនបានចូលជា សេ-អ៊ី-អា ដោយមានកម្មវិធីទទួលស្គាល់ដោយ បងសូ។ ខ្ញុំនៅតែបន្តកសាងកម្លាំងបន្ថែមទៀតបានចំនួន២នាក់ ស្ថិតក្នុងភូមិក្បាលជ្រូក គឺឈ្មោះ គង់ សាជា អតីត

ជាកូនសិស្សអនុវិទ្យាល័យក្រុងស្វាយរៀង បច្ចុប្បន្នជាប្រជាជនឃុំចេក ស្រុកមានជ័យថ្មី តំបន់២៣ និងឈ្មោះ សារឿន អតីតអ្នករត់ពន្ធ បច្ចុប្បន្នមានតួនាទីជាប្រធានសហករណ៍ភូមិត្បែង ឃុំគគីសោម។

នៅក្នុងឆ្នាំ១៩៦០ ខ្ញុំនិងបងសូបានរួមសកម្មភាពជាមួយគ្នានៅភូមិព្រៃតាអី ឃុំគគីសោម គឺដើរឃោសនាលើកឥទ្ធិពលលោកសេរី ដេររបបកុម្មុយនីស្តបំភ័យប្រជាជនឱ្យខ្លាចរបបកុម្មុយនីស្ត។ ក្រោយពីឃោសនាហើយ ខ្ញុំបានកសាងកម្លាំងបានម្នាក់ឈ្មោះ អុក ភិត អតីតជាអ្នករត់ពន្ធទៅផ្សារទ្រៀង និងជាអ្នកធ្វើស្រែនៅភូមិព្រៃតាធឹក ឃុំគគីសោម។

ពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៤ ខ្ញុំចាប់ផ្តើមទាក់ទងខ្មែរចាស់ៗ ដូចជាឈ្មោះ បងសូ និង វ៉ុត ដើម្បីចុះធ្វើសកម្មភាពដើរឃោសនាអប់រំប្រជាជនថ្មីតាមមូលដ្ឋាននីមួយៗ ឱ្យធ្វើសកម្មភាពនៅឃុំគគីរសោម ចំណែកខ្ញុំធ្វើសកម្មភាពផ្នែកគ្រូនៅឃុំស្វាយជ្រំ និងក្រុងស្វាយរៀង។ សកម្មភាពក្រុមខ្ញុំគ្មានអ្វីថ្មីទេ គឺមានតែធ្វើឱ្យប្រជាជនខ្លាច និងស្អប់អង្គការបដិវត្តន៍។

នៅឆ្នាំ១៩៦៥ បងសូបានខទ្មេសនាមខ្មែរចាស់របស់គាត់ ឱ្យមកខ្ញុំធ្វើការ ទាក់ទងក្នុងគោលបំណងឃោសនាអប់រំមិនឱ្យជឿក្រុមខ្មែរក្រហមឱ្យប្រជាជនស្រឡាញ់របបលោកសេរី ធ្វើសកម្មភាពតាមដានក្រុមខ្មែរក្រហមនៅតាមមូលដ្ឋាននីមួយៗ។ សកម្មភាពខាងលើនេះ បងសូ និង ខ្ញុំបានចែកទីតាំងធ្វើសកម្មភាពទៅតាមឈ្មោះ ដូចជា៖ ១) ឆែប អតីតអ្នករកស៊ីរត់ពន្ធទៅផ្សារទ្រៀង និងធ្វើស្រែនៅភូមិព្រៃតាអី ឃុំគគីសោម ក្រោយឆ្នាំ១៩៧០ ជាប្រធានយោធាតំបន់២៣។ ២) ស៊ែល អតីតអ្នករកស៊ីលក់នំបញ្ចុកម្ជូរស្លា និងធ្វើស្រែនៅភូមិថ្នល់កែង ក្រោយឆ្នាំ១៩៧០ គឺជាអនុប្រធានយោធាតំបន់២៣។ ៣) សាលីវ អតីតឥស្សរជនជិនាន់៩ឆ្នាំ មានស្រុកកំណើតនៅកំពង់រោទ៍ តំបន់២៣ ក្រោយឆ្នាំ១៩៧០ គឺជាលេខាស្រុកប្រសូត្រ។ ៤) វុត្ថា អតីតរកស៊ីជួញស្រូវ ក្រោយឆ្នាំ១៩៧០ មានតួនាទីជាប្រធានពាណិជ្ជកម្មស្រុកប្រសូត្រ។ ៥) សំអន អតីតធ្វើឥស្សរជនិនាន់៩ឆ្នាំ ក្រោយឆ្នាំ១៩៧០ មានតួនាទីជាលេខាស្រុកចន្ទ្រា។ ៦) សំអឿន អតីតធ្វើឥស្សរជនិនាន់៨ឆ្នាំ ក្រោយឆ្នាំ១៩៧០ មានតួនាទីជាលេខាស្រុកក្រសាំង តំបន់២៣។ ៧) សយ អតីតធ្វើឥស្សរជនិនាន់៩ឆ្នាំ ក្រោយឆ្នាំ១៩៧០ ជាលេខាស្រុកមានជ័យថ្មី។ ៨) ចាន់ស៊ុវ៉ាន់ ហៅ គួន អតីតធ្វើឥស្សរជនិនាន់៩ឆ្នាំ ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៦ ធ្វើជាលេខាស្រុកមានជ័យថ្មី ស្រុកស្វាយរៀង។ ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ មានតួនាទីជាអនុលេខាតំបន់២៣។ ៩) សៅ យុន ហៅ សៅ សារ៉ែត អតីតធ្វើឥស្សរជនិនាន់៩ឆ្នាំ ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៦ មានតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍ ស្រុកសំរោង និងនៅឆ្នាំ១៩៧៧ មាននាទីជាលេខាស្រុកសំរោង។ ១០) សាអែម អតីតជាអ្នករកស៊ីជួញមាន់ទា គោក្របី ដល់ឆ្នាំ១៩៧០ មាននាទីជាប្រធានឃុំម៉ឺនដៃ ស្រុកសំរោង តំបន់២៣។ ១១) ជិន អតីតអ្នករកស៊ីរត់ពន្ធមាន់ទា ក្រោយឆ្នាំ១៩៧០ មានតួនាទីជាប្រធានសន្តិសុខស្រុកសំរោង តំបន់២៣។

នៅឆ្នាំ១៩៦៦ ឈ្មោះ ទិត ឈុន បានរាយការណ៍ពាក្យផ្តែផ្តាំរបស់ បងយ៉ា ពីទីក្រុងភ្នំពេញថា នៅចុងខែធ្នូ ឆ្នាំ១៩៦៦ ខាងមុខនេះ បងយ៉ា ត្រូវដកខ្លួនចេញពីភ្នំពេញ ពេលទទួលដំណឹងនេះហើយ សូមឱ្យឈប់រាយការណ៍ដំណឹងទៅបងយ៉ា ទៀត។ ទិត ឈុន ត្រូវមានតួនាទីរាយការណ៍ផ្ទាល់ទៅកាន់បងសូ និងបងវ៉ុត។ នៅឆ្នាំ១៩៦៧ បងសូ បានហៅឈ្មោះគ្រូនៅក្នុងខេត្តស្វាយរៀងចំនួន៦នាក់ មកជួបជុំ និងរំឭកផែនការដែលបានឱ្យធ្វើសកម្មភាព។ ខ្ញុំបានយកផែនការឃោសនាអប់រំប្រជាជននៅក្នុងភូមិកក់ ភូមិកញ្ចែក ឱ្យប្រជាជនប្រឆាំងនឹងខ្មែរក្រហម និងតាមដានសកម្មភាពខ្មែរក្រហមឱ្យជាប់។

នៅដើមឆ្នាំ១៩៦៩ បងសូ បានហៅបង វ៉ុក, ទិត ឈុន និង ខ្ញុំ មកពិភាក្សាដើម្បីចាត់ចែងកម្លាំងចូលបង្កប់ក្នុងជួរបដិវត្តន៍។ ក្រោយពីពិភាក្សារួច ក៏មានបែងចែកជា២ផ្នែក គឺផ្នែកទី១ ចូលបង្កប់ក្នុងព្រៃមានបងវ៉ុក, សំអន, សំអឿន, ស៊ែល, ឆែម, សាលីវ, បងគួន, បងសូ, សៅ សារ៉ែត និង សយ។ ផ្នែកទី២ ចូលបង្កប់ក្នុងមូលដ្ឋានមានខ្ញុំ, សុខជិន, គង់ សាជា,

សេក សារឿន, ទេព សុន, ប៉ែន សាក់, គីម សំ, រិត ឈុន, ចាន់ ម៉ៅ, ចាន អោក និង អន យ៉ុន។ ផ្នែកទី ២ នេះ គឺបងសូ ចាត់តាំងឱ្យចូលបង្កប់ក្នុងជួរបដិវត្តន៍ ដើម្បីកសាងកម្លាំងសហការជាមួយយួន ក្ដាប់រដ្ឋអំណាចពេលរដ្ឋប្រហារខាងមុខ។ ចំណែកអ្នកនៅសល់ពីការចូលបង្កប់ខ្លួនក្នុងបដិវត្តន៍គឺត្រូវកសាងកម្លាំងតាមមូលដ្ឋាន និងបំផុសឱ្យប្រជាជនស្អប់ និងប្រឆាំងខ្មែរក្រហម។

ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្ដម សីហនុ ពេលនោះបក្សពួកខ្ញុំដែលបង្កប់ក្នុងជួរបដិវត្តន៍នៅព្រៃ ក៏ចេញមកពីក្នុងព្រៃវិញ មករស់នៅក្នុងភូមិឃុំស្រុកគ្រប់ៗគ្នា។ ឈ្មោះអ្នកដែលចេញពីក្នុងព្រៃមក បងសូ បានខទ្វេសនាម និងឱ្យទទួលតួនាទីដូចជា៖ បងសូ ត្រូវទទួលនាទីជាលេខាស្រុកកំពង់រោទិ៍។ សាលីវ ត្រូវទទួលនាទីជាលេខាស្រុកប្រសូត្រ។ សយ ទទួលនាទី ជាប្រធានសន្តិសុខស្រុកកំពង់រោទិ៍។ សៅ សារ៉េត ទទួលនាទីជាប្រធានសន្តិសុខ ស្រុកសំរោង ហើយជាសមាជិកស្រុកសំរោង។ បងសំអន ទទួលនាទីជាអនុលេខាស្រុករមាសហែក។ បងសំអឿន ទទួលនាទីជាលេខាស្រុកក្រសាំង។ បងតួន ទទួលនាទីជាអនុលេខាស្រុករមាសហែក។ បងរ៉ុក ទទួលនាទីជាលេខាស្រុកសំរោង។ ឆែម ទទួលនាទីជាប្រធានយោធាស្រុកសំរោង។ ស៊ែល ទទួលនាទីជាអនុយោធាស្រុកសំរោង។ ចំណែកខ្ញុំ បងរ៉ុកបានហៅខ្ញុំទៅនៅជាមួយគាត់ ដោយប្រគល់តួនាទីជាប្រធានសេដ្ឋកិច្ចស្រុកសំរោង។ នៅចុងឆ្នាំ១៩៧០ ខ្ញុំបានទៅចូលរួមធ្វើសកម្មភាពជាបងតួន លេខាស្រុករមាសហែក និង បងសំអន អនុលេខាស្រុករមាសហែក បានចុះទៅមូលដ្ឋានរៃយកស្រូវពីប្រជាជនគឺមួយគ្រួសារយកមួយថាំងស្រូវ អ្នកមានអ្នកក្រ គឺគិតដូចគ្នា។ បើប្រជាជនណាមិនមានស្រូវផ្ដល់ជូន និងចាប់ដាក់ក្នុងសន្តិសុខ ធ្វើឱ្យប្រជាជនមានការតក់ស្លុត និងភ័យខ្លាចចំពោះអង្គការបដិវត្តន៍។ ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ ខ្ញុំនៅតែបន្តធ្វើសកម្មភាពកសាងកម្លាំងជាមួយបងៗលេខាស្រុក ធ្វើយ៉ាងណាកុំឱ្យប្រជាជនមានភាពកក់ក្ដៅជាមួយបដិវត្តន៍ និងដើររៃស្រូវអង្ករពីប្រជាជនដដែល។

នៅឆ្នាំ១៩៧៣ បងសូ ឡើងធ្វើជាលេខាតំបន់ ២៣ រួចក៏ហៅគ្នាមកប្រជុំនៅស្រុករមាសហែក ដែលជាតំបន់ខ្ញុំធ្វើការ។ ខ្លឹមសារនៃការពិភាក្សាគឺមានដូចជា ត្រូវត្រៀមខ្លួនបំផ្លើសមាគ៌ាសហករណ៍របស់អង្គការក្នុងឆ្នាំ១៩៧៣, ត្រូវកសាងកម្លាំងក្នុងបដិវត្តន៍ឱ្យបានច្រើន ដើម្បីក្ដាប់សហករណ៍ និង ត្រូវបំផុសមាគ៌ាឱ្យកាន់តែខ្លាំងឡើង។ នៅក្នុងអង្គប្រជុំ បងសូ ក៏បានប្រកាសដក ឆែម និង ស៊ែល ចេញពីស្រុកសំរោង មកកាន់ការងារក្នុងតំបន់វិញ។ បន្ទាប់មកបងសូ បានខទ្វេសនាមឈ្មោះ៥នាក់ទៀតឱ្យចូលរួមធ្វើសកម្មភាពបន្តទៀតមានដូចជា៖ ១) ឯក សាមាន ហៅ សាក់ អតីតអ្នកបើកឡាន នៅក្រុងស្វាយរៀង មាននាទីជាប្រធានមន្ទីរតំបន់ ២៣។ ២) ឈាន អតីតក្ដាប់មិនបាន មាននាទីជាប្រធានយុវជនតំបន់២៣។ សាវ៉ាវុទ្ធី អតីតក្ដាប់មិនបាន មាននាទីជាអនុប្រធានវប្បធម៌ ឃោសនាការ សិល្បៈតំបន់២៣ ហើយនៅឆ្នាំ១៩៧៦ មាននាទីជាប្រធានវប្បធម៌ ឃោសនាការសិល្បៈតំបន់២៣។ មាង ហៅ សាម អតីតអ្នករកស៊ីរត់ពន្ធនៅផ្សារជ្រៀង និងធ្វើស្រែនៅភូមិថ្នល់ទទឹង បច្ចុប្បន្នមាននាទីជាប្រធានសន្តិសុខតំបន់២៣។ ទាប អតីតក្ដាប់មិនបាន បច្ចុប្បន្នមាននាទីជាប្រធានសេដ្ឋកិច្ចតំបន់២៣។ ក្រោយពីបងសូ បានខទ្វេសនាមរួច ខ្ញុំមានតួនាទីយកផែនការទាំងនោះទៅផ្សព្វផ្សាយឱ្យខ្សែរបស់ខ្ញុំដែលមិនបានចូលរួមប្រជុំបានដឹងទាំងអស់គ្នា។

នៅខែឧសភា ឆ្នាំ១៩៧៥ ឈូក បានហៅ ខ្ញុំ បងសូ បងតួន ទៅប្រជុំតំបន់២៤ ពេលនោះខ្ញុំឃើញសមាជិកដែលចូលរួមប្រជុំគឺប្រធានតំបន់ជាច្រើន ដើម្បីប្រជុំលើកផែនការសម្រាប់ធ្វើសកម្មភាពឆ្នាំ ១៩៧៥។ គោលបំណងនៃផែនការក្នុងអង្គប្រជុំគឺ ត្រូវក្ដាប់កងទ័ពឱ្យណែន និងពង្រីកកងទ័ពបន្ថែម ដើម្បីត្រៀមធ្វើរដ្ឋប្រហារនៅថ្ងៃខាងមុខ។ នៅចុងឆ្នាំ១៩៧៥ បងសូ បានហៅខ្ញុំឱ្យទៅ ទាក់ទង

យួននៅព្រំដែនបាវិត ឈ្មោះ ទីវ៉ែរ ជាចៅហ្វាយខេត្តឡុងអាង។ ពេលត្រឡប់មកពីទាក់ទងយួនរួច បងសូក៏បានហៅគ្នាប្រជុំដើម្បីរាយការណ៍ជូនអង្គប្រជុំពីការយល់ព្រមរបស់យួន តាមសំណូមពររបស់យើងឱ្យយួនយកកងទ័ពមកដាក់តាមព្រំដែនដើម្បីការពារកុំឱ្យកងទ័ពកម្ពុជាទៅជិតព្រំដែន។ សុំឱ្យយួនចូលមកទឹកដីខ្មែរនៅតាមព្រំដែន យកស្រូវអង្ករ គោ ក្របីរបស់ប្រជាជនខ្មែរ និងប្រជាជនខ្មែរដែលយួនកៀរយកទៅបានសុំឱ្យទៅរស់នៅខាងយួន។

នៅចុងឆ្នាំ១៩៧៦ អង្គការបានចាប់ ឈូក, ហាក់, ធុច, កែវ អាន, យ៉ា និង ដៃ សារី ដែលសុទ្ធតែថ្នាក់ដឹកនាំធំៗ។ ក្រោយពីដឹងដំណឹងពីការចាប់ខ្លួនសមាជិកតាមតំបន់ បងសូ ក៏ទាក់ទងទៅចៅហ្វាយខេត្ត ឡុងអាង ប្រទេសវៀតណាម ដើម្បីរាយការណ៍ពីការចាប់ខ្លួនអ្នកខាងលើ។ ដោយសារអង្គការបានចាប់បក្ខពួកធំៗអស់ជាច្រើន ទើបសកម្មភាពធ្វើរដ្ឋប្រហារត្រូវផ្អាកសិន។ កងទ័ពវៀតណាមនៅតាមព្រំដែនត្រូវបងសូស្នើឱ្យរក្សាទុកនៅដដែល តែបង្កើនការផ្សាំងគ្រាប់ចូលទឹកដីខ្មែរឱ្យបានកាន់តែច្រើន ដើម្បីកុំឲ្យប្រជាជនខ្មែរទៅធ្វើស្រែនៅតាមព្រំដែនបាន។ ចំណែកខាងវៀតណាមទទួលយកតាមការស្នើភ្លាមៗ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ បងសូ និង ខ្ញុំ រៀបចំកន្លែងប្រជុំនៅជាយក្រុងស្វាយរៀង ចំណុចត្រើយតាហោ ខាងកើត ជាមួយបងៗប្រធានតំបន់ក្នុងភូមិភាគ មុននឹងទៅជួបចៅហ្វាយខេត្ត ឡុងអាងនៅតាមព្រំដែនបាវិតដើម្បីរាយការណ៍ និងស្នើសុំឱ្យខាងយួនចូលមកវាយលុកយកខេត្តស្វាយរៀងនៅដើមខែធ្នូ ឆ្នាំ១៩៧៧ ហេតុនេះសូមឱ្យខាងយួនជួយត្រៀមកម្លាំងឱ្យរួចរាល់។ ពេលដែលកងកម្លាំងយួនចូលមកដល់ប្រទេសខ្មែរ សូមឱ្យមានការជឿជាក់លើទំនាក់ទំនងរវាងខ្មែរនិងយួន ដើម្បីងាយស្រួលក្នុងការក្តាប់កម្លាំងបានទាំងសងខាង។ ពេលកងទ័ពចូលមកដល់ខេត្តស្វាយរៀង ប្រជាជនត្រូវជម្លៀសទៅរស់នៅខាងយួន ដើម្បីសុំឱ្យបងប្អូនយួនជួយឧបត្ថម្ភ។ ចំណុចខាងលើនេះ បងសូ នឹងមកជួបប្រជុំម្តងទៀតក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ដើម្បីសុំការសម្រេចនូវការកិច្ចខាងលើ។ ភាគីខាងយួន បានទទួលតាមការស្នើទាំងអស់ និងសន្យាថា នឹងរៀបចំកងទ័ពឱ្យបានគ្រប់ចំនួន ដើម្បីវាយចូលមកខេត្តស្វាយរៀង។ មកដល់ខែកញ្ញា ឆ្នាំ១៩៧៧ បងសូបានទៅជួបប្រជុំម្តងទៀតជាមួយភាគីខាងយួន ដើម្បីរាយការណ៍ពីកម្លាំងដែលយួនត្រូវទាក់ទងពេលវាយចូលមកខ្មែរ។ ប៉ុន្តែឈ្មោះ ទីវ៉ែរ ចៅហ្វាយខេត្ត ឡុងអាង បានសំណូមពរឲ្យបងសូ ដកទ័ពតំបន់ស្រុកចេញឱ្យអស់ពីព្រំដែននៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៧ បើសិនជាឃើញកងទ័ពយួនចូលទៅ សូមកុំឱ្យបាញ់ ត្រូវគេចចេញឱ្យអស់។ បងសូ យល់ព្រមតាមសំណូមពរទាំងអស់ រួចអង្គប្រជុំបានបិទ។ បងសូបានស្នើសុំឱ្យគ្រប់ស្រុកតំបន់ដែលមានទ័ពបោះនៅតាមព្រំដែន ធ្វើតាមសំណូមពរយួនត្រូវដកទ័ពចេញឲ្យអស់មុនថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៧ ដើម្បីជៀសវាងកុំឱ្យមានការប៉ះទង្គិចគ្នា។ ពេលកងទ័ពយួនចូលមកដល់ខេត្តស្វាយរៀង អង្គការភូមិភាគបានប្រគល់អង្ករឱ្យខាងពាណិជ្ជកម្មតំបន់២៣ ចំនួន ១៦០០០បាវ សម្រាប់ដោះស្រាយជីវភាពប្រជាជន។ ខ្ញុំបានកំណត់អង្ករចែកជូនប្រជាជនហូបចំនួន៤ស្រុក គឺ ស្រុកប្រសូត្រ ស្រុកកំពង់រោទិ៍ ស្រុកចន្ទ្រា និង ស្រុកសំរោង ដោយប្រជាជនម្នាក់ទទួលបានមួយកំប៉ុងក្នុងមួយថ្ងៃ។ ការកំណត់របបហូបបានបង្កឲ្យប្រជាជនជាច្រើនឈឺស្លាប់ ជាពិសេសកូនក្មេងៗ។ រហូតដល់ថ្ងៃដែលកងទ័ពវៀតណាមដកទ័ពចេញពីខេត្តស្វាយរៀង ទើបស្រុកអាចយកកងចល័តរបស់ខ្លួនទៅច្រូតស្រូវ ដើម្បីដោះស្រាយជីវភាពប្រជាជន ដោយយករថយន្តរបស់អង្គការជួយដឹកស្រូវមកកិនរួចចែកប្រជាជនហូបក្នុងមួយថ្ងៃបានពីរកំប៉ុង។ ពេលកងទ័ពវៀតណាមដកចេញទៅ បានយកក្របី និងគោ ប្រហែលជា៣០ ឬ ៤០ ភាគរយ និង ស្រូវប្រហែលជា២៥ភាគរយ។ សម្ភារដែលខ្ញុំត្រៀមទុកឱ្យកងកម្លាំងវៀតណាម មានដូចជា ប្រេងម៉ាស៊ូត៣២០០០លីត្រ, ចប៥០០០ដើង និងអំបិល១៥០តោន គឺវៀតណាមយកទៅអស់រលីង។

ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំនិងបងសូ

*បានយកឡានមួយគ្រឿង កងការពារពីរនាក់ និង អ្នកបើក ឡានម្នាក់ ទៅ ទាក់ទងវៀតណាមនៅព្រំដែនៗ រថយន្តមកដល់ព្រំដែន ក៏ឃើញកងការពារព្រំដែនយួនរត់ទៅអញ្ជើញបងសូ និងខ្ញុំនាំទៅកាន់កន្លែងប្រជុំៗ បន្តិចក្រោយមក យើងក៏បើកអង្គប្រជុំ ដោយភាគីខាងវៀតណាមមានគ្នាពីរនាក់គឺ ទីវែរ ចៅ ហ្វាយខេត្ត ឡុងអាង និង ហ្វាយ សូ គណៈទាក់ទងខេត្តតាយនិញៗ ចំណែកខាងខ្មែរមាន ខ្ញុំ បងសូ និងឆែមៗ ផ្តើមកិច្ចប្រជុំគឺភាគីខាងវៀតណាមឱ្យបងសូរាយការណ៍សកម្មភាពប្រទេសខ្មែរឱ្យស្តាប់ដូចជា ៖ កងទ័ពខ្មែរក្រហមឡើងមកកាន់ខេត្តស្វាយរៀងច្រើន និងកំពុងបន្ថែមមកទៀតៗ កងទ័ពដែលដេញកងទ័ពវៀតណាម គឺជាកងទ័ពអង្គការផ្ទាល់ មិនមែនជាកងទ័ពតំបន់ ឬស្រុកនោះទេៗ បងសូ បន្ថែមថា ការដែលគាត់ឡើងមកប្រជុំនេះ គឺដើម្បីពិភាក្សាពីការត្រៀមធ្វើរដ្ឋប្រហារក្នុងខែមីនា ឬ ខែមេសា ដើម្បីសហការជាមួយវៀតណាមៗ ក្រោយរាយការណ៍ក៏មានការពិភាក្សាចុះឡើង តែ ហ្វាយ សូ សួរទៅកាន់បងសូ ថា តើត្រូវការកងទ័ពប៉ុន្មានដើម្បីធ្វើរដ្ឋប្រហារបាន? បងសូ តបថាសុំចំនួន៥កងពល គឺគ្រប់គ្រាន់ហើយៗ ចំណែកថ្ងៃដែលត្រូវធ្វើរដ្ឋប្រហារគឺ បងសូសុំធ្វើក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ៗ ប្រជុំចប់ខ្ញុំនិងបងៗ ក៏ត្រឡប់មកមូលដ្ឋានវិញៗ ខ្ញុំត្រូវបងសូឱ្យចុះបំពេញភារកិច្ចនៅតាមមូលដ្ឋានស្រុករយៈពេល១៣ថ្ងៃរហូតដល់ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៨ ទើបវិលមកកន្លែងវិញៗ អង្គការបានផ្តល់ក្រណាត់មកឱ្យខ្ញុំច្រើន ខ្ញុំត្រូវធ្វើដំណើរចុះចែកក្រណាត់ ស្រាប់តែអង្គការមកចាប់ខ្លួនខ្ញុំក្នុងថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៨ៗ*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ D៤១៥៤៥ៗ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ហេង សោយ ហៅ ម៉ក់ ពិត ឬយ៉ាងណានោះទេ?***



*សំឡីគ ដែលខ្មែរក្រហមគាបដាក់ក្នុងបាវសម្រាប់នាំចេញទៅបរទេស នៅអំឡុងឆ្នាំ១៩៧៨ ក្នុងរបបខ្មែរក្រហមៗ (ហ្គុនណា ប៊ីយស្ត្រម/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅ
## តាមដងទន្លេមេគង្គនៅខេត្តកំពង់ចាម និងខេត្តស្ទឹងត្រែង រំឭកអំពីព្រឹត្តិការណ៍ទឹកជំនន់ឆ្នាំ១៩៧៨

*លី ដេវីត និង ស្រេង លីដា*



*ផ្ទះរបស់ប្រជាជននៅតាមដងទន្លេមេគង្គ ក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ពេលរដូវទឹកឡើង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

កម្ពស់ទឹកទន្លេមេគង្គ ហក់ឡើងខ្ពស់ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ ដែលជាចំណុចដល់គួរឱ្យព្រួយបារម្ភចំពោះប្រជាពលរដ្ឋរស់នៅតាមតំបន់ទន្លេៗ ទោះបីជាស្ថានភាពទឹកជំនន់តាមទន្លេមេគង្គមិនទាន់ឡើងដល់កម្រិតប្រកាសអាសន្ន ប៉ុន្តែប្រជាជនក៏គួរមានការប្រុងប្រយ័ត្នជាមុន ព្រោះកម្ពស់ទឹកបានហូរចូលទៅតាមដៃទន្លេ និងព្រែករួចទៅហើយ ដែលបណ្តាលឱ្យមានការជន់លិចតាមតំបន់មួយចំនួនដែលស្ថិតនៅក្បែរទន្លេមេគង្គ។ ការលិចលង់នៅរដូវវស្សាឆ្នាំរោង បានរំឭកដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលធ្លាប់រស់នៅតាមដងទន្លេមេគង្គនៅខេត្តកំពង់ចាម និងខេត្តស្ទឹងត្រែង អំពីព្រឹត្តិការណ៍ទឹកជំនន់ឆ្នាំ១៩៧៨។ ខាងក្រោមនេះគឺជាការរៀបរាប់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅខេត្តកំពង់ចាម និងខេត្តស្ទឹងត្រែង៖

ខ្ញុំឈ្មោះ ឌឹម គឹមសាន គឺជាមេភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ទឹកជំនន់ឆ្នាំនេះ បានបណ្តាលឱ្យមានការលិចផ្លូវចម្ការ និងទឹកន្លែងជាច្រើនទៀតនៅតាមមូលដ្ឋាន។ ទឹកជំនន់ បានរំឭកខ្ញុំអំពីព្រឹត្តិការណ៍នៃទឹកជំនន់ឆ្នាំ១៩៧៨ ដែលត្រូវនឹងឆ្នាំរោង។ អ្នករស់រានមាន

ជីវិតពីរបបខ្មែរក្រហម តែងនិយាយថា ក្នុងរបបខ្មែរក្រហមមានទឹកធំនោះ គឺទឹកជំនន់ឆ្នាំ១៩៧៨។ នាគ្រានោះ ភូមិរបស់ខ្ញុំត្រូវបានទឹកជន់លិច មិនមានដីដើម្បីធ្វើស្រែ និងដាំដំណាំនោះឡើយ។ អ្នកភូមិត្រូវបន្តធ្វើការងារនៅតាមផ្ទះរៀងៗខ្លួនអស់រយៈពេល១ខែ។ ជាញឹកញាប់ កងឈ្លបខ្មែរក្រហមត្រូវបានបញ្ជូនមកដើម្បីតាមដានអ្នកភូមិ ថាតើអ្នកភូមិណាមិនធ្វើការ ឬនិយាយអ្វីខ្លះ។ ក្នុងរយៈពេលជាង១ខែនៃទឹកជំនន់ឆ្នាំ១៩៧៨នេះ អ្នកភូមិមានពេលសម្រាកនៅលើផ្ទះ និងអាចទៅហូបបាយនៅរោងបាយរួមដែលស្ថិតនៅទីទួលមួយនៅក្នុងភូមិ។ បើទោះបីជាមិនទៅធ្វើការងារនៅតាមការដ្ឋានក៏ដោយ អ្នកភូមិនៅតែបន្តការងាររើសគ្រាប់ពោត និងមិនហ៊ានឈប់សម្រាកទេ។ នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានចូលមករំដោះប្រជាជនចេញពីរបបខ្មែរក្រហម។ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់ និងបន្តធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃនេះ។

ខ្ញុំឈ្មោះ ម៉ៅ វណ្ណា អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំគឺជាអតីតនាយកសាលាបឋមសិក្សាទីប្រជុំដែលស្ថិតនៅភូមិទី៨នេះ។ រាល់គ្រាដែលមានទឹកជំនន់រដូវវស្សាលិចភូមិ ខ្ញុំតែងតែនឹកឃើញឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំដែលត្រូវបានខ្មែរក្រហមសម្លាប់រួចទម្លាក់ចូលទន្លេក្នុងរដូវគ្រោះទឹកជំនន់ ឆ្នាំ១៩៧៨។ ខ្មែរក្រហមយកប្រជាជនទៅសម្លាប់នៅវត្តក្បាលកោះ និងបរិវេណជុំវិញ។ ប្រជាជន៧៥ (ប្រជាជនថ្មី) ជាច្រើនគ្រួសារត្រូវបានកងឈ្លបខ្មែរក្រហមដឹកយកទៅសម្លាប់នៅវត្តក្បាលកោះ។ មានការកាប់សម្លាប់ប្រជាជនកាន់តែច្រើនឡើងចាប់ពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨ គឺនៅពេលដែលកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកដល់។ អតីតកម្មាភិបាលភូមិភាគបូព៌ា កម្រិតមូលដ្ឋាន ប្រជាជន៧៥ ដែលនៅសេសសល់ និងប្រជាជន៧៣ដែលប្រព្រឹត្តកំហុសធ្ងន់ត្រូវបានចាប់ និងដឹកយកទៅសម្លាប់នៅវត្តក្បាលកោះ។ បើទោះបីជាមានទឹកជំនន់លិចភូមិ និងទីតាំងសម្លាប់វត្តក្បាលកោះ នាខែវស្សាឆ្នាំ១៩៧៨ ក៏ខ្មែរក្រហមនៅតែបន្តសម្លាប់ប្រជាជន ដោយដឹកតាមកាណូតយកទៅសម្លាប់ និងបោះចោលចូលទឹកទន្លេ។ ឪពុកម្តាយនិងបងប្អូនប្រុសស្រីរបស់ខ្ញុំក៏ជាជនរងគ្រោះដែលត្រូវបានសម្លាប់ក្នុងព្រឹត្តិការណ៍សម្លាប់ប្រជាជនបោះចូលទន្លេ នៅពេលដែលមានទឹកជំនន់ឆ្នាំ១៩៧៨។

ខ្ញុំឈ្មោះ ទាវ ផាយ ភេទស្រី អាយុ៦៨ឆ្នាំ កើតនៅខេត្តស្វាយរៀង។ សព្វថ្ងៃខ្ញុំរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ក្នុងនោះស្រី៣នាក់។ ប្តីខ្ញុំឈ្មោះ សើង សារ៉ាង ក្រោយរៀបការយើងមានកូនចំនួន៣នាក់។ កាលពីវ័យកុមារ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១(ចាស់)។ ខ្ញុំមករស់នៅនិគមជនអូរស្វាយចាប់តាំងពីឆ្នាំ១៩៦៧ ដែលនៅពេលនោះ ខ្ញុំទើបតែមានអាយុ១១ឆ្នាំ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំនិងគ្រួសារបានផ្លាស់ទៅរស់នៅ ទំពាំងទា- ទំពាំងមាន់ ដើម្បីវែកដី លើកភ្លឺស្រែ និងទំនប់។ ខ្ញុំត្រូវដើបពីម៉ោង៤ព្រឹកទៅធ្វើស្រែ និងលើកទំនប់ រហូតដល់





ប្រជាជនដែលរស់នៅឆ្លងកាត់គ្រោះទឹកជំនន់ក្នុងរបបខ្មែរក្រហម នៅឆ្នាំ១៩៧៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ោង៦ល្ងាចទើបឈប់សម្រាក។ ខ្ញុំទទួលបានរបបអាហារពីរពេលក្នុងមួយថ្ងៃ គឺបាយលាយជាមួយគល់ចេក មើមក្ដួច និងពោត។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងប្រុសម្នាក់ឈ្មោះ គង់ រេន។ ខ្ញុំមិនដឹងថាគាត់ធ្វើខុសអ្វីនោះទេ ទើបបានជាខ្មែរក្រហមយកគាត់ទៅសម្លាប់ចោល។ ខ្ញុំក៏ធ្លាប់ឃើញខ្មែរក្រហមរៀបការឱ្យអ្នកភូមិដែរ ដែលការរៀបការមានចំនួនចាប់ពី៧គូទៅដល់១០គូ។ ក្នុងពិធីរៀបការនោះពេលនោះ អង្គការមិននិយាយអ្វីច្រើននោះទេ គឺឱ្យប្ដីប្រពន្ធធ្វើការប្ដេជ្ញាចិត្តចំពោះអង្គការ និងខិតខំបម្រើអង្គការ ខំបង្កបង្កើនផលស្រូវឱ្យបាន៣តោនក្នុងមួយហិកតា។ នៅឆ្នាំ១៩៧៨ មានទឹកជំនន់មួយយ៉ាងធំដែលបណ្ដាលឱ្យមានការលិចលង់នៅតាមកន្លែងមួយចំនួន។ នាគ្រានោះ អង្គការបានជម្លៀសគ្រួសារខ្ញុំទៅរស់នៅភូមិសាមខួយ។ បើទោះបីជាមិនអាចធ្វើស្រែដែលត្រូវបានជន់លិច ក៏អង្គការឱ្យខ្ញុំរកទីទួលមិនលិចទឹកដើម្បីដាំដុះ និងធ្វើស្រែ។ នៅពេលនោះការហូបចុកកាន់តែខ្វះខាត។ ទឹកជំនន់ឆ្នាំ១៩៧៨មានរយៈពេលប្រហែលកន្លះខែ ទើបស្រកទៅវិញ។ ស្រូវ និងពោតត្រូវបានខូចខាតទាំងអស់។







ទឹកជំនន់នៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម នៅឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផ្ទះសហគមន៍ជនជាតិស្មៀង ភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម បើកឱ្យសិស្សមកអានសៀវភៅ សិក្សារៀនសូត្រ និងស្រាវជ្រាវបន្ថែម ទាក់ទងនឹងប្រវត្តិសាស្ត្រ បន្ទាប់ពីសិក្សានៅក្នុងថ្នាក់រៀន

**ផ្សុង ដានី**



សិស្សសាលាបឋមសិក្សា និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ មកទស្សនារូបថត និងអានសៀវភៅនៅផ្ទះសហគមន៍ភូមិក្តុលលើ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ សិស្សសាលាបឋមសិក្សា និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ ចំនួន៨៣នាក់ បានមកទស្សនាពិព័រណ៍រូបថត និងអានសៀវភៅ ទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមនៅផ្ទះសហគមន៍ភូមិក្តុលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្ម ដើម្បីបង្កើនចំណេះដឹង និងសិក្សាឈ្វេងយល់បន្ថែមបន្ទាប់ពីសិក្សានៅក្នុងថ្នាក់រៀន។

លោក ឈុំ រ៉ា បុគ្គលិកនៅផ្ទះសហគមន៍ជនជាតិស្មៀងភូមិក្តុលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្ម ធ្វើការណែនាំខ្លួន និងក្រុមការងារទៅកាន់សិស្សានុសិស្ស។ លោក ឈុំរ៉ាបានរៀបរាប់ថាផ្ទះសហគមន៍ជនជាតិស្មៀងនៅភូមិក្តុលលើ ចាប់ផ្តើមជួសជុលនៅខែមីនា ឆ្នាំ២០២៤ និងបានបញ្ចប់ទាំងស្រុងនៅដើមខែកញ្ញា ឆ្នាំ២០២៤។ ទីតាំងនេះគឺជាអំណោយរបស់យាយ ម៉ែន ប្រាញ់ ដល់មជ្ឈមណ្ឌលឯកសារកោះថ្ម ដើម្បីជួលជុល និងរៀបចំដើម្បីបម្រើដល់ផលប្រយោជន៍រួមរបស់ប្រជាជននៅក្នុងសហគមន៍ទាំងមូល។ បន្ទាប់មក លោក ឈុំ រ៉ា បានដឹកនាំសិស្ស

ឡើងទៅជាន់ខាងលើផ្ទះសហគមន៍ជនជាតិស្ទៀងភូមិក្តុលលើ ដើម្បីថ្វាយបង្គំព្រះពុទ្ធរូប ព្រមទាំងទស្សនាទេសភាពចម្ការផ្លែឈើ និងវាលស្រែពណ៌បៃតងស្រស់ដ៏ធំល្វឹងល្វើយ។ ទេសភាពដ៏ស្រស់ត្រកាលទាំងនេះ បានធ្វើឱ្យសិស្សានុសិស្សមានអារម្មណ៍ស្រស់ស្រាយ និងសប្បាយរីករាយ។

បន្ទាប់មក លោក ឈុំ វ៉ា បានដឹកនាំសិស្សចុះមកខាងក្រោម ដើម្បីទស្សនាពិព័រណ៍ព្រះឆាយាល័ក្ខណ៍ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ, រូបភាពជនរងគ្រោះក្នុងគុកទួលស្លែង និងសៀវភៅប្រវត្តិសាស្ត្រ។ នៅក្នុងឱកាសនោះ សិស្សានុសិស្សអាចជ្រើសរើសសៀវភៅដែលខ្លួនចូលចិត្តយកមកអាន។ សិស្សភាគច្រើនបានអានទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកោះថ្ម លេខពិសេស ឆ្នាំ២០២៤ ដែលរៀបរាប់អំពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៨រូបទៀត ចាកចេញពីទីតាំងបន្ទាយកងវរសេនាធំតំបន់២១ តំបន់កោះថ្ម ភូមិភាគបូព៌ា ទៅកាន់ប្រទេសវៀតណាម ដើម្បីកសាងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧, សៀវភៅ សាក្សីប្រវត្តិសាស្ត្រ, សៀវភៅបូជាភ្លើង, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩), សៀវភៅវិញ្ញាណក្ខន្ធ ជនរងគ្រោះពីរបបខ្មែរក្រហម និងសៀវភៅជីវិតម្តាយ។

សិស្សានុសិស្សដែលមកអានសៀវភៅ និងសិក្សារៀនសូត្រនៅផ្ទះសហគមន៍ជនជាតិស្ទៀងភូមិក្តុលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្ម បានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

១) នាងខ្ញុំឈ្មោះ **សាន និការ** ភេទស្រី អាយុ១២ឆ្នាំ គឺជាសិស្សថ្នាក់ទី៦ នៃសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន ក្តុលផ្សារ។ ថ្ងៃនេះ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំង ដែលបានមកទស្សនា និងអានសៀវភៅនៅផ្ទះសហគមន៍ជនជាតិស្ទៀងភូមិក្តុលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្ម។ ខ្ញុំមានអារម្មណ៍ស្រស់ស្រាយ និងចង់អានសៀវភៅ ព្រោះទីតាំងនេះមានទេសភាពស្រស់ស្អាត។ ការអានសៀវភៅធ្វើឱ្យខ្ញុំមានចំណេះដឹងជាងមុន និងចេះគិតបានត្រឹមត្រូវ។ នៅផ្ទះសហគមន៍ជនជាតិស្ទៀងភូមិក្តុលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្ម មានសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដូច្នេះធ្វើឱ្យខ្ញុំយល់ដឹងអំពីប្រវត្តិសាស្ត្រ ជាពិសេសទាក់ទងជាមួយរបបខ្មែរក្រហម។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មដែលអនុញ្ញាតឱ្យខ្ញុំមកអានសៀវភៅ និងបង្រៀនខ្ញុំអំពីរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហម។

២) នាងខ្ញុំឈ្មោះ **គង់ សុខុមកន្និកា** ភេទស្រី អាយុ១២ឆ្នាំ រៀនថ្នាក់ទី៦ នៃសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន ក្តុលផ្សារ។ ខ្ញុំយល់ឃើញថា ការអានសៀវភៅនៅទីនេះធ្វើឱ្យខ្ញុំយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរបានច្រើន។ ខ្ញុំចូលចិត្តអានសៀវភៅ ព្រោះធ្វើឱ្យខ្ញុំយល់ដឹង និងចេះសរសេរសាច់រឿង។ នៅទីនេះ មានភាពស្ងប់ស្ងាត់ និងមានទេសភាពទាក់ទាញ។ ខ្ញុំសូមអរគុណដល់បងៗក្រុមការងារនៅផ្ទះសហគមន៍ជនជាតិស្ទៀងនៅភូមិក្តុលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានយកចិត្តទុកដាក់ចំពោះខ្ញុំនិងធ្វើការណែនាំសៀវភៅប្រវត្តិសាស្ត្រ និងពិព័រណ៍រូបថតដល់ខ្ញុំ ដោយភាពរួសរាយរាក់ទាក់ សម្តីទន់ភ្លន់ និងចិត្តល្អ។



សិស្សសាលាបឋមសិក្សា និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្តុលផ្សារ មកទស្សនារូបថត និងអានសៀវភៅនៅផ្ទះសហគមន៍ភូមិក្តុលលើ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









សិស្សសាលាបឋមសិក្សា និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ មកទស្សនារូបថត និងអានសៀវភៅ នៅផ្ទះសហគមន៍ភូមិក្តុលលើ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារកម្ពុជា ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង និងស្តាប់ការរៀបរាប់ពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម

ឈុំ រ៉ា



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចន្លោះពីថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់រទេះរុញចំនួន៣គ្រឿង និងកាសជំនួយត្រចៀកចំនួន៦គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាជនមានពិការភាពចំនួន៩ នាក់ ក្នុងនោះមានស្ត្រីចំនួន៦នាក់ កំពុងរស់នៅភូមិចន្ទីកណ្តាល ភូមិចន្ទីទី១ និងភូមិក្តុលក្រោម ក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ការផ្តល់រទេះរុញ និងកាសជំនួយត្រចៀកនេះ គឺស្របទៅតាមគោលបំណងនៃគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយធ្វើយ៉ាងណាឱ្យសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានប្រសើរឡើង ឈ្វេងយល់អំពីសុខភាពសាធារណៈ និងផ្តល់សេវាសុខភាពសាធារណៈសម្រាប់អ្នករស់រានមានជីវិតពីរបប

ខ្មែរក្រហម ជាពិសេសជនដែលមានពិការរស់នៅតាមសហគមន៍ដាច់ស្រយាល។

ក្រោយពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំងនេះ បានទទួលរទេះរុញ និង កាសជំនួយត្រចៀករួច ក៏បានបង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

១) ខ្ញុំឈ្មោះ **តូច តិ** ភេទស្រី អាយុ៨៨ឆ្នាំ កើតនៅភូមិចង្ក្រានទី១ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ តូច និងម្ដាយឈ្មោះ អ៊ូ ។ ខ្ញុំខ្វិនជើងខាងស្ដាំតាំងពីអាយុ៥ខែដោយសារការចាក់ថ្នាំ ទើបបណ្ដាលឱ្យជើងខ្ញុំស៊ិតរហូតមកទល់សព្វថ្ងៃ។ ក្នុងរបបខ្មែរក្រហម ខ្ញុំមិនដែលគិតថា ខ្លួនឯងមានជីវិតរស់នៅទេ ព្រោះខ្មែរក្រហមបង្ខំខ្ញុំឱ្យធ្វើការងារច្រើន និងហូបចុកមិនបានគ្រប់គ្រាន់។

ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ចំពោះរទេះរុញដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានផ្ដល់ឱ្យខ្ញុំដោយឥតគិតថ្លៃ ព្រោះកន្លងមកមិនដែលមានក្រុមអង្គការណាមកសួរនាំខ្ញុំអំពីសុខភាព និងប្រវត្តិឆ្លងកាត់សម័យសង្គ្រាម, របបខ្មែរក្រហម ហើយបានផ្ដល់រទេះរុញឱ្យខ្ញុំទេ។ ខ្ញុំមិនមានកូនចៅ និងសាច់ញាតិទេ គឺខ្ញុំរស់នៅម្នាក់ឯង។ រទេះរុញនេះមានប្រយោជន៍ណាស់សម្រាប់ខ្ញុំ ព្រោះអាចសម្រួលក្នុងការធ្វើដំណើររបស់ខ្ញុំ។ ជាថ្មីម្ដងទៀត ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម និងសូមជូនពរក្រុមការងារឱ្យមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។

២) ខ្ញុំឈ្មោះ **ឈាន កុច** ភេទប្រុស អាយុ៦៥ឆ្នាំ គឺជាជនជាតិស្ទៀង កើតនៅក្នុងភូមិក្ដុលក្រោម (ក្ដុលត្បូង) ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិឃុំដដែល។ ខ្ញុំស្ដាប់មិនសូវឮតាំងពីឆ្នាំ២០២០ គឺមានរយៈពេល៤ឆ្នាំហើយ ដោយសារតែជំងឺលើសឈាម។ ខ្ញុំពិតជាពិបាកក្នុងការស្ដាប់ណាស់ ពេលដែលកូនចៅនិយាយជាមួយខ្ញុំ។ ខ្ញុំស្ដាប់មិនឮហើយក៏មិនបានឆ្លើយតបទៅកូនចៅខ្ញុំវិញដែរ។ ខ្ញុំស្ដាប់មិនឮហេតុនេះធ្វើឱ្យខ្ញុំមានអាការៈតានតឹង ទាំងការពិតកូនចៅនិយាយល្អពីខ្ញុំ ប៉ុន្តែខ្ញុំយល់ខុស។ ការដែលខ្ញុំទទួលបានកាសជំនួយត្រចៀក អាចឱ្យខ្ញុំមានទំនាក់ទំនងល្អប្រចាំថ្ងៃជាមួយអ្នកនៅជុំវិញខ្លួន។ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្ដល់កាសជំនួយត្រចៀក ដល់ខ្ញុំ។

៣) ខ្ញុំឈ្មោះ **រី ស៊ីម** អាយុ៦៨ឆ្នាំ ភេទស្រី កើតនៅភូមិទួលចំបក់ ឃុំបារាយណ៍ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិចង្ក្រានទី១ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលបានទទួលរទេះរុញ ព្រោះខ្ញុំធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀតបាន។

៤) ខ្ញុំឈ្មោះ **ជា អ៊ា** ភេទស្រី អាយុ៨៤ឆ្នាំ កើតនៅក្នុងភូមិក្ដុលក្រោម ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិឃុំដដែល។ ខ្ញុំស្ដាប់មិនសូវឮតាំងពីឆ្នាំ២០២៣ ដោយសារតែជំងឺចាស់ជរា។ ការដែលខ្ញុំស្ដាប់មិនសូវឮ ធ្វើឱ្យខ្ញុំមានអារម្មណ៍ធុញថប់ ព្រោះមិនដឹងថាអ្នកនៅជុំវិញខ្លួននិយាយអ្វីខ្លះ។ កូនចៅមិនចង់និយាយជាមួយខ្ញុំទេ ព្រោះខ្ញុំស្ដាប់មិនឮ។ ពេលខ្ញុំឈឺម្ដងៗ ខ្ញុំស្ដាប់មិនឮ និងហឹងក្នុងត្រចៀក ធ្វើឱ្យខ្ញុំមិនចង់និយាយស្ដីអ្វីទាំងអស់។ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានផ្ដល់កាសជំនួយត្រចៀកដល់ខ្ញុំ។

៥) ខ្ញុំឈ្មោះ **ម៉ុញ ខ្លី** ភេទប្រុស អាយុ៨៣ឆ្នាំ កើតនៅភូមិកញ្ឆិត ឃុំ ឡុកថាញ់ ស្រុក ឡុកនិញ ខេត្តបិញភឿក។ នៅឆ្នាំ១៩៧៩ ខ្ញុំផ្លាស់មករស់នៅភូមិចង្ក្រាន ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំស្ដាប់មិនសូវបានតាំងពីឆ្នាំ២០២០ គឺមានរយៈពេល៤ឆ្នាំហើយដោយសារជំងឺចាស់ជរា។ ខ្ញុំពិតជាពិបាកក្នុងការស្ដាប់ ពេលដែលកូនចៅនិយាយជាមួយ។ ខ្ញុំស្ដាប់មិនឮនិងមិនបានឆ្លើយតបទេ។ ខ្ញុំមានអារម្មណ៍មិនល្អពេលស្ដាប់កូនចៅមិនឮ ទោះបីកូនចៅនិយាយល្អពីខ្ញុំក៏ដោយ។ កាសជំនួយត្រចៀកនេះធ្វើឱ្យខ្ញុំមានទំនាក់ទំនងល្អប្រចាំថ្ងៃជាមួយអ្នកនៅជុំវិញខ្លួនវិញ។ ខ្ញុំសូម

ថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់កាសជំនួយត្រចៀកដល់ខ្ញុំ។

៦) **ឯម យ៉េម** ភេទស្រី អាយុ៨៨ឆ្នាំ មានទីកន្លែងកំណើតនៅ ភូមិចង្កុំទី១ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន គាត់រស់នៅក្នុងឃុំដដែល។ កូនស្រីរបស់គាត់រៀបរាប់ថា៖ «ខ្ញុំពិតជាមានអារម្មណ៍រីករាយ និងរំភើបជាខ្លាំង ដែលក្រុមការងាររបស់មជ្ឈ-មណ្ឌលឯកសារកោះថ្មបានឧបត្ថម្ភកាសជំនួយត្រចៀកដល់ម្តាយរបស់ខ្ញុំ ដើម្បីឱ្យគាត់មានឱកាសស្តាប់ឮ អាចនិយាយឆ្លងឆ្លើយជាមួយកូនចៅ និងបងប្អូននៅក្នុងភូមិដូចធម្មតាវិញ។ ពេលដែលម្តាយខ្ញុំស្តាប់ឮ គឺស្រួលក្នុងការសួរនាំអំពីសុខភាពរបស់គាត់ពេលគាត់ឈឺ ឬមិនស្រួលខ្លួនម្តងៗ។ ខ្ញុំពិតជាពិបាកក្នុងការសួរនាំ។ ភាគច្រើនទៅ ពេលមិនស្រួលខ្លួនគឺគាត់មិននិយាយរកកូនចៅទេ ដល់អញ្ចឹងខ្ញុំមិនដឹងថាគាត់ឈឺអ្វីទេ។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកោះថ្មដែលបានជួយឱ្យម្តាយរបស់ខ្ញុំស្តាប់ឮម្តងទៀត»។








ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែករំលែកទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចែករទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព

ផេង ពង្សរ៉ាស៊ី



*ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចែករទេះរុញ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកទ្រាំង និងស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ចន្លោះពីថ្ងៃទី១៧ និងទី១៨ ខែកញ្ញា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចែករទេះរុញចំនួន៥គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅស្រុកទ្រាំង និងស្រុកត្រាំកក់ ខេត្តតាកែវ។ ការចែករទេះរុញនេះក៏មានការចូលរួមពីអាជ្ញាធរមូលដ្ឋានឃុំរនាម ក្នុងស្រុកទ្រាំង និងឃុំលាយបូរ និងឃុំតាភេម ស្រុកត្រាំកក់ ព្រមទាំងប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំខាងលើ។ ការចែករទេះរុញនេះ គឺស្របទៅតាមគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ តែងតែរៀបចំកម្មវិធីជួបជុំជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដើម្បីសួរនាំពីស្ថានភាពសុខភាព និងពិនិត្យសុខភាពជាបឋមជូនគាត់។ ក្នុងឱកាសនោះ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក៏បានចែករទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពដើម្បីជួយសម្រួលដល់ការធ្វើដំណើរប្រចាំថ្ងៃ ធ្វើឱ្យធូរស្បើយអារម្មណ៍ និងជួយសម្រាលបន្ទុកក្នុងគ្រួសារ។ នេះ

គឺជាលើកទីបីហើយ ដែលមជ្ឈមណ្ឌលឯកសារខេត្តតាកែវផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តតាកែវ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានទទួលបានរទេះរុញក៏បានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖



១) ខ្ញុំឈ្មោះ **ប៊ុន សាមិត្ត** ភេទប្រុស អាយុ៧០ឆ្នាំ រស់នៅភូមិថ្មី ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំមានជំងឺលើសឈាម និងបញ្ហាខួរក្បាល។ ខ្ញុំធ្លាក់ខ្លួនឈឺតាំងពីខ្ញុំសន្លប់នៅពេលកំពុងធ្វើការងារជាងផ្ទះឱ្យអ្នកភូមិ។ ក្រោយពីសន្លប់ ដៃជើងរបស់ខ្ញុំកម្រើកលែងបាន។ ខ្ញុំឈឺដើរលែងរួចប្រហែលជា ៣ទៅ៤ឆ្នាំមកហើយ។ ថ្ងៃនេះ ខ្ញុំទទួលបានរទេះរុញ ធ្វើឲ្យខ្ញុំត្រេកអរ និងសប្បាយរីករាយខ្លាំងណាស់។ ខ្ញុំសូមជូនពរដល់មជ្ឈមណ្ឌលឯកសារខេត្តតាកែវឱ្យប្រកបតែសេចក្តីសុខចម្រើន។



២) ខ្ញុំឈ្មោះ **នួន ម៉ន** ភេទប្រុស អាយុ៨៦ឆ្នាំ រស់នៅភូមិថ្មី ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ។ ខ្ញុំសប្បាយខ្លាំងណាស់ ពេលដែលខ្ញុំទទួលបានរទេះរុញនេះ។ រទេះរុញនេះនឹងសម្រួលដល់ការធ្វើដំណើររបស់ខ្ញុំ ដូចជា ជិះទៅវត្ត និងជិះជុំវិញផ្ទះ។



៣) ខ្ញុំឈ្មោះ **ចាប ជុំ** ភេទប្រុស អាយុ៧៨ឆ្នាំ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិថ្មី ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ។ ខ្ញុំឈឺដើរមិនរួចជាងមួយឆ្នាំកន្លងមកហើយ។ សព្វថ្ងៃខ្ញុំរស់នៅតែពីរនាក់ប្រពន្ធ សូម្បីស្លៀកពាក់ខោអាវ ក៏ខ្ញុំមិនអាចស្លៀកពាក់ដោយខ្លួនឯងបានដែរ គឺទាល់តែប្រពន្ធរបស់ខ្ញុំជួយ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់នៅពេលដែលខ្ញុំទទួលបានរទេះរុញនេះ ព្រោះអាចសម្រួលដល់ការធ្វើដំណើររបស់ខ្ញុំ ជាពិសេសខ្ញុំអាចជិះទៅវត្ត ដោយប្រពន្ធរបស់ខ្ញុំជួយរុញ។ ជាចុងក្រោយ ខ្ញុំអរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រួមទាំងក្រុមការងារដែលបានផ្តល់រទេះរុញដល់ខ្ញុំ។



៤) ខ្ញុំឈ្មោះ **ហ៊ុន អៀច** ភេទស្រី អាយុ៧៩ឆ្នាំ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិត្រពាំងកក់ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដែលបានចែករទេះរុញនេះដល់ខ្ញុំ។ ខ្ញុំសូមជូនពរដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវទាំងអស់មានសេចក្តីសុខចម្រើន។



៥) ខ្ញុំឈ្មោះ **ជុំ អិន** ភេទប្រុស អាយុ៦៨ឆ្នាំ រស់នៅភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ជុំ សុខ និងម្តាយឈ្មោះ ញិញ ម៉ៅ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ក្នុងនោះមានស្រី៣នាក់។ រយៈពេល១០ឆ្នាំមកហើយ ដែលខ្ញុំមិនអាចដើរទៅណាមកណាបាន ដោយសារខ្ញុំមានជំងឺលើសឈាម។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ពេលទទួលបានរទេះរុញនេះ ព្រោះខ្ញុំមិនធ្លាប់ទទួលបានរទេះរុញនេះពីមុនទេ។ ខ្ញុំអាចជិះរទេះរុញនេះនៅជិតៗផ្ទះ។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដែលបានផ្តល់រទេះរុញនេះដល់ខ្ញុំ។

# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចែករទេះ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## ដែលមានពិការភាព នៅឃុំព្រៃកណ្ដៀង និងស្ដាប់ការរៀបរាប់អំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ភា រស្មី និង ថុន ស្រីពេជ្រ



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចែករទេះរុញ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បាននាំយករទេះរុញចំនួន៦គ្រឿង ទៅចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពចំនួន៦នាក់ រស់នៅឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ការប្រគល់រទេះរុញនេះធ្វើឡើងនៅសាលាឃុំព្រៃកណ្ដៀង។

លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានប្រាប់អំពីគោលបំណងនៃការផ្ដល់រទេះរុញជូនអ្នកដែលមានពិការភាពជាពិសេសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលត្រូវបានអ្នកស្ម័គ្រចិត្តកម្ពុជាសម្ភាសន៍កន្លងមក។ លោក ដេង ពង្សរ៉ាស៊ី បន្តថា ការចែកជូនរទេះរុញនេះគឺដើម្បីជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព ដូចជាការធ្វើដំណើរទៅណាមកណាដោយខ្លួនឯង និងអាចជួយសម្រាលបន្ទុកក្នុងគ្រួសារ។

បន្ទាប់មក លោកមេឃុំព្រែកណ្ដៀងឈ្មោះ ឈិន សាខន បានថ្លែងថា «ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំងដែលមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានគិតគូរ និងយកចិត្តទុកដាក់ផ្ដល់រទេះរុញចំនួន៦គ្រឿងជូនដល់ប្រជាពលរដ្ឋដែលមានពិការភាពរស់នៅក្នុងឃុំព្រែកណ្ដៀងនេះ»។ លោកមេឃុំ ឈិន សាខន បានបន្តថា «នៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ សម្រាប់ប្រជាពលរដ្ឋដែលមានពិការភាពរស់នៅក្នុងឃុំព្រែកណ្ដៀងនេះ។ ខ្ញុំសូមស្នើមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ផ្ដល់រទេះរុញថែមទៀត ដល់ប្រជាពលរដ្ឋដែលមានពិការភាពនៅក្នុងឃុំព្រែកណ្ដៀង»។ ចុងបញ្ចប់ លោកមេឃុំ ឈិន សាខន បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងជូនពរដល់ក្រុមការងារទាំងអស់ដែលបាននាំយករទេះរុញមកចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំង៦នាក់។

ក្រោយចប់កម្មវិធី អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលទទួលបានរទេះរុញ បានបង្ហាញពីចំណាប់អារម្មណ៍ និងចែករំលែករឿងរ៉ាវដែលបានឆ្លងកាត់របបខ្មែរក្រហមដូចខាងក្រោម៖



## ១) ប្រាជ្ញ យ៉ន ៖ បងប្រុសខ្ញុំគឺជាប្រធានសហករណ៍ឃុំ ត្រូវបានយកទៅសម្លាប់

ខ្ញុំឈ្មោះ ប្រាជ្ញ យ៉ន ភេទប្រុស អាយុ៧៣ឆ្នាំ រស់នៅភូមិព្រែកណ្ដៀង ឃុំព្រែកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ខ្ញុំមានជំងឺគ្រុនស្វិតដៃជើងតាំងពីខ្ញុំមានអាយុ៨ខែ។ រហូតមកដល់សព្វថ្ងៃនេះ ជើងខាងស្ដាំរបស់ខ្ញុំស្វិតម្ខាង និងមិនអាចកម្រើកបានទេចាប់ពីចង្កេះរហូតមកដល់ចុងជើង។ ខ្ញុំមានការលំបាកក្នុងការធ្វើដំណើរ។ ប៉ុន្តែនៅពេលនេះខ្ញុំទទួលបានរទេះរុញដើម្បីជិះនៅជិតៗផ្ទះដោយខ្លួនឯងដោយមិនចាំបាច់ពឹងពាក់កូនចៅ។ រទេះរុញនេះពិតជាមានសារសំខាន់ណាស់សម្រាប់ខ្ញុំ និងកូនរបស់ខ្ញុំ។ កូនប្រុសខ្ញុំឈ្មោះ ដាត មានអាយុ៤៦ឆ្នាំ បានជួបគ្រោះថ្នាក់ចរាចរណ៍ដោយសារដេញគោឆ្លងថ្នល់ ហើយត្រូវរថយន្តបុកបណ្ដាលឱ្យបាក់ឆ្អឹងចង្កេះ ហើយពិការជើងទាំងសងខាងកម្រើកមិនបានអស់រយៈពេល៦ឆ្នាំមកហើយ។ ខ្ញុំមានឪពុកឈ្មោះ ញឹក ប្រាជ្ញ និងម្ដាយឈ្មោះ ជា អៀត។ សព្វថ្ងៃឪពុកម្ដាយខ្ញុំស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនចំនួន៧នាក់ គឺស្រី២នាក់ និងប្រុស៥នាក់។ នៅក្នុងរបបខ្មែរក្រហម បងប្រុសរបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ចំណែកប្អូនស្រីរបស់ខ្ញុំម្នាក់ទៀតស្លាប់ដោយសារជំងឺ។

ខ្ញុំរៀនសូត្រត្រឹមថ្នាក់ទី១០ដែលជាកម្រិតអនុវិទ្យាល័យ-ដ្ឋាន។ នៅឆ្នាំ១៩៦៧ ខ្ញុំបួសជាព្រះសង្ឃនៅវត្តព្រែកណ្ដៀងដើម្បីរៀនសូត្របន្ត។ ខ្ញុំបួសរៀនរយៈពេល៩វស្សាក៏ត្រូវខ្មែរក្រហមបង្ខំឱ្យសឹក។ នៅអំឡុងពេលទម្លាក់គ្រាប់បែកប្រជាជនស្ទើរតែទាំងអស់បានចាកចេញពីភូមិព្រែកណ្ដៀង។ ខ្ញុំនិងព្រះសង្ឃផ្សេងទៀតបានភៀសខ្លួនទៅគង់នៅវត្តទឹកថ្លា ហើយត្រូវបានជម្លៀសនៅទីនោះតែម្ដង គឺប្រហែលជាកន្លះខែក្រោយពេលទីក្រុងភ្នំពេញត្រូវបានរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ កាលនោះខ្ញុំមិនចង់សឹកឡើយ ព្រោះកាលណាខ្ញុំសឹក ខ្ញុំលែងបានរៀនសូត្របន្តទៀតហើយ។ ទោះបីជាខ្ញុំស្ដាយយ៉ាងណាក៏មិនអាចបដិសេធបានដែរ ព្រោះទូទាំងប្រទេសព្រះសង្ឃត្រូវបានជម្លៀសអស់ហើយ។ បងរបស់ខ្ញុំឈ្មោះ ប្រាជ្ញ អ៊ួន គឺជាប្រធានសហករណ៍ឃុំព្រែកណ្ដៀង នៅពេលនោះបានកាត់ខោអាវពណ៌ខ្មៅឱ្យខ្ញុំ និងឱ្យខ្ញុំវិលត្រឡប់មកភូមិព្រែកណ្ដៀងវិញ។ បន្ទាប់មកបង អ៊ួន ក៏បានចាត់តាំងខ្ញុំឱ្យធ្វើការនៅក្នុងមន្ទីរវប្បធម៌ដែលមានការបង្រៀនសិស្ស និងមើលការខុសត្រូវគ្រូបង្រៀនចំនួន៥នាក់ទៀត។ ខ្ញុំបានធ្វើការនៅមន្ទីរវប្បធម៌តាំងពីរបបខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសរហូតដល់របបខ្មែរក្រហមដួលរលំ។ ខ្ញុំចាប់ផ្ដើមចូល

ធ្វើការងារនៅឆ្នាំ១៩៧៥ ដោយរៀនរាល់ថ្ងៃ ខ្ញុំក្រោយម៉ោង៤ទៀតគឺដើម្បីដឹកនាំកុមារទូលដីដាក់ស្រែ។ បន្ទាប់មក ខ្ញុំបង្រៀនសិស្សរយៈពេល១ម៉ោងកន្លះទៅ២ម៉ោង ទើបដឹកនាំសិស្សទៅជម្រះស្មៅ, ទៅដាំពោត, លាយដីដំបូកធ្វើជី, លើកប្រព័ន្ធភ្លឺស្រែ និងទៅកាប់ដើមទន្រ្ទានខែត្រនៅឃុំព្រៃកណ្ដៀង។

នៅឆ្នាំ១៩៧៦ សិស្សគ្រប់ថ្នាក់ដែលមានចំនួនប្រមាណ២០០នាក់ត្រូវឱ្យកាប់ព្រៃ និងតម្រង់ប្រព័ន្ធផ្លូវនៅក្នុងភូមិ។ មូលហេតុដែលប្រមូលសិស្សមកកាប់ព្រៃដូច្នេះដោយសារតែនៅក្នុងភូមិព្រៃកណ្ដៀងពីមុនគឺសម្បូរទៅដោយព្រៃ និងដើមឈើដុះជាច្រើន។

នៅឆ្នាំ១៩៧៧ ខ្ញុំបានដឹកនាំកុមារ ទៅជាន់រហាត់ទឹកស្រែប្រាំង នៅខាងលិចភូមិព្រៃកណ្ដៀង។ រហាត់មួយគឺមានកុមារជាន់ចំនួន២នាក់ ប៉ុន្តែការជាន់រហាត់ទឹកនេះគឺនឿយហត់ជាងការកាប់ព្រៃធ្វើផ្លូវទៅទៀត ព្រោះកុមារត្រូវជាន់ទឹកទាំងយប់ទាំងថ្ងៃ ធ្វើយ៉ាងណានៅក្នុងស្រែ១ហិកតា មានទឹកគ្រប់គ្រាន់។ កាលណាមានអ្នកចុះមកត្រួតពិនិត្យ ហើយឃើញស្រែមានទឹកគ្រប់គ្រាន់ នោះយើងនឹងមិនត្រូវបានទិតៀនទេ។ ចំណែកអាហារ ហូបចុកប្រចាំថ្ងៃ ពេលខ្លះបានហូបបបរ និងពេលខ្លះទៀតបានហូបបាយ។ នៅរដូវប្រាំង ឆ្នាំ១៩៧៧ អ្នកដែលធ្វើការនៅសាលាស្រុក សាលាសង្កាត់ ឬមានតួនាទីនៅផ្នែកវប្បធម៌ និងកសិកម្មត្រូវបានកោះហៅឱ្យទៅរៀនសូត្រនៅស្រុកបាភ្នំ។ កាលនោះ ឃុំព្រៃកណ្ដៀងបានបញ្ជូនខ្ញុំ និងសមាជិកចំនួន២នាក់ទៀតឱ្យទៅរៀនសូត្រ។ ពេលនោះខ្ញុំបានជួបជាមួយ សោ ភឹម លេខាភូមិភាគបូព៌ាជាលើកដំបូង។ សោ ភឹម ជិះឡានស៊ីប អាខៀវ។ សោ ភឹម មកចូលរួមលើកនេះក្នុងនាមជាគ្រូឧទ្ទេសបង្រៀនដល់កម្មាភិបាលដែលបានចូលរួមអំពីនយោបាយ និងត្រូវលើកស្ទួយវិស័យកសិកម្ម និងសហករណ៍ឱ្យបានថ្កុំថ្កើងរុងរឿង។ ការរៀននេះ គឺរៀនក្នុងរយៈពេល១សប្ដាហ៍។ រៀនរាល់ថ្ងៃ បន្ទាប់ពីរៀនរួច សហករណ៍បាននាំយើងជិះឡានដើរមើលស្រុកភូមិ ដំណាំស្រែចម្ការ ប្រព័ន្ធប្រឡាយដើម្បីឱ្យយើងយកមកអនុវត្តនៅក្នុងស្រុកភូមិរបស់ខ្លួនវិញ។ ទោះបីយ៉ាងណា ខ្ញុំនៅមានអារម្មណ៍ភ័យខ្លួនជារៀងរាល់ថ្ងៃ។ នៅពេលយប់ ខ្ញុំតែងលួចជជែកគ្នាស្ងាត់ៗអំពីអ្នកដែលខ្ញុំធ្លាប់ស្គាល់ពីមុនមក ហើយត្រូវបានអង្គការចាប់យកទៅសម្លាប់ម្ដងម្នាក់ៗ។ ខ្ញុំគិតក្នុងចិត្ត និងបានជជែកគ្នាថា មិនដឹងខ្មែរក្រហមយកយើងទៅសម្លាប់នៅយប់នេះ ឬយប់ណានោះទេ ព្រោះឱ្យតែពាក្យថារៀនសូត្រគឺរស់ពុំបានយូរឡើយ។ សំណាងល្អ យើងទាំងអស់គ្នាបានវិលត្រឡប់មកមូលដ្ឋានរបស់ខ្លួនវិញ។ រយៈពេលប្រមាណជា៥ខែក្រោយ សោ ភឹម លេខាភូមិភាគបូព៌ាត្រូវបានខ្មែរក្រហមចោទថាក្បត់។ អ្នកដែលធ្លាប់បានទៅរៀនជាមួយខ្ញុំមួយចំនួន ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ នៅសល់តែខ្ញុំម្នាក់ប៉ុណ្ណោះ។ បងប្រុសរបស់ខ្ញុំដែលជាប្រធានសហករណ៍ ត្រូវបានកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីចាប់យកទៅសម្លាប់។ កាលនោះខ្ញុំភ័យខ្លាំងណាស់ ព្រោះខ្លាចប្រធានសហករណ៍ថ្មីរាយការណ៍ឈ្មោះខ្ញុំឡើងទៅកាន់ថ្នាក់លើដូចអ្នកឯទៀតដែរ ប៉ុន្តែជាសំណាងល្អប្រធានសហករណ៍ថ្មីមិនបានផ្ដល់ឈ្មោះខ្ញុំទៅថ្នាក់លើឡើយ។ បន្ទាប់ពីកងទ័ពមកពីភូមិភាគនិរតីចូលមកគ្រប់គ្រងនៅខាងភូមិភាគបូព៌ា ការសិក្សារបស់សិស្សក៏មិនបានជាប់លាប់ដែរ រហូតដល់របបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ក្រោយមក អ្នកភូមិបានមកហៅខ្ញុំឱ្យចូលធ្វើជាគ្រូបង្រៀន ប៉ុន្តែខ្ញុំខ្លាចដូចនៅក្នុងសម័យខ្មែរក្រហម ដោយខ្មែរក្រហមប្រើឱ្យធ្វើការងារច្រើន ហើយរៀបចំផែនការយកទៅសម្លាប់ទៀត។ ខ្ញុំមានសៀវភៅឯកសារនៅក្នុងរបបខ្មែរក្រហមច្រើនណាស់ ប៉ុន្តែខ្ញុំបានដុតចោលអស់ហើយ ព្រោះខ្ញុំខ្លាចទៅថ្ងៃខាងមុខឯកសារទាំងអស់នេះនាំបញ្ហាដល់ខ្ញុំ។ រហូតមកដល់សព្វថ្ងៃ ខ្ញុំមានការសោកស្ដាយដែលពេលនោះខ្ញុំមិនបានចូលធ្វើជាគ្រូបង្រៀន។

ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារខេត្ត

ព្រៃវែង ដែលបានផ្តល់ទេះរុញមកឱ្យខ្ញុំ។ ខ្ញុំសូមជូនពរដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងឱ្យមានសេចក្តីសុខ អាយុវែង និងរីកចម្រើនតទៅទៀត។



## ២) ជិន ឆនៈ ខ្មែរក្រហមមកចាប់ប្តីខ្ញុំ ដោយប្រាប់ថាជាសម្ពាធខ្មាំង

ខ្ញុំឈ្មោះ ជិន ឆន ភេទស្រី មានអាយុ៧៦ឆ្នាំ រស់នៅភូមិស្តៅ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ជិន និង ម្តាយឈ្មោះ សន។ ខ្ញុំមានប្តីឈ្មោះ អ៊ុំ អឿន។ សព្វថ្ងៃខ្ញុំមានបញ្ហាពុកឆ្អឹងខ្នង ឈឺចង្កេះ និងកប់សរសៃពិបាកដើរ។ ជើងរបស់ខ្ញុំស្ពឹក និងទន់ស្មើរទាំងអស់។ ខ្ញុំបានទៅមន្ទីរពេទ្យក្រុងព្រៃវែង ដើម្បីឱ្យពេទ្យព្យាបាល។ គ្រូពេទ្យបានឱ្យថ្នាំមកខ្ញុំលេប និងឱ្យខ្សែរឹតចង្កេះមកខ្ញុំ។ ខ្ញុំបានធូរស្រាលដែរ ប៉ុន្តែមិនបានជាទាំងស្រុងទេ។ រៀងរាល់ថ្ងៃ ខ្ញុំមិនអាចដើរទៅងូតទឹកដោយខ្លួនឯងបានទេ ទាល់តែមានអ្នកមកជួយទប់។ ខ្ញុំមានជំងឺនេះរយៈពេល៤ទៅ៥ឆ្នាំហើយ។ ខ្ញុំសម្រាន្តមិនសូវលក់។ ខ្ញុំពិបាកចិត្តខ្លាំងណាស់។ ខ្ញុំធ្លាប់តែដើរធ្វើបុណ្យ ប៉ុន្តែនៅពេលនេះខ្ញុំមិនអាចទៅណាមកណាបាន។ មានពេលខ្លះ ខ្ញុំដេកយំ ហូរទឹកភ្នែកចង់គិតខ្លីសម្លាប់ខ្លួន។ ក្រោយមក ទើបខ្ញុំខំកាត់ចិត្តដោយខ្លួនឯង ដោយព្យាយាមស្វែងយល់ធម៌ក្នុងព្រះពុទ្ធសាសនា។ ឥឡូវនេះផ្លូវចិត្តរបស់ខ្ញុំបានល្អប្រសើរហើយ។

កាលពីតូចខ្ញុំរស់នៅក្រុងព្រៃវែង។ ខ្ញុំបានរៀននៅសាលាក្រុងព្រៃវែងត្រឹមថ្នាក់ទី៧ ក៏ឈប់រៀន។ នៅឆ្នាំ១៩៧០ ខ្ញុំរៀបការជាមួយប្តីខ្ញុំ និងបានមករស់នៅជាមួយប្តីនៅភូមិស្តៅ។ ប្តីរបស់ខ្ញុំគឺជាទាហាន ប៉ុន្តែខ្ញុំមិនដឹងថាគាត់ជាទាហានខាងណាទេ។

នៅឆ្នាំ១៩៧៣ កំឡុងពេលមានសង្គ្រាម និងការទម្លាក់គ្រាប់បែក ខ្ញុំនិងប្តីបានបីកូនរត់ចូលទៅក្នុងលេណដ្ឋាន។ កាលនោះខ្ញុំគ្រុនក្តៅ។ ប្តីខ្ញុំកំពុងតែបីកូន និងបំពេកូននៅក្នុងលេណដ្ឋានស្រាប់តែមានមនុស្ស២ទៅ៣នាក់ មកចាប់ប្តីរបស់ខ្ញុំចេញទៅ ដោយប្រាប់ថា មេបញ្ជាការបញ្ជាមកឱ្យជាសសម្ពាធខ្មាំង។ ពេលនោះខ្ញុំគ្រុនក្តៅផង ខ្ញុំយំជោកខ្លួន។ កម្មាភិបាលខ្មែរក្រហមបានស្តីឱ្យខ្ញុំ និងប្រាប់ខ្ញុំថា «កុំឱ្យខ្ញុំស្តាយស្រណោះពួកខ្មាំង នាងឯងនៅអាយុប៉ុណ្ណឹងអាចរកប្តីបានទៀត»។ ប្តីខ្ញុំបានបែកចេញទៅចោលប្រពន្ធ និងកូនទើបតែមានអាយុ១ខែ តើឱ្យនរណាធ្វើចិត្តបានយ៉ាងឆាប់រហ័ស? ខ្ញុំកាន់តែពិបាកចិត្ត និងនឹកប្តីកាន់តែខ្លាំងឡើង នៅពេលដែលកូនរបស់ខ្ញុំយំ ហើយខ្ញុំក៏យំតាមកូន។ ជីវិតខ្ញុំលំបាកណាស់ ត្រូវមើលថែម្តាយចាស់ និងថែកូនតែម្នាក់ឯងដោយមិនមានប្តីនៅក្បែរ។ ដៃម្ខាងរបស់ខ្ញុំបីកូន ដៃម្ខាងវេចអីវ៉ាន់ ដើម្បីរត់គេចខ្លួនពីការទម្លាក់គ្រាប់បែក និងទៅរស់នៅឃុំធាយ។

នៅឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំបានវិលត្រឡប់មកស្រុកកំណើតវិញ។ នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យចូលក្នុងក្រុមយុវជនកម្លាំងស្រួច នៅក្នុងភូមិស្តៅ ដែលមានសមាជិកចំនួន២០នាក់ ដែលមាន តា ហ៊ុន គឺជាប្រធានក្រុម។ កាលនោះ ខ្ញុំធ្វើការធ្ងន់ៗសព្វគ្រប់បែបយ៉ាងទៅតាមការបញ្ជារបស់ប្រធានកង ដូចជាភ្ជួរស្រែ ដែលភាគច្រើនការងារនេះបុរសៗគឺជាអ្នកធ្វើ ប៉ុន្តែខ្ញុំក៏អាចភ្ជួរបានដែរ។ ក្រៅពីការងារភ្ជួរ ខ្ញុំទៅដកស្ទូង លើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ ដែលសុទ្ធសឹងជាការងារធ្ងន់ៗ។ ឯរបបអាហារហូបចុក ខ្ញុំមិនបានហូបគ្រប់គ្រាន់ឡើយ ដោយសារតែខ្ញុំត្រូវបែងចែកចំណែកទុកឱ្យកូនខ្លះ។ ខ្ញុំតែងតែលួចអាហារមកហូបជារៀងរាល់ថ្ងៃ។ ដូចជា ពេលទៅដាំដំឡូង ខ្ញុំលួចដកដំឡូង ពេលទៅដាំពោត ខ្ញុំលួចកាច់ពោត ពេលទៅច្រូតស្រូវខ្ញុំលួចបូតស្រូវមកបុកខ្លួនឯង និងពេលទៅដាំអំពៅ ខ្ញុំក៏លួចកាច់អំពៅមកហូបដើម្បីរស់។ ជួនកាល ពេលខ្ញុំឃើញផ្លែខ្វិតទុំ ខ្ញុំក៏លួចផ្លែខ្វិតយក

មកដុតហូបទៀត។ សំណាងល្អ ដែលខ្មែរក្រហមមិនបានឃើញខ្ញុំលួច។ ចំណែកអ្នកផ្សេងទៀតក៏បានលួចរបស់ហូបដូចខ្ញុំដែរ ប៉ុន្តែត្រូវកងឈ្លបចាប់បាន ហើយយកទៅរៀនសូត្រ និងមិនដែលឃើញត្រឡប់មកកងវិញទេ។ ឃើញដូច្នេះ ខ្ញុំក៏ផ្អាកលួច។ ដោយសេចក្តីស្រេកឃ្លាន និងចង់ឱ្យកូននិងក្រុមគ្រួសារបានហូបគ្រប់គ្រាន់ខ្ញុំដាច់ចិត្តលួចបន្តទៀត។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវអង្គការស្នើឱ្យទៅដកសំណាបនៅភូមិព្រហ៊ូត និងភូមិព្រលឹងមាស ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ នៅទីនោះស្រែនីមួយៗសម្បូរទៅដោយសត្វឈ្លើងច្រើនណាស់។ សត្វឈ្លើងជាច្រើនបានមកទាមជើងរបស់ខ្ញុំ។ ខ្ញុំបានស្រែក និងលោតដោយសារតែឃើញសត្វឈ្លើងហែលមកទាមជើងខ្ញុំច្រើនពេក ។ ប្រពន្ធរបស់ប្រធានក្រុមក៏បានស្តីបន្ទោសខ្ញុំ។ ខ្ញុំបានយំសុំដូរការងារ ប៉ុន្តែប្រពន្ធប្រធានក្រុមមិនយល់ព្រមឡើយ។ កំឡុងពេលខ្ញុំចាកចេញឆ្ងាយពីកូនមកដកសំណាបនៅព្រហ៊ូត មានអ្នកភូមិផ្តល់ដំណឹងមកខ្ញុំថា កូនរបស់ខ្ញុំបានគ្រុនក្តៅ និងកើតជំងឺកញ្ជ្រឹលពេញខ្លួន។ ខ្ញុំបានសុំប្រធានក្រុមទៅមើលកូន ប៉ុន្តែប្រធានក្រុមមិនអនុញ្ញាតឱ្យខ្ញុំទៅមើលកូនឡើយ ទោះបីជាខ្ញុំយំអង្វរ ហើយព្យាយាមសុំអនុញ្ញាតច្រើនដងក៏ដោយ។ ប្រធានក្រុមបានតបមកខ្ញុំវិញថា ឱ្យខ្ញុំគិតអំពីផលប្រយោជន៍រួម និងមិនគួរបោលការងារដោយសារប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ ខ្ញុំបានរង់ចាំអស់រយៈពេលប្រហែលជិត១ខែ ទើបការងារដកសំណាបត្រូវបានរំសាយ ហើយខ្ញុំអាចវិលត្រឡប់មកផ្ទះវិញ និងបានមកមើលថែកូន។ ពេលមកដល់ផ្ទះ កូនរបស់ខ្ញុំបានស្រែកហៅខ្ញុំ ធ្វើឱ្យខ្ញុំអាណិតកូនរហូតស្រក់ទឹកភ្នែក។ ជំងឺកញ្ជ្រឹលរបស់កូនខ្ញុំនៅពេលនោះ នៅមិនទាន់ជាសះស្បើយទេ ព្រោះពុំមានថ្នាំដើម្បីព្យាបាល។

នៅដើមខែមករា ឆ្នាំ១៩៧៩ ខណៈពេលដែលខ្ញុំកំពុងដាំដំឡូង កងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីមកប្រាប់ប្រជាជនឱ្យភៀសខ្លួនចេញពីភូមិ ប៉ុន្តែនៅពេលនោះខ្ញុំពុំបានចេញទៅណាឡើយ។ ខ្ញុំក៏មិនខ្លាចទាហានវៀតណាមដែរ ហើយបើខ្ញុំត្រូវស្លាប់គឺខ្ញុំសុខចិត្តស្លាប់នៅក្នុងភូមិរបស់ខ្ញុំ។ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំចូលធ្វើការងារជានារីភូមិស្តៅរហូតដល់ឆ្នាំ១៩៨៨ ទើបខ្ញុំឈប់ពីការងារ ហើយត្រឡប់មកធ្វើស្រែចម្ការវិញ។

ខ្ញុំពិតជារីករាយ និងអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលគិតគូរអំពីសុខទុក្ខខ្ញុំ។ រទេះរុញនេះធ្វើឱ្យខ្ញុំមានអារម្មណ៍កក់ក្តៅជាងមុន ព្រោះខ្ញុំអាចធ្វើដំណើរទៅណាមកណាបានស្រួល។ ខ្ញុំនឹងជិះរទេះនេះជារៀងរាល់ថ្ងៃ ដើម្បីស្រូបយកខ្យល់អាកាសជុំវិញផ្ទះនៅពេលព្រឹក និងពេលល្ងាច។



### ៣) នួន រុន ៖ កងជីកជញ្ជូន

ខ្ញុំឈ្មោះ នួន រុន ភេទប្រុស អាយុ៨២ឆ្នាំ រស់នៅភូមិចាន់ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ នួន និងម្តាយឈ្មោះ ស៊ុម។ ខ្ញុំមានបងប្អូនចំនួន៥នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ឡាត ប៉ុន្តែគាត់បានស្លាប់បោលខ្ញុំប្រហែលជាជិត៤០ឆ្នាំមកហើយ។ សព្វថ្ងៃខ្ញុំមានជំងឺលើសឈាម។ ខ្ញុំធ្លាក់ខ្លួនពិការ និងស្លាប់មួយចំហៀងខ្លួនរយៈពេល៣ខែមកហើយ។ ខ្ញុំទើបតែអាចនិយាយបានតិចៗនៅក្នុងខែនេះ ប៉ុន្តែដៃនិងជើងខាងឆ្វេងរបស់ខ្ញុំមិនអាចកម្រើកបានទេ។ ពេលខ្ញុំឈឺដំបូង ខ្ញុំងើបពីកន្ទេលមិនរួចទេ។ នៅពេលនេះ ខ្ញុំបានធូរស្រាលជាងមុនបន្តិចហើយ ព្រោះខ្ញុំអាចអង្គុយបាន ប៉ុន្តែខ្ញុំមិនអាចអង្គុយបានយូរឡើយ។ ចាប់តាំងពីខ្ញុំធ្លាក់ខ្លួនពិការមក ខ្ញុំមានអារម្មណ៍ខ្មាស់អ្នកស្រុកអ្នកភូមិជាខ្លាំង។

កាលពីតូច ខ្ញុំចូលសិក្សារៀនសូត្រនៅសាលាបឋមសិក្សាវត្តពោធិ៍លាស់ ក្នុងភូមិចាន់ ត្រឹមថ្នាក់

ទី៥។ នៅឆ្នាំ១៩៧០ ខ្ញុំចូលធ្វើការនៅក្នុងកងដឹកជញ្ជូន។ ខ្ញុំគឺជាអ្នកដឹកសាកសពទាហានវៀតកុង ប៉ុវៀតណាមខាងជើង ដែលបានស្លាប់ដោយសារសង្គ្រាមចេញពីភូមិស្នេហ៍ឆ្ពោះទៅកាន់មាត់ទន្លេរួចមានមនុស្សដឹកសាកសពបន្តតាមកាណូតទៅកាន់កន្លែងផ្សេងទៀត។ នៅឆ្នាំ១៩៧៥ ខ្ញុំនៅបន្តធ្វើការនៅក្នុងកងដឹកជញ្ជូនដដែល រហូតដល់ខ្មែរក្រហមដួលរលំនៅដើមខែមករា ឆ្នាំ១៩៧៩។ ជារៀងរាល់ថ្ងៃ ការដឹកជញ្ជូនគឺមិនទៀងទាត់ទេ។ ជួនកាលខ្មែរក្រហមចាត់តាំងឱ្យខ្ញុំទៅដឹកស្បៀងពីបន្ទាយដេក យកមកទុកនៅក្នុងឃ្លាំងភូមិស្ពៅ។ ជួនកាលដឹកបាយសម្លយកទៅឱ្យអ្នកស្ទូងនៅវាលស្រែ និងជួនកាលដឹកក្រណាត់ ដឹកអង្ករ និងថ្នាំពេទ្យយកទៅដាក់នៅឃ្លាំងភូមិពន្លៃ។ ការងារដឹកជញ្ជូននេះគឺពុំមានការលំបាកខ្លាំងសម្រាប់ខ្ញុំទេដោយសារតែខ្ញុំទទួលបានរបបអាហារគ្រប់គ្រាន់។

នៅឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពភូមិភាគនិរតីចូលមកបានសម្លាប់កម្មាភិបាល និងកងទ័ពភូមិភាគបូព៌ាអស់ជាច្រើននាក់។ នៅពេលនោះ ខ្ញុំបានដឹកសាកសពចេញពីភូមិចាន់ ទៅខាងលិចភូមិពន្លៃ។ ខ្ញុំបានដឹកសាកសពអ្នកស្លាប់ជារៀងរាល់ថ្ងៃ ក្នុងរយៈពេលប្រហែលជាកន្លះខែ។ ចំនួនសាកសពសរុបដែលខ្ញុំ ដឹកគឺចន្លោះពី២០ ទៅ៣០នាក់។ ខ្ញុំមានអារម្មណ៍រន្ធត់ខ្លះដែរពេលដឹកសាកសព ប៉ុន្តែខ្ញុំមិនសូវភ័យខ្លាំងពេកនោះទេ។ កាលនោះ ខ្ញុំតែងតែយកអង្ករ ផ្លែឈើ អំពៅ យកទៅជូនកម្មាភិបាលដែលមានតួនាទីធំ ដូច្នេះខ្ញុំមិនសូវបារម្ភទេ។ កម្មាភិបាលទាំងនោះចូលចិត្តខ្ញុំ និងលើកសរសើរខ្ញុំដែរ។ នៅខាងមុខផ្ទះរបស់ខ្ញុំ ពីមុនមានព្រៃ និងមានស្រះយ៉ាងធំ។ ខ្មែរក្រហមបានយកអ្នកទោសមកសម្លាប់នៅទីនេះជាច្រើននាក់ ហើយកងឈ្លបមិនឱ្យប្រជាជនទៅក្បែរស្រះនោះទេ។ ក្រោយបែក ឃើញមានខ្មោះជាច្រើននៅជាប់ដៃរបស់សាកសព។

ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងដែលបាននាំយករទេះរុញមកប្រគល់ឱ្យខ្ញុំដល់ផ្ទះ ព្រោះខ្ញុំមិនអាចធ្វើដំណើរទៅចូលរួមកម្មវិធីចែករទេះរុញនៅសាលាឃុំព្រៃកណ្តៀងបាន។ ខ្ញុំត្រេកអរខ្លាំងណាស់។ រទេះរុញនេះ ខ្ញុំងាយស្រួលផ្នែក ហើយធ្វើឱ្យខ្ញុំអង្គុយបានយូរជាងមុន។



**៤) ផាន់ សាន់ ៖ កងចល័ត**

ខ្ញុំឈ្មោះ ផាន់ សាន់ ភេទស្រី អាយុ៨៣ឆ្នាំ។ ខ្ញុំរស់នៅភូមិព្រៃកំពែង ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ផាន់ ហើយម្តាយឈ្មោះ យិន។ ខ្ញុំគឺជាកូនទោលនៅក្នុងគ្រួសារ។ នៅអាយុ២០ឆ្នាំ ឪពុករបស់ខ្ញុំធ្លាក់ខ្លួនឈឺ ហើយក៏ស្លាប់។ គ្រួសារខ្ញុំមានហូបគ្រប់គ្រាន់ ប៉ុន្តែមិនសូវធូរធារប៉ុន្មានទេ។ កាលពីក្មេង ខ្ញុំមិនបានសិក្សារៀនសូត្រទេ គឺត្រូវជួយឃ្វាលគោ និងរកខ្យងស្វោរលក់។ ពេលខ្ញុំអាយុ២១ឆ្នាំ ក្នុងឆ្នាំ១៩៦៥ ខ្ញុំរៀបការជាមួយឈ្មោះ វ៉េន ដុន ដែលជាអ្នករស់នៅភូមិជាមួយគ្នា ហើយការរៀបការរបស់ខ្ញុំមានរយៈពេល៣ថ្ងៃ។

នៅសម័យ លន់ នល់ ក្នុងភូមិខ្ញុំចាប់ផ្តើមមានសង្គ្រាម និងមានគ្រាប់ផ្លោងពីទីរួមខេត្តព្រៃវែង និងមកពីខាងជ្រោយជ្រែ។ គ្រួសាររបស់ខ្ញុំបានជម្លៀសទៅស្រុកបាភ្នំ ហើយរស់នៅចល័តពីភូមិមួយទៅភូមិមួយទៀត។ អំឡុងពេលនោះខ្ញុំមានកូនចំនួន៣នាក់ ប៉ុន្តែកូនខ្ញុំនៅតូចៗណាស់។ នៅស្រុកបាភ្នំ អ្នកភូមិបាននាំគ្នាផ្តល់ស្រូវឱ្យគ្រួសារខ្ញុំបន្តិចបន្តួច ក្រៅពីនោះគឺប្តីខ្ញុំឆ្លៀតត្រឡប់មកធ្វើស្រែនៅភូមិកំណើតវិញ។ ការរស់នៅរបស់គ្រួសារខ្ញុំមិនសូវលំបាកប៉ុន្មានទេ គឺមានហូបគ្រប់គ្រាន់ ព្រោះប្តីខ្ញុំបានចេញរកបន្លែត្រីសាច់ទុកឱ្យខ្ញុំធ្វើម្ហូប។ នៅខាងស្រុកបាភ្នំ ខ្ញុំបានជួយធ្វើស្លុកស្លឹកត្នោត ដាក់បាយឱ្យកងទ័ពខ្មែរក្រហមនៅសមរភូមិ។ ក្រោយមកផ្ទះរបស់ខ្ញុំត្រូវភ្លើងឆេះអស់។ ខ្ញុំមិនដឹងថាត្រូវគ្រាប់ផ្លោងត្រូវ ឬក៏មានទាហានចូលមកដុតនោះទេ។

នៅឆ្នាំ១៩៧៥ គ្រួសារខ្ញុំបានត្រឡប់មករស់នៅក្នុងភូមិព្រៃកំពែងវិញ ព្រោះកងទ័ពរំដោះខ្មែរក្រហមទទួលបានជ័យជម្នះហើយ។ ពេលត្រឡប់មកដល់ភូមិព្រៃកំពែង ប្តីរបស់ខ្ញុំបានសាងសង់ខ្ទមតូចមួយសម្រាប់គ្រួសាររស់នៅ។ ការងាររបស់ខ្ញុំនៅក្នុងភូមិគឺធ្វើស្រែជាក្រុម ប៉ុន្តែខ្មែរក្រហមមិនទាន់ប្រមូលរបស់របរ និងឱ្យប្រជាជនហូបបាយរួមទេ។ ការងាររបស់ខ្ញុំនៅពេលនោះគឺធ្វើស្រែដកស្ទូងស្រូវ ហើយទទួលបានផលចែកតាមផ្ទះ។ ការចែកស្រូវក្នុងពេលនោះគឺគិតទៅតាមចំនួនសមាជិកក្នុងគ្រួសារ ដែលមានកូនច្រើនទទួលបានផលច្រើនជាងអ្នកភូមិដែលមានកូនតិច។

នៅឆ្នាំ១៩៧៦ ខ្ញុំឆ្លងទន្លេបានកូនប្រុសម្នាក់។ នៅពេលឆ្លងទន្លេ ខ្មែរក្រហមឱ្យខ្ញុំសម្រាករយៈពេលពីរខែ។ ការងាររបស់ស្ត្រីដែលទើបឆ្លងទន្លេរួច គឺត្រូវដាំដំណាំ ពោត សណ្តែក ដំឡូង អំពៅ ចេក និងដំណាំផ្សេងៗទៀតនៅក្នុងភូមិ។ នៅរដូវវស្សា ខ្ញុំជួយដកស្ទូង ប្រូតកាត់នៅក្នុងសហករណ៍។ ក្រោយមក នៅក្នុងភូមិរបស់ខ្ញុំចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិដាក់រួម ហើយហូបអាហាររួម។ ការហូបចុកនៅក្នុងសហករណ៍របស់ខ្ញុំគឺបបរ ប៉ុន្តែសំណាងល្អយើងអាចយកដំណាំដែលដាំក្នុងផ្ទះមកហូបបាន ហើយពេលខ្លះយើងត្រូវលួចអង្ករ។

នៅដើមឆ្នាំ១៩៧៩ នៅពេលកងទ័ពវៀតណាមចូលមករំដោះ គ្រួសារខ្ញុំមិនបានរត់ទៅណានោះទេ។ គ្រួសាររបស់ខ្ញុំបានទៅយករបស់របរដែលដាក់រួមមកវិញ និងប្រកបរបរធ្វើស្រែខ្លួនឯងចាប់តាំងពីពេលនោះមក។ សព្វថ្ងៃនេះ ខ្ញុំមានកូន៦នាក់។ ខ្ញុំតែងនិយាយរឿងរ៉ាវដែលខ្ញុំបានឆ្លងកាត់ប្រាប់ទៅកូនៗរបស់ខ្ញុំអំពីការហូបបបរនៅក្នុងរបបខ្មែរក្រហម ហើយកូនៗរបស់ខ្ញុំក៏ជឿខ្ញុំដែរ។

ខ្ញុំធ្លាក់ខ្លួនឈឺងងឹតភ្នែកអស់រយៈពេល៣ឆ្នាំមកហើយ ហើយសម្រាកខ្ញុំនៅមួយកន្លែងក្នុងផ្ទះ។ ខ្ញុំធ្លាប់បានទៅពិនិត្យនៅពេទ្យព្រះអង្គឌួងដែរ ប៉ុន្តែគ្រូពេទ្យថាព្យាបាលមិនជាសះស្បើយនោះទេ ព្រោះដាច់សរសៃភ្នែក។ ថ្ងៃនេះ ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនរទេះរុញមួយមកខ្ញុំ។ ខ្ញុំអាចជិះរទេះរុញនេះទៅលេងផ្ទះកូនបងប្អូនជិតខាង ហើយក៏អាចជិះទៅវត្តបានដែរ ទោះបីជាខ្ញុំមើលមិនឃើញក៏ដោយ។



**៥) ជ្រាវ លាង ៖ ខ្ញុំគិតថាបងខ្ញុំស្លាប់នៅទួលពោធិ៍**

ខ្ញុំឈ្មោះ ជ្រាវ លាង ភេទប្រុស អាយុ៦៩ឆ្នាំ រស់នៅភូមិស្តៅ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ បច្ចុប្បន្ន ខ្ញុំមិនអាចធ្វើការបានទៀតទេ ហើយក៏មិនអាចដើរចេញទៅក្រៅបានដែរ។ ខ្ញុំធ្លាក់ខ្លួនឈឺប្រហែល២ឆ្នាំមកហើយ។ ខ្ញុំលើសឈាម ទឹកនោមផ្អែម និងខ្វាញ់រុំសរសៃឈាម។ ខ្ញុំធ្លាប់បានទៅព្យាបាលនៅពេទ្យរុស្ស៊ី, ខាងកោះខ្សង ខេត្តកោះកុង និងនៅខេត្តព្រៃវែង បន្តែមិនបានធូរស្រាលប៉ុន្មានទេ។ អាការរបស់ខ្ញុំក្នុងពេលឥឡូវ គឺញ័រដៃជើងខាងស្តាំ និយាយមិនច្បាស់ ដើរមិនរួច ហើយខ្ញុំក៏មិនដែលបានទៅព្យាបាលទីណាទៀតដែរ គឺនៅបើកថ្នាំលើសឈាមពីមណ្ឌលសុខភាពយកមកលេប។

ខ្ញុំមានម្តាយឈ្មោះ នៅ ញឹម និងមានបងប្អូនចំនួន៦នាក់។ ស្ថានភាពគ្រួសារខ្ញុំគឺមានហូបគ្រប់គ្រាន់ ព្រោះឪពុកម្តាយខ្ញុំប្រកបរបបធ្វើស្រែ។ ខ្ញុំចូលរៀនដំបូងនៅវត្តស្តៅ ជាមួយលោកគ្រូឈ្មោះ លី។ ខ្ញុំរៀនបានពីរឆ្នាំ ក៏បន្តការសិក្សាថ្នាក់ទី១០ សង្គមចាស់នៅបឋមសិក្សាព្រៃកណ្តៀង ដោយស្នាក់នៅក្នុងវត្តព្រៃកណ្តៀងជាមួយលោកតា មិន។ ខ្ញុំរៀននៅព្រៃកណ្តៀងបានតែមួយឆ្នាំ ក៏មានសង្គ្រាមកើតឡើង ហើយខ្ញុំបានឈប់រៀនត្រឡប់មកផ្ទះវិញ។ នៅផ្ទះ ខ្ញុំជួយឃ្វាលគោ ក្របីម្តាយឪពុករបស់ខ្ញុំ។

នៅចន្លោះពីឆ្នាំ១៩៧២ ដល់ ឆ្នាំ១៩៧៣ ក៏មានការទម្លាក់គ្រាប់បែក និងបាញ់ផ្លោង ចូលមក

ក្នុងភូមិ។ គ្រួសាររបស់ខ្ញុំបានជម្លៀសប្រជាជនទៅភូមិវាលព្រៅ ក្នុងស្រុកពោធិ៍រៀង ខេត្តព្រៃវែង។ អំឡុងពេលធ្វើដំណើរ និងការស្នាក់នៅវាលព្រៅ គ្រួសាររបស់ខ្ញុំបានលួចចូលមកក្នុងភូមិវិញដើម្បីកើបស្រូវជង្រុកយកទៅបុកហូប។ រយៈពេលមួយឆ្នាំក្រោយមក ខ្ញុំបានប្តូរមកនៅខាងកើតភូមិធាយវិញ។ នៅទីនោះ មេភូមិឈ្មោះ អួន បានដឹកនាំប្រជាជន និងចងក្រុងជាសហករណ៍ធ្វើការងាររួម។ ការងាររបស់ខ្ញុំនៅទីនោះ គឺគ្រាន់តែចាំត្រៀមសែងអ្នករបួសវាយនៅសមរភូមិព្រៃវែង និងស្រុកពាមរក៍។ ខ្ញុំមកចាំសែងអ្នករបួសនៅម្តុំទួលកំពង់ទឹក វាយប្រយុទ្ធសមរភូមិសំរោង ខាងលិចភូមិព្រែកណ្តៀងក្នុងមួយសប្តាហ៍ម្តង។

នៅឆ្នាំ១៩៧៥ អ្នកភូមិរបស់ខ្ញុំដែលរស់នៅស្រុកបាភ្នំបានត្រឡប់ចូលមករស់នៅក្នុងភូមិវិញ។ អ្នកភូមិទាំងអស់ចាប់ផ្តើមរុះផ្ទះធំមកធ្វើជាខ្ទមស្នាក់នៅរៀងៗខ្លួនវិញ។ ពេលមករស់នៅក្នុងភូមិ ស្រួលបួល ខ្ញុំស្ម័គ្រចិត្តចូលធ្វើការជាកងឈ្លបភូមិ។ កងឈ្លបមានសមាជិកប្រមាណ១០នាក់ ហើយអ្នកដែលចូលក្រុមនេះបាន ទាល់តែជាអ្នកស្មោះត្រង់ជាមួយខ្មែរក្រហម និងមិនមានទំនាក់ទំនងជាមួយបងប្អូន។ ខ្មែរក្រហមបានប្រាប់កងឈ្លបឱ្យរើសអើងប្រជាជនដែលជម្លៀសមកពីភ្នំពេញ និងប្រជាជនដែលរត់ទៅនៅខាងលន់នល់។ ការងាររបស់កងឈ្លប គឺដើរយាមនៅពេលយប់។ នៅចុងឆ្នាំ១៩៧៥ នៅក្នុងភូមិស្តៅចាប់ផ្តើមប្រមូលរបស់របរដាក់រួម និងហូបបាយរួម។

នៅខែមិថុនា ឆ្នាំ១៩៧៦ ខ្មែរក្រហមបានរៀបការឱ្យខ្ញុំជាមួយប្រពន្ធឈ្មោះ ម៉េង ហ៊ន។ ពេលនោះខ្ញុំស្នើទៅអង្គការដើម្បីរៀបការដោយខ្លួនឯង មិនមែនអង្គការបង្ខំឡើយ។ ការរៀបការនៅពេលនោះ គឺមានចំនួន៦គូ នៅក្នុងវត្តស្តៅ។ ខ្ញុំរៀបការនៅពេលព្រឹក ចំណែកពេលរសៀលគឺចេញទៅធ្វើការធម្មតា និងមិនមានការជួបជុំហូបអាហារទេ។ បន្ទាប់ពីរៀបការរួច ប្រធានកងបានប្តូរខ្ញុំឱ្យទៅធ្វើការក្នុងកងចល័តនៅទួលបេះដូង។ នៅរដូវវស្សា ខ្ញុំភ្ជួរស្រែ និងដឹកជញ្ជូន ចំណែករដូវប្រាំងគឺលើកប្រព័ន្ធភ្លឺស្រែ។ ខ្ញុំនិងប្រពន្ធបានជួបគ្នានៅកន្លែងធ្វើការ ប៉ុន្តែយើងមិនអាចឈប់និយាយគ្នាបានទេ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានសម្រាកពេទ្យម្តង គឺដោយសារខ្ញុំកាប់ចបទៅត្រូវអណ្តូង ហើយខ្ទាតមកត្រូវជើង។ ខ្ញុំបានមកព្យាបាលពេទ្យឃុំក្នុងភូមិព្រែកណ្តៀង។ ការព្យាបាលរបស់ខ្ញុំគឺមានថ្នាំចាក់ដាក់ក្នុងដបពណ៌ក្រហមដូចទឹកក្រូច ហើយក៏មានថ្នាំទឹកដឹកដែរ។ ខ្ញុំសម្រាកព្យាបាលនៅពេទ្យបានកន្លះខែទើបបានធូរស្រាល និងទៅធ្វើការវិញ។ បងប្រុសរបស់ខ្ញុំម្នាក់ឈ្មោះ ជ្រាវ ម៉ារីន ត្រូវបានខ្មែរក្រហមយកទៅធ្វើការបាត់ដំណឹងរហូតដល់បច្ចុប្បន្ន។ ខ្ញុំគិតថា បងប្រុសរបស់ខ្ញុំបានស្លាប់នៅទួលពោធិ៍ ព្រោះគាត់បានបញ្ចេញសកម្មភាពមិនពេញចិត្តជាមួយខ្មែរក្រហម។ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ គ្រួសាររបស់ខ្ញុំបានប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមកូនៗ។

ខ្ញុំសប្បាយចិត្តណាស់ដែលមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងផ្តល់រទេះរុញមកខ្ញុំ។ ខ្ញុំនឹងឱ្យចៅៗជួយរុញរទេះដែលខ្ញុំជិះដើរលេងផ្ទះបងប្អូននៅក្នុងភូមិ។



## ៦) សន ភាង៖ កងកុមារ

ខ្ញុំឈ្មោះ សន ភាង ភេទស្រី អាយុ៦៣ឆ្នាំ រស់នៅភូមិព្រៃអង្គុញ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ សព្វថ្ងៃនេះ ខ្ញុំមានកូន៤នាក់ គឺស្រីទាំងអស់។ កូនៗរបស់ខ្ញុំមានគ្រួសារអស់ហើយ ហើយខ្ញុំនៅតែពីរនាក់ប្តីរបស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំមានឪពុកឈ្មោះ សន ចំណែកម្តាយខ្ញុំឈ្មោះ ជា និងមានបងប្អូនចំនួន៥នាក់។ គ្រួសាររបស់ខ្ញុំមានជីវភាពខ្វះខាត ហើយម្តាយខ្ញុំតែងតែមានជំងឺ។

កាលពីតូច ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១ ពីសង្គមចាស់ (ស្មើថ្នាក់ទី២បច្ចុប្បន្ន)។ ការងារខ្ញុំនៅពេល

នោះគឺ ឃ្វាលគោក្របី និងធ្វើស្រែប្រាំងៗ មកដល់របបលន់នល់ គ្រួសារខ្ញុំគេចទៅរស់នៅឃុំធាយ ស្រុកបាភ្នំ ជាមួយមីងរបស់ម្តាយខ្ញុំ។ ការរស់នៅទីនោះគឺមិនងាយស្រួលទេ ព្រោះខ្ញុំត្រូវឡើងមកដងទឹកពីភូមិទ័ពស្តេចយកទៅប្រើប្រាស់នៅផ្ទះ។ ចំណែកឪពុកខ្ញុំត្រូវទាហានលន់នល់ជិះយន្តហោះបាញ់ត្រូវជើង និងស្មា នៅពេលដែលគាត់មកស៊ីឈ្នួលលីអង្ករម្តាយឱ្យចិន។ ខ្ញុំខិតខំធ្វើការ មើលប្អូនរកម្ហូបអាហារ ហើយពេលខ្លះខ្ញុំបានលួចចូលមកក្នុងភូមិព្រៃអង្គុញវិញដើម្បីរកបន្លែ។ នៅឆ្នាំ១៩៧៥ គ្រួសារខ្ញុំបានត្រឡប់មកនៅផ្ទះវិញ ព្រោះសង្គ្រាមបានបញ្ចប់។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យចូលធ្វើការនៅក្នុងកងកុមារ។ ការងាររបស់កុមារ គឺត្រូវឃ្វាលគោក្របី, រើសសំរាម, លើកប្រព័ន្ធភ្លឺស្រែ និងទៅកាច់ពោតនៅបន្ទាយដេក។ ពេលខ្ញុំអាយុ១៦ឆ្នាំ ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យចូលក្នុងកងចល័ត និងត្រូវទៅរែកដីនៅខាងកោះជ័យ ស្រុកព្រះស្តេចរយៈពេល៣ខែ។ ពេលខ្ញុំត្រឡប់មករស់នៅផ្ទះក្នុងភូមិបានតែ៣ថ្ងៃ ប្រធានសហករណ៍បញ្ជូនខ្ញុំឱ្យទៅកាត់ដេរនៅខាងអន្លង់ទ្រា។ ខ្ញុំធ្វើដំណើរចេញពីភូមិ២នាក់ ប៉ុន្តែទៅដល់ត្រឹមឡូនេសាទ ខ្មែរក្រហមក៏ឱ្យខ្ញុំនៅធ្វើត្រីប្រហុកសិន។ ការងាររបស់ខ្ញុំ គឺដាំបាយ និងធ្វើត្រីប្រហុក។ នៅឡូនេសាទមានម្ហូបច្រើនណាស់ គឺមានត្រី បង្កង អន្ទង់ និងអណ្តើកទៀត។ ខ្ញុំរស់នៅឡូនេសាទបានរយៈពេល៣ខែ ក៏រត់ត្រឡប់មកផ្ទះវិញ ព្រោះនៅទីនោះមានការកាប់សម្លាប់គ្នា។ ខ្ញុំបានត្រឡប់មកធ្វើការនៅក្នុងកងចល័តវិញ ហើយការងាររបស់ខ្ញុំ គឺច្រូតស្រូវនៅក្នុងភូមិ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក គ្រួសាររបស់ខ្ញុំបាននាំគ្នារត់ទៅសំដៅអ្នកលឿង ប៉ុន្តែមួយរយៈក្រោយមកក៏ត្រឡប់មកយកម្តាយដែលឈឺទៅសម្រាកនៅពេទ្យតំបន់ក្នុងភូមិស្មោ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំចាប់ផ្តើមប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមគ្រួសារ។

នៅឆ្នាំ១៩៨១ ខ្ញុំរៀបការជាមួយឈ្មោះ ថី ថាន។ ការរៀបការរបស់ខ្ញុំប្រព្រឹត្តទៅតាមប្រពៃណី ហើយប៉ុន្តែមិនទាន់មានប្រាក់ចាយទេ។ ពេលរៀបការរួច ខ្ញុំត្រូវមើលថែប្អូនៗ ឪពុកម្តាយចាស់ ហើយត្រូវស្ទូង ដក ច្រូតកាត់ និងភ្ជួររាស់ដោយខ្លួនឯង។ ខ្ញុំមិនបានសម្រាកទេ ទោះបីជាខ្ញុំសម្រាលកូនហើយក៏ដោយ ចំណែកប្តីរបស់ខ្ញុំមកជួយខ្ញុំបានបន្តិចបន្តួច ព្រោះគាត់ត្រូវរត់គេចពីការចាប់ទៅធ្វើទាហាន។

ខ្ញុំត្រូវធ្វើការងារធ្ងន់រហូតដល់ខ្ញុំធ្លាក់ខ្លួនឈឺ។ មុនដំបូងខ្ញុំចាប់ផ្តើមឈឺជើងទាំងសងខាង ហើយនៅពេលទៅពិនិត្យពេទ្យថាខ្ញុំកប់សរសៃ។ ខ្ញុំបានទៅព្យាបាលខ្លះដែរ ប៉ុន្តែមិនបានធូរស្បើយទេ។ ខ្ញុំគិតថាជំងឺរបស់ខ្ញុំមកពីការធ្វើការធ្ងន់តាំងពីខ្ញុំនៅក្មេង។ បច្ចុប្បន្ននេះ ខ្ញុំមានជំងឺលើសឈាម ឡើងជាតិស្ករ និងឈឺនៅក្នុងខ្លួន។ ខ្ញុំមិនអាចដើរបានទេប្រសិនបើគ្មានឈើច្រត់ ហើយជាញឹកញាប់ខ្ញុំតែងតែវិលមុខ។

ខ្ញុំអរគុណក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងដែលផ្តល់រទេះរុញមកឱ្យខ្ញុំ។ រទេះរុញនេះនឹងជួយខ្ញុំឱ្យធ្វើដំណើរចេញទៅក្រៅបាន នៅពេលដែលខ្ញុំមានអារម្មណ៍ធុញថប់។



ផ្លូវលំក្នុងឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំក្រពើពីរ និងឃុំប្រម៉ោយ

**ធ្យូង ជានី**



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅឃុំក្រពើពីរ និងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានផ្តល់រទេះរុញចំនួន៣គ្រឿង និងកាសជំនួសត្រចៀកចំនួន២គ្រឿងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥នាក់ រស់នៅឃុំក្រពើពីរ និង ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ គួរបញ្ជាក់ថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលទទួលរទេះរុញ និង កាសជំនួយត្រចៀកនាពេលនេះ គឺសុទ្ធតែធ្លាប់ទទួលបានសេវាពិនិត្យសុខភាពដាបឋម និងប្រាក់ឧបត្ថម្ភសម្រាប់ការពិនិត្យសុខភាពពីគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ការចែកជូនរទេះរុញ និង កាសជំនួយត្រចៀកខាងលើ ក៏មានការចូលរួមសហការ និងទទួលស្វាគមន៍ពីអាជ្ញាធរមូលដ្ឋានភូមិឃុំ ដោយបានបង្ហាញអារម្មណ៍សប្បាយរីករាយ នៅពេលដែលប្រជាជនក្នុងភូមិរបស់ខ្លួនទទួលបានរទេះរុញ ដើម្បីធ្វើដំណើរទៅបុណ្យបុស្តាប់លោកទេសនានៅវត្តក្នុងរដូវបុណ្យភ្ជុំបិណ្ឌ។

នៅក្នុងឱកាសនោះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលទទួលបានរទេះរុញ និងកាសជំនួយត្រចៀកបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖



១) ខ្ញុំឈ្មោះ **សូ លន** ភេទស្រី អាយុ៧០ឆ្នាំ កើតនៅភូមិត្រពាំងទន្លេ ឃុំកំពុងឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយចិត្តជាខ្លាំងដែលមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ផ្តល់កាសជំនួយត្រចៀកមកដល់ខ្ញុំ។ កាសជំនួយត្រចៀកនេះ ពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ ព្រោះអាចជួយឱ្យខ្ញុំស្តាប់ឮខ្លាំងច្បាស់ជាងមុន និងជួយឱ្យខ្ញុំងាយស្រួលក្នុងការទំនាក់ទំនងជាមួយបងប្អូនក្រុមគ្រួសារ។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលតែងតែយកចិត្តទុកដាក់លើបញ្ហាសុខភាពរបស់ខ្ញុំ ព្រមទាំងផ្តល់កាសជំនួយត្រចៀកដល់រូបខ្ញុំ។

២) ខ្ញុំឈ្មោះ **ប៉ន ធឿន** ភេទប្រុស អាយុ៧១ឆ្នាំ កើតនៅភូមិព្រៃជ្រេស ខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ផ្តល់រទេះរុញចំនួន១គ្រឿងដល់ខ្ញុំដែលជាជនពិការ។ រទេះរុញនេះ ពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ។ ខ្ញុំនឹងជិះរទេះរុញចេញទៅលេងខាងក្រៅផ្ទះដោយខ្លួនឯងនៅក្បែរៗផ្ទះ និងមើលទេសភាពដើម្បីឱ្យអារម្មណ៍ស្រស់ស្រាយ។ ខ្ញុំក៏អាចប្រាស្រ័យទាក់ទងជាមួយញាតិមិត្តបងប្អូនក្នុងភូមិ។ ពិសេសមួយទៀត ក្រុមគ្រួសារខ្ញុំមិនសូវពិបាកមើលថែគ្រា ឬលើកខ្ញុំដូចមុនទៀតហើយ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលបានជូនរទេះរុញដល់រូបខ្ញុំ ប្រៀបដូចជាផ្តល់ជើងថ្មីឱ្យខ្ញុំបានដើរម្តងទៀត។ ខ្ញុំសូមជូនពរឱ្យក្រុមការងារទាំងអស់មានសុខភាពល្អ និងសំណូមពរឱ្យមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបន្តចែករទេះរុញជូនដល់ប្រជាជនជាបន្តបន្ទាប់ទៀត។



៣) ខ្ញុំឈ្មោះ **សេក រី** ភេទស្រី អាយុ៦៧ឆ្នាំ កើតនៅភូមិនារាយណ៍ ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ នៅពេលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះមកសួរសុខទុក្ខអំពីបញ្ហាសុខភាព និងរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមរបស់ខ្ញុំដំបូង ខ្ញុំពិតជាមានអារម្មណ៍រីករាយ ព្រោះខ្ញុំចង់ចែករំលែករឿងរ៉ាវរបស់ខ្ញុំទាំងអស់ដល់កូនចៅជំនាន់ក្រោយ ដើម្បីជាជំនួយដល់ការសិក្សារបស់សិស្សានុសិស្សយកទៅស្រាវជ្រាវ និងឈ្វេងយល់បន្ថែម។ ខ្ញុំកាន់តែសប្បាយរីករាយ ពេលដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែករទេះរុញឱ្យខ្ញុំដើម្បីជិះដោយខ្លួនឯងដោយមិនចាំបាច់ពឹងកូន និងប្តី។





៤) ខ្ញុំឈ្មោះ **គាំ ឡុន** ភេទប្រុស អាយុ៧២ឆ្នាំ កើតនៅភូមិក្រាំងថ្កូវ ឃុំព្រះភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ មូលហេតុដែលត្រចៀកខ្ញុំស្តាប់មិនឮ គឺមកពីវ័យចាស់ជរា បូកផ្សំជំងឺប្រចាំកាយរបស់ខ្ញុំមានបញ្ហាត្រចៀក។ ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំង នៅពេលដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះមកសម្ភាសន៍ខ្ញុំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដែលខ្ញុំបានឆ្លងកាត់។ កាសជំនួយត្រចៀកមួយនេះពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ ព្រោះជួយឱ្យខ្ញុំងាយស្រួលក្នុងការស្តាប់ច្បាស់ជាងមុន។ ខ្ញុំអាចទំនាក់ទំនងជាមួយកូនចៅ និងញាតិមិត្តជិតខាង។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងដែលបានផ្តល់កាសជំនួយត្រចៀកឱ្យខ្ញុំ។



៥) ខ្ញុំឈ្មោះ **ចិន បឿន** ភេទប្រុស អាយុ៦៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំពិតជាសប្បាយរីករាយដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងផ្តល់នូវរទេះរុញមកខ្ញុំ។ រទេះរុញនេះពិតជាមានសារសំខាន់ណាស់ចំពោះខ្ញុំ ព្រោះជួយឱ្យខ្ញុំអាចដិះដោយខ្លួនឯងបាន មិនសូវលំបាកដល់កូនចៅ។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលតែងតែយកចិត្តទុកដាក់ដល់ខ្ញុំ ហើយក៏សូមជូនពរឱ្យក្រុមការងារ ទាំងអស់ជួបតែសេចក្តីសុខ និងសម្រេចការងារគ្រប់ៗគ្នា។

ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំក្រពើពីរ និងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តចែករទេះរុញចំនួន៤គ្រឿង ជូនដល់អ្នករស់រានមាន

## ជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព និងបន្តស្តាប់ការរៀបរាប់អំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ទូច វណ្ណេត និង សាំង ចាន់ធូ



ផ្ទះរបស់ប្រជាជននៅតាមដងទន្លេមេគង្គ ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ពេលរដូវទឹកឡើង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចន្លោះពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបន្តចុះចែករទេះរុញចំនួន៤គ្រឿងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពមិនអាចដើររួច នៅស្រុកកំពង់សៀម និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ការផ្តល់រទេះរុញទាំង៤គ្រឿងនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីសម្រួលដល់ការលំបាក និងការធ្វើដំណើររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំងនេះ បង្ហាញនូវសេចក្តីរីករាយ និងថ្លែងអំណរគុណចំពោះក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលខ្វាយខ្វល់អំពីសុខភាព និងស្ថានភាពលំបាកពេលធ្វើដំណើររបស់ខ្លួន ព្រមទាំងបានចែករំលែកបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម ដូចខាងក្រោម៖

## ១) សឿង ហេង ៖ កងឡើងត្នោត និងផលិតស្ករ



សឿង ហេង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សឿង ហេង អាយុ៧៧ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ។ បច្ចុប្បន្ននេះ ខ្ញុំរស់នៅភូមិល្វា ឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបការជាមួយប្រពន្ធឈ្មោះ ថាន ខឿន និងមានកូនចំនួន៤នាក់ គឺស្រីទាំង៤នាក់។ ខ្ញុំមិនបានរៀនសូត្រទេ ដោយសារតែជីវភាពគ្រួសារក្រលំបាក។ នៅឆ្នាំ១៩៧០ ខ្ញុំនៅជួយធ្វើការងារឪពុកម្ដាយនៅផ្ទះ។ មិនយូរប៉ុន្មាន រដ្ឋប្រហារ លន់ នល់ បានកើតឡើងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

ចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ ការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើង។ អំឡុងពេលនោះ ការទម្លាក់គ្រាប់បែកពីសំណាក់ទាហាន លន់ នល់ នៅតាមភូមិកាន់តែច្រើនដើម្បីទប់ទល់ជាមួយកងទ័ពខ្មែរក្រហម ដែលនៅឈរជើងនៅតាមផ្ទះប្រជាជន។ យ៉ាងណាក៏ដោយ កងទ័ពខ្មែរក្រហមវាយលុក និងកាន់កាប់ទីតាំងជាច្រើនរហូតដល់ព្រំប្រទល់ទីរួមខេត្តកំពង់ចាម។ ចន្លោះពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានដាក់ឱ្យធ្វើការក្នុងកងប្រវាស់ដៃ ដើម្បីចែកស្រូវអង្ករគ្នាហូប។

មកដល់ដើមឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយរំដោះភូមិសាស្ត្រខេត្តកំពង់ចាមស្ទើរតែទាំងអស់ លើកលែងតែទីរួមខេត្តកំពង់ចាម ដែលនៅក្រោមការគ្រប់គ្រងរបស់ទាហាន លន់ នល់។ មិនយូរប៉ុន្មានបន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទាហានលន់ នល់ ដែលនៅបន្តប្រយុទ្ធការពារទីរួមខេត្តកំពង់ចាម បានបរាជ័យពីការវាយទប់ទល់ការចូលកាន់កាប់របស់កងទ័ពខ្មែរក្រហម។ ខ្ញុំបានឃើញប្រជាជន៧៥ ជម្លៀសពីទីរួមខេត្តកំពង់ចាម និងទីក្រុងភ្នំពេញ មកដល់ហាន់ជ័យ។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានចាត់តាំងឱ្យឡើងត្នោត។ កងឡើងត្នោត និងធ្វើស្ករត្នោត មានគ្នាចំនួន១២នាក់។ មិត្ត ធា ប្រធានកងបានដាក់ផែនការឱ្យសមាជិកកងឡើងត្នោតចំនួន៥០ដើមក្នុងម្នាក់។ យើងទាំងអស់គ្នាមិនបានឡើងតាមផែនការដាក់ចេញមកនោះទេ។ ខ្ញុំឡើងត្នោតចំនួន១៥ដើម និងបានទឹកត្នោតមួយខ្លះដើម្បីរំងាស់ជាស្ករ។ ក្នុងមួយថ្ងៃ កងឡើងត្នោត និងធ្វើស្ករត្នោត អាចផលិតស្ករត្នោតពី ៣-៤ខ្ទះ។ បន្ទាប់ពីឡើងត្នោតពេលព្រឹករួច ខ្ញុំត្រូវលាងបំពង់ រួចហើយត្រឡប់មកផ្ទះវិញ។ ដល់ពេលល្ងាចទើបខ្ញុំឡើងយកទឹកត្នោតម្ដងទៀត។ ចំណែកអ្នករំងាស់ស្ករត្នោតមានគ្នាចំនួន២នាក់ ដែលប្រចាំការនៅរោងសហករណ៍។ បន្ទាប់ពីរដូវឡើងត្នោតបានបញ្ចប់ ខ្ញុំត្រូវបានបញ្ជូនទៅភ្ជួរស្រែ ជាមួយក្របីមួយនឹមដែលប្រធានកងចែកឱ្យ។ នៅរដូវទឹកឡើង ខ្ញុំត្រូវទៅកាប់បង្គោលនៅលើភ្នំហាន់ជ័យ។ ការហូបចុករបស់ខ្ញុំ គឺហូបគ្រប់គ្រាន់ មិនដូចកងចល័តផ្សេងទេ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរំលំនៅដើមឆ្នាំ១៩៧៩ ខ្ញុំបន្តរស់នៅភូមិ និងប្រកបមុខរបរឡើងត្នោត និងធ្វើស្រែចម្ការ។

## ២) ដោក វន ៖ កងចល័តវ័យកណ្ដាល

ខ្ញុំឈ្មោះ ដោក វន ភេទប្រុស អាយុ៩១ឆ្នាំ រស់នៅភូមិល្វាទេរ ឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ ប៊ុន ថែម និងមានកូនចញ្ចឹមម្នាក់។ ខ្ញុំកើតនៅភូមិល្វាទេរ ឃុំហាន់ជ័យ ស្រុកកំពង់សៀមនេះតែម្ដង។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាវត្តក្រូចសើចដល់ថ្នាក់ទី៩ សង្គមចាស់។ នៅឆ្នាំ១៩៦៥ ខ្ញុំបានរៀបការប្រពន្ធនៅក្នុងភូមិល្វាទេរ និងប្រកបមុខរបរធ្វើស្រែចម្ការ។ ដោយសារមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទើបមានអ្នកភូមិបានទៅចូលរួមដង្ហែបាតុកម្មប្រឆាំងនឹងលន់ នល់ នៅទីរួមខេត្តកំពង់ចាម។ ក្រោយមកទៀតក៏មានសង្គ្រាមរវាងទាហាន លន់ នល់និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងជាច្រើនសមរភូមិនៅក្នុងខេត្តកំពង់ចាម។

នៅចន្លោះពីឆ្នាំ១៩៧២ ដល់ ឆ្នាំ១៩៧៣ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យសែងអ្នករបួស និងសាកសពកងទ័ពខ្មែរក្រហមដែលធ្វើសង្គ្រាមជាមួយទាហាន លន់ នល់ ពីខេត្តកំពង់ចាម។ សាកសពទាំងនោះត្រូវជញ្ជូនបណ្ដាក់គ្នាពីភូមិមួយទៅភូមិមួយទៀត។ ខ្ញុំមិនបានប្រកបមុខរបរធ្វើការដោយមានសង្គ្រាមដូច្នេះខ្ញុំក៏បានមកស្នាក់នៅផ្ទះបងប្អូននៅភូមិមាន់ហើរ ឃុំហាន់ជ័យ ស្រុកកំពង់សៀមវិញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយបែកនិងគ្រប់គ្រង។ រយៈពេល២ទៅ៣ថ្ងៃក្រោយមកខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង។ ខ្ញុំបានឃើញប្រជាជនថ្មីជាច្រើនមកពីភ្នំពេញដោយអ្នកខ្លះមានស្រុកកំណើតនៅ ហាន់ជ័យ និងខ្លះទៀតត្រូវបានជម្លៀសបន្តទៅតំបន់ផ្សេង។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដាក់ឱ្យធ្វើការនៅក្នុងកងវ័យកណ្ដាល និងថែទាំគោ ដើម្បីភ្ជួររាស់។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យភ្ជួររាស់ស្រែ និងដីចម្ការតាំងពីព្រឹកព្រលឹមរហូតដល់ម៉ោង១១ទើបឈប់ហូបបបរ បន្ទាប់មកភ្ជួររាស់បន្តពីម៉ោង១ រហូតដល់ម៉ោង៥ល្ងាច។ នៅខែខ្លះ ប្រធានកងចាត់តាំងខ្ញុំឱ្យធ្វើការនៅពេលយប់បន្ថែមទៀត ដូចជាដេញកណ្ដុរមិនឱ្យស៊ីស្រូវ និងពោត។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យភ្ជួរដីនៅល្អាក និងវិហារធំ ចំណែកប្រពន្ធខ្ញុំត្រូវបានចាត់តាំងឱ្យធ្វើការនៅក្នុងកងធ្វើអង្ករ។ បន្ទាប់មកទៀត ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យជីកប្រឡាយ លើកទំនប់ត្រួយចេក ដែលមានព្រំប្រទល់ជាប់គ្នារវាងឃុំទ្រាននិងឃុំស្រក។ ក្រោយពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ខ្ញុំនៅបន្តធ្វើស្រែចម្ការរហូតមក។



ដោក វន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៣) ហ៊ឹម អ៊ែល ៖ កងចល័តវ័យកណ្ដាល

ខ្ញុំឈ្មោះ ហ៊ឹម អ៊ែល មានអាយុ៨៨ឆ្នាំ រស់នៅភូមិហាន់ជ័យ ឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ជា ផុន និងមានកូនប្រុសស្រីចំនួន៥នាក់។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំមានឪពុកឈ្មោះ ហ៊ឹម និងម្ដាយឈ្មោះ អ៊ឹម និងមានបងប្អូនចំនួន២នាក់។ ខ្ញុំមិនបានរៀនសូត្រទេ ដោយសារជីវភាពក្រីក្រ។ ខ្ញុំនៅជួយធ្វើការជាមួយឪពុកម្ដាយ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ អ្នកភូមិបានទៅចូលរួមដង្ហែបាតុកម្មប្រឆាំងនឹង លន់ នល់ នៅទីរួមខេត្តកំពង់ចាម ដែលបានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ ក្រោយមក ក៏មានសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងជាច្រើនសមរភូមិនៅក្នុងខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ ខ្ញុំបានរៀបការប្រពន្ធនៅក្នុងភូមិហាន់ជ័យ។ នៅចន្លោះពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ខ្ញុំត្រូវបានកងទ័ពរំដោះខ្មែរក្រហមចាត់តាំងឱ្យសែងសាកសព និងកងទ័ពខ្មែរក្រហមដែលរងរបួសពេលធ្វើសង្គ្រាមជាមួយទាហាន លន់ នល់ ពីខេត្តកំពង់ចាម ដោយខ្ញុំត្រូវជញ្ជូនបណ្តាក់គ្នាពីភូមិមួយទៅភូមិមួយទៀត។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយបែកនិងគ្រប់គ្រង។ ក្រោយពីកងទ័ពខ្មែរក្រហមវាយបែកភ្នំពេញរយៈពេល២ទៅ៣ថ្ងៃ ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ខ្ញុំបានឃើញប្រជាជនថ្មីជាច្រើនបានធ្វើដំណើរមកដល់ភូមិ អ្នកខ្លះមានស្រុកកំណើតនៅ ហាន់ជ័យ និងខ្លះទៀតត្រូវបានជម្លៀសបន្តទៅតំបន់ផ្សេងៗ។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដាក់ឱ្យធ្វើការនៅក្នុងកងវ័យកណ្តាល និងថែទាំគោដើម្បីភ្ជួររាស់។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យភ្ជួរ ស្រែ និងភ្ជួរដីចម្ការតាំងពីព្រឹកព្រលឹម រហូតដល់ម៉ោង១១ទើបឈប់ហូបបបរ។ ខ្ញុំធ្វើការបន្តពីម៉ោង១រសៀល រហូតដល់ម៉ោង៥ល្ងាចទើបឈប់សម្រាក។ នៅខែខ្លះ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យធ្វើការនៅពេលយប់បន្ថែមទៀត ដូចជាដេញកណ្តុរមិនឱ្យស៊ី ស្រូវ និងពោត។ នៅឆ្នាំ១៩៧៧ ខ្ញុំមានកូនចំនួន២នាក់ ចំណែកប្រពន្ធខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យធ្វើការនៅក្នុងកងត្បាញក្រមា។ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំនៅបន្តធ្វើការស្រែចម្ការនៅក្នុងភូមិធម្មតា។


ហ៊ឹម អ៊ែល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អតីតកងទ័ពខ្មែរក្រហមម្នាក់ត្រូវបានបញ្ជូនទៅរៀនបើកយន្តហោះចម្បាំងនៅប្រទេសចិន

ឡុង ដានី



រូបថតនេះ កងទ័ពខ្មែរក្រហមចំនួន១៣នាក់ទៅរៀនបើកយន្តហោះនៅប្រទេសចិន ជាមួយគ្រូដែលជាជនជាតិចិនចំនួន២នាក់ និងអ្នកបកប្រែភាសា ខ្មែរ ចិនឈ្មោះ ជា។ រូបអង្គុយរាប់ពីឆ្វេងមកស្តាំ ទី១ឈ្មោះ ចិន បឿន, ទី២) ឈ្មោះ ចែម, ទី៣) ឈ្មោះ ឆែម ទី៤) ឈ្មោះ យាង, ទី៥) ឈ្មោះ តុង។ រូបឈរពីឆ្វេងមកស្តាំ ៖ ទី១) គ្រូជនជាតិចិនឈ្មោះ ឡោ គួ, ទី២) ឈ្មោះ ចែម (ប្រធានក្រុម) ទី៣) ឈ្មោះ ស៊ិត, ទី៤) ជនជាតិចិន (អនុប្រធាន ឡោ គួ), ទី៥) ឈ្មោះ ភឿន។ រូបឈរពីស្តាំមកឆ្វេង៖ ទី១) ឈ្មោះ អៀង វុធ (កូនប្រុសរបស់ អៀង សារី), ទី២) ឈ្មោះ ឡោ គ្រី, ទី៣) ឈ្មោះ ស៊ុន, ទី៤) ឈ្មោះ ជា (អ្នកបកប្រែភាសា ខ្មែរ- ចិន) ទី៥) ឈ្មោះ ញឹប និងទី៦) ឈ្មោះ អ៊ុម (អនុប្រធានក្រុម)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ុក យាង គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់ ក្នុងចំណោមកងទ័ពខ្មែរក្រហម៥០នាក់ ដែលត្រូវបញ្ជូនឱ្យទៅរៀនបើកយន្តហោះចម្បាំង ធុន៥ (Shenyang J-5) និង ធុន៦ (Shenyang J-6) នៅក្នុងខេត្តហឺប៉ី (Hebei) ប្រទេសចិន នៅដើមឆ្នាំ១៩៧៦។ រូបថតរបស់ ម៉ុក យាង គឺអង្គុយនៅលេខរៀងទី២ រាប់ពីស្តាំទៅឆ្វេង។ រូបថតនេះត្រូវបានថតនៅព្រលានយន្តហោះខេត្តហឺប៉ី ប្រទេសចិន នៅពាក់កណ្តាលឆ្នាំ១៩៧៨ នៅពេលរៀននឹងហ្វឹកហាត់បើកយន្តហោះប្រដេញត្រូវបានបញ្ចប់ និងត្រៀមខ្លួនត្រឡប់មកភ្នំពេញវិញ។ ម៉ុក យាង បានបន្ថែមថា នៅពេលបញ្ជូនទៅដល់ប្រទេសចិនដំបូង កងទ័ពខ្មែរក្រហមមានចំនួន៥០នាក់ តែក្នុងពេលរៀន និងអនុវត្តផ្ទាល់រយៈពេល៣ឆ្នាំ គឺមានតែអតីតកងទ័ពខ្មែរក្រហមប្រហែល១៥នាក់ប៉ុណ្ណោះ បានរៀន និងហ្វឹកហាត់ចប់សព្វគ្រប់ក្នុងចំណោម១៥នាក់នោះ ក៏មាន ម៉ុក យាង, អៀង វុធ (កូនប្រុសរបស់ អៀង សារី) សេន រស្មី (កូនប្រុសរបស់ សុនសេន) សិទ្ធិ (កូនប្រុសរបស់ វន វ៉េត)។ ចំណែកកងទ័ពខ្មែរក្រហមផ្សេងទៀតត្រូវបានគ្រូចិនដកចេញឱ្យទៅរៀនផ្នែកផ្សេងវិញ ពីព្រោះមិនមានសមត្ថភាពរៀនផ្នែកបើកយន្តហោះប្រដេញ និងកងទ័ពខ្មែរក្រហមមួយចំនួនទៀតត្រូវបានបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញដោយសារមានជាប់

ពាក់ព័ន្ធនឹងខ្សែរក្សត់ៗ ប្រវត្តិរឿងរ៉ាវរបស់ ម៉ុក យាង មានដូចខាងក្រោម៖

ខ្ញុំបាទឈ្មោះ ម៉ុក យាង ភេទប្រុស អាយុ៧០ឆ្នាំ ប្រកបរបរធ្វើចម្ការ ខ្ញុំមានស្រុកកំណើតនៅស្រុកស្អាង ខេត្តកណ្ដាល បច្ចុប្បន្ននេះខ្ញុំរស់នៅភូមិដាច់ស្រយាលមួយក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ៗ ខ្ញុំមានឪពុកឈ្មោះ ម៉ុក យន់ (ស្លាប់) នៅក្នុងរបបខ្មែរក្រហមដោយសារគ្មានអាហារហូបចុកគ្រប់គ្រាន់ និង ម្ដាយឈ្មោះ សុខ ហៀក (ស្លាប់ឆ្នាំ២០០៩)ៗ ខ្ញុំមានបងប្អូនចំនួន៥នាក់ នៅក្នុងនោះមានស្រីពានាក់ ខ្ញុំជាកូនទី២នៅក្នុងគ្រួសារៗ ប្រពន្ធទី១ របស់ខ្ញុំឈ្មោះ សៀក ម៉េត អាយុ៧០ឆ្នាំ គាត់រស់នៅភូមិអង្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង រស់នៅជាមួយគ្នាមានកូនចំនួន៣នាក់ (ស្រី២នាក់) ទើបលែងលះគ្នាៗ ប្រពន្ធទី២ឈ្មោះ ហាំង ភ័ត្រា អាយុ៤៥ឆ្នាំ ប្រកបរបរធ្វើចម្ការ មានកូនចំនួន២នាក់ ស្រីទាំងអស់ៗ នៅវ័យកុមារខ្ញុំរស់នៅជាមួយឪពុកម្ដាយនៅក្នុងភូមិអន្លង់តាសេក គ្រួសារប្រកបរបរធ្វើស្រែចម្ការ កាលពីសម័យនោះខ្ញុំបានរៀនសូត្រត្រឹមថ្នាក់ទី៧ ពីសង្គមចាស់ ស្មើនឹងថ្នាក់ទី៦នាពេលបច្ចុប្បន្នៗ ខ្ញុំរៀននៅសាលាក្នុងស្រុកកំណើតបានត្រឹមថ្នាក់ទី៧ ក៏ឈប់រៀនដោយសារតែ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ៗ ក្រោយពេលឈប់រៀនខ្ញុំបានចូលបម្រើកងទ័ព ពេលនោះខ្ញុំមានអាយុប្រហែល១៥ឆ្នាំ ហើយយុវជនៗនៅក្នុងស្រុកកំណើតដែលមានអាយុចាប់ពី១៥ ទៅ១៦ឆ្នាំ បានចូលបម្រើទ័ពជាច្រើននាក់ ដំបូងខ្មែរក្រហមឱ្យខ្ញុំទៅបោះទីតាំងនៅស្រុកកោះធំ នៅមុំវត្តពោធិ៍បាន ខ្ញុំរស់នៅទីនោះរៀនខាងផ្នែកអប់រំនយោបាយ រៀននៅទីនោះអស់រយៈពេលមួយខែ ក៏ផ្លាស់មករស់នៅវត្តអង្គព្រលឹង ស្រុកអង្គស្នួលៗ នៅដំបូងខ្ញុំស្ថិតនៅក្នុងវរសេនាធំលេខ១៤ កងពលលេខ១១ ដែលមានឈ្មោះ ទាញ និង សោម ជាប្រធាន និងអនុកងពលលេខ១១ៗ វរសេនាធំលេខ១៤ មានការបែងចែកជាបីកងវរសេនាតូច គឺវរសេនាតូចលេខ១១៦ វរសេនាតូចលេខ១១៧ និង



ម៉ុក យាង (រូបខាងស្ដាំ) កំពុងផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សារវាលវែងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វរសេនាតូចលេខ១១៨ៗ អង្គភាពខ្ញុំស្ថិតនៅក្នុងកងវរសេនាតូចលេខ១១៨ អនុសេនាធំលេខ៨១ កែវ ណារ៉ុង ជាប្រធាន ខ្ញុំរស់នៅទីនោះហាត់អំពីយុទ្ធសាស្ត្រក្នុងការវាយជាមួយខ្មាំង លោក កែវ ណារ៉ុង ជាអ្នកបង្ហាត់បង្រៀនផ្ទាល់ៗ ខ្ញុំបានហ៊ឹកហាត់បណ្ដើរចូលរួមប្រយុទ្ធនៅតាមសមរភូមិបណ្ដើរ ដំបូងកងវរសេនាតូចលេខ១១៨ របស់ខ្ញុំបានវាយនៅខត្តង្គ ក្រោយមកទៀតបានចូលមកវាយរាជធានីភ្នំពេញនៅតាមឈូករ៉ៅៗ នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំមានតួនាទីជាប្រធានអនុសេនាតូចលេខ៣ ក្នុងអនុសេនាធំ៨១ នៅក្នុងអនុសេនាធំ៨១មាន៣អនុសេនាតូច (អនុសេនាតូចលេខ១ លេខ២ និងលេខ៣) ៗ បន្ទាប់មកក៏មានការបង្កើតកងពលលេខ១១៤ មានតា សាន ជាប្រធានយោធា និងតា សារឿន ប្រធាននយោបាយៗ វាយចូលភ្នំពេញលើកទី២នៅផ្លូវជាតិលេខ៥ ម្ដុំស្ពានសត្វា អង្គភាពរបស់ខ្ញុំមានកងទ័ពស្លាប់អស់ជាច្រើននាក់ណាស់ៗ អនុសេនាតូចរបស់ខ្ញុំក៏បានចូលជួយកងទ័ពភូមិភាគនិរតីវាយនៅបន្ទាយប៉ារ៉ារបស់ លន់ នល់ ដែរៗ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយបែកទីក្រុងភ្នំពេញ អង្គភាពខ្ញុំបានចូលតាមបណ្ដោយផ្លូវលេខ៤ ពីខាងពោធិ៍ចិនតុងចូលមកភ្នំពេញ មកស្នាក់នៅម្ដុំស្ដាតអូឡាំពិកៗ ក្រោយមកប្រធានអនុសេនាធំនិងប្រធានវរសេនាតូចបានរៀបផែនការណ៍ ដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទាំងអស់

ដោយប្រាប់ប្រជាជនថា ខ្លាចអាមេរិកាំងមកទម្លាក់គ្រាប់បែក និងគ្មានអាហារហូបចុក។ ប្រជាជនខ្លះក៏ចេញទៅរស់នៅតាមជនបទ ហើយប្រជាជនមួយចំនួនតូចបានពួនសំងំនៅក្នុងផ្ទះ ពីព្រោះតែមិនចង់ចាកចេញពីផ្ទះរបស់ពួកគេ។ ក្រោយពេលជម្លៀសប្រជាជនពីទីក្រុងភ្នំពេញអស់ ខ្ញុំបានផ្លាស់មកធ្វើអាងទឹកនៅបឹងបាយ៉ាប ខ្ញុំមករស់នៅទីនេះអស់រយៈពេលមួយខែ ក៏ធ្វើដំណើរជាមួយកងពល១៨ មកនៅវត្តព្រះពុទ្ធមានបុណ្យវិញ។ ពេលនោះកងទ័ព១៨ បានប្តូរឈ្មោះជាកងពល៨០១ របស់អគ្គសេនាធិការវិញ។ បន្ទាប់មក ខ្ញុំក៏ត្រូវបានជ្រើសរើសឱ្យទៅរៀនបើកយន្តហោះចម្បាំងនៅប្រទេសចិន និងបានផ្លាស់មកនៅពោធិ៍ចិនតុងនៅចុងឆ្នាំ១៩៧៥។ នៅក្នុងកងអនុសេនាធំ៨១ របស់ខ្ញុំមានតែខ្ញុំម្នាក់គត់ ដែលបានទៅរៀន។ កាលនោះ ខ្ញុំមានតួនាទីជាអនុប្រធានកងអនុសេនាធំលេខ៨១ ខ្ញុំមិនសូវចង់ទៅរៀនប៉ុន្មានទេដោយសារតែ កែវ ណៅរ៉ុង ជាអ្នកចាត់តាំង ទើបខ្ញុំមិនអាចជំទាស់នឹងបទបញ្ជា។ នៅក្នុងកងពល៨០១ ខ្មែរក្រហមជ្រើសរើសច្រើនចាប់ពីប្រធានវរសេនាតូចចុះមកយុទ្ធជន។ បន្ទាប់ពីពិនិត្យសុខភាពបានរួចរាល់ ខ្ញុំនិងអ្នកផ្សេងទៀតប្រហែល១០០នាក់ (អ្នករៀនបើកយន្តហោះចម្បាំងចំនួន៥០នាក់ និងយន្តហោះទម្លាក់គ្រាប់បែកចំនួន៥០នាក់) រួមទាំងអ្នកបកប្រែភាសាចិនជាជនជាតិខ្មែរ-ចិន៣នាក់ (ប្តីឈ្មោះ ជា និងប្រពន្ធជាអ្នកបកប្រែខាងយន្តហោះចម្បាំង និងម្នាក់ទៀតជាអ្នកបកប្រែខាងយន្តហោះទម្លាក់គ្រាប់បែក)បានឡើងយន្តហោះចេញពីទីក្រុងភ្នំពេញរយៈពេល៤ម៉ោង ទៅចុះនៅព្រលានយន្តហោះក្រុងយុនមីង សម្រាកហូបបាយ និងចាក់សាំងយន្តហោះ រួចបន្តដំណើរពីក្រុងយុនមីងទៅទីក្រុងប៉េកាំងរយៈពេលប្រហែល៤ម៉ោងទៀត បានទៅដល់ព្រលានយន្តហោះទីក្រុងប៉េកាំងនៅម៉ោងប្រហែល៥ល្ងាច។ នៅព្រលានយន្តហោះទីក្រុងប៉េកាំង មាន ពេជ្រ ជាង ដែលជាអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសចិន និងកម្មាភិបាលជនជាតិចិនជាច្រើនរូបមកទទួលពួកខ្ញុំ ដោយមានរថយន្តក្រុងចំនួន៤គ្រឿង បានដឹកពួកខ្ញុំចេញពីព្រលានយន្តហោះទីក្រុងប៉េកាំង ឆ្ពោះទៅសណ្ឋាគារមានកម្ពស់៩ជាន់ ក្នុងទីក្រុងប៉េកាំង។ បន្ទាប់មកភាគីចិនបានចែកអាវរងារដល់ពួកខ្ញុំ (អ្នករៀនបើកយន្តហោះចម្បាំងទទួលបានអាវក្រាស់ល្មមៗ ចំណែកអ្នករៀនបើកយន្តហោះទម្លាក់គ្រាប់បែកទទួលបានអាវក្រាស់ និងអាវរោមចៀមមួយទៀត ពីព្រោះត្រូវទៅរៀននៅទីក្រុងហាប៊ីន ដែលជាតំបន់ត្រជាក់ខ្លាំង)។ កងទ័ពខ្មែរក្រហមដែលរៀនផ្នែកយន្តហោះចម្បាំងទាំង៥០នាក់ មានអ្នកប្រែភាសាខ្មែរ-ចិនសរុបចំនួន៥នាក់ គឺអ្នកប្រែភាសាជាជនជាតិចិនចំនួន៣នាក់ (ចេះភាសាខ្មែរ) និងអ្នកបកប្រែជនជាតិខ្មែរពីរនាក់ (ឈ្មោះ ជា និងប្រពន្ធ)។ ប្រធានក្រុមកងទ័ពខ្មែរក្រហមដែលរៀនផ្នែកយន្តហោះចម្បាំងទាំង៥០នាក់ មានឈ្មោះ ស៊ូ ចែម និងអនុប្រធានមានឈ្មោះ យិន អ៊ឹម។ ខ្ញុំនៅចាំថា ពេលពួកខ្ញុំទៅដល់ប្រទេសចិនដំបូងក្នុងរដូវផ្ការីក។ ពួកខ្ញុំស្នាក់នៅទីក្រុងប៉េកាំងរយៈពេល១សប្តាហ៍ ភាគីចិនបាននាំពួកខ្ញុំទៅទស្សនកិច្ចនៅតំបន់ជាច្រើន ដូចជានៅវាំងចាស់ ធានអានមេន មហាកំពែងជាដើម។ ចិនទទួលរាក់ទាក់ពួកខ្ញុំបានយ៉ាងល្អ ទាំងការស្នាក់នៅ និងការហូបចុក គឺគ្រប់គ្រាន់។ បន្ទាប់ពី១សប្តាហ៍នៅទីក្រុងប៉េកាំង ពួកខ្ញុំដែលរៀនបើកយន្តហោះចម្បាំងត្រូវជិះរថភ្លើងចេញពីប៉េកាំងទៅក្រុងស៊ីងយ៉ាង។ ចំណែកកងទ័ពខ្មែរក្រហមដែលរៀនបើកយន្តហោះទម្លាក់គ្រាប់បែកទៅទីក្រុងហាប៊ីននៅជិតសហភាពសូវៀត។ បន្ទាប់ពីធ្វើដំណើរតាមរថភ្លើងរយៈពេលមួយយប់មួយថ្ងៃពួកខ្ញុំបានមកដល់ក្រុងស៊ីងយ៉ាងដើម្បីរៀនភាសាចិន ដោយមានគ្រូជនជាតិចិនជាអ្នកបង្រៀន គ្រូអត់ចេះភាសាខ្មែរទេ ប៉ុន្តែមានអ្នកបកប្រែនៅជាមួយ។ គ្រូជនជាតិចិនបានបែងចែកពួកខ្ញុំរៀនពីរថ្នាក់។ បន្ទាប់ពីរៀនបានរយៈពេលប្រហែល ១ទៅ២ខែ ចិនបានបញ្ជូនពួកខ្ញុំតាមរថភ្លើងចេញពីក្រុងស៊ីងយ៉ាង ទៅកាន់ក្រុងស៊ីចៀជួង (Shijiazhuang) នៃខេត្តហឺប៉ី (Hebei) និងបន្តចូលរៀនភាសាចិនបន្ថែមរយៈពេល១ខែទៀត។ បន្ទាប់មកចូលរៀនទ្រឹស្តីផ្នែកយន្តហោះចម្បាំងរយៈពេល៣ទៅ៤ខែ ព្រមទាំងមានអ្នកបកប្រែចាំជួយបក

ប្រែក្នុងពេលរៀនមានគ្រូចិនម្នាក់បង្រៀនសិស្ស ៣នាក់ៗ ក្នុងពេលរៀនទ្រឹស្តីយន្តហោះ គឺរៀនអំពីកម្លាំងឡើងកម្លាំងចុះ កម្លាំងទម្ងន់របស់យន្តហោះ។ បន្ទាប់ពីចប់វគ្គទ្រឹស្តី ពួកខ្ញុំចូលរៀនផ្នែកយន្តហោះហ្វឹកហ្វឺនធុន៦ (Shenyang J-6) រយៈពេល១០០ម៉ោង ស្មើរនឹងមួយឆ្នាំនៅព្រលានវាលស្មៅក្នុងក្រុងស៊ីចៀជួង ខេត្តហឺប៉ី។ រៀនបើកជាក់ស្តែងជាមួយគ្រូជនជាតិចិន គឺយន្តហោះហ្វឹកហ្វឺនធុន៦ ជាប្រភេទយន្តហោះស្ទាបកាត់មានល្បឿនយឺត បើកយន្តហោះប្រភេទនេះគ្រឡាប់កាប់ផ្ងារយ៉ាងមិចក៏បានដែរ នៅលើយន្តហោះមានកន្លែងអង្គុយ២ សិស្សនៅមុខ គ្រូនៅក្រោយ និងមានចង្កូតម្នាក់មួយ។ ឆ្នាំទី២ខ្ញុំចូលរៀនអនុវត្តន៍ជាក់ស្តែងលើយន្តហោះប្រដេញធុន៥ (Shenyang J-5) ប្រើពេល១០០ម៉ោង ស្មើនឹងរយៈមួយឆ្នាំក្នុងព្រលានយន្តហោះមួយផ្សេងទៀតក្នុងក្រុងស៊ីចៀជួង ខេត្តហឺប៉ី។ ឆ្នាំទី៣ ខ្ញុំបន្តទៅរៀនអនុវត្តន៍ជាក់ស្តែងលើយន្តហោះប្រដេញធុន៦ (Shenyang J-6) រយៈពេល១ឆ្នាំទៀត នៅព្រលានយន្តហោះធំផ្សេងមួយទៀតក្នុងខេត្តហឺប៉ីដូចគ្នា។ ក្នុងពេលរៀននិងអនុវត្តផ្ទាល់រយៈពេល៣ឆ្នាំ មានអ្នកខ្លះជាប់ និងអ្នកខ្លះទៀតត្រូវបានគ្រូចិនដកចេញឱ្យទៅរៀនផ្នែកផ្សេងវិញ។ ចំណែកមួយចំនួនទៀតត្រូវបានបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ ដោយមានជាប់ពាក់ព័ន្ធខ្សែក្បត់។ ដំបូងមានគ្នា៥០នាក់ ចុងក្រោយនៅសល់ប្រហែលតែ១៥នាក់ប៉ុណ្ណោះ។ ខ្ញុំចាំម្នាក់ឈ្មោះ ប៊ូ សារិន ត្រូវបានគ្រូចិនដកចេញឱ្យទៅរៀនផ្នែកបញ្ជូរវិញ។ ក្នុងពេលរៀនបើកយន្តហោះចម្បាំងនៅខេត្តហឺប៉ី មានគណៈប្រតិភូកម្ពុជារួមមាន តាណាត តាលៃ មកទស្សនកិច្ចកន្លែងខ្ញុំរៀនដែរ។ ចំណែកឈ្មោះ សិទ្ធិ ជាកូនប្រុសរបស់ វ៉ន វ៉េត ក៏ត្រូវបានដកចេញពីក្រុម ខណៈពេលកំពុងហ្វឹកហាត់បន្ថែមនៅព្រលានយន្តពោធិ៍ចិនតុងនៅចុងឆ្នាំ១៩៧៨។ បន្ទាប់ពីរៀនចប់យន្តហោះចម្បាំងទាំង៣ប្រភេទ ក្រុមយន្តហោះចម្បាំងទាំងអស់ធ្វើដំណើរចេញពីខេត្តហឺប៉ីមកទីក្រុងប៉េកាំងរួចធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែខ្ញុំ និង យិន អ៊ីម មិនទាន់បានត្រឡប់ទៅវិញនោះទេ ពួកខ្ញុំទាំងពីរនៅសណ្ឋាគារនៅទីក្រុងប៉េកាំងបន្តទៀត ព្រោះនៅមើលថែអ្នកបកប្រែឈ្មោះ ជា ដោយសារគាត់បានផឹកថ្នាំរឹតបូលក្នុងពោះក្នុងគោលបំណងមិនចង់ត្រឡប់មកប្រទេសកម្ពុជាវិញ។ ជា ត្រូវបញ្ជូនទៅមន្ទីរពេទ្យ មានប្រពន្ធជាអ្នកមើលថែ។ ខ្ញុំនិង យិន អ៊ីម រង់ចាំនៅសណ្ឋាគាររយៈពេល១សប្តាហ៍។ បន្ទាប់មកខ្ញុំនិង យិន អ៊ីម ត្រូវបានភាគីចិនបញ្ជូនត្រឡប់មកប្រទេសវិញ។ ខ្ញុំនិង យិន អ៊ីម ធ្វើដំណើរទៅព្រលានយន្តហោះប៉េកាំង អ្នកដំណើរនៅលើយន្តហោះទាំងអស់រួមមាន ខ្ញុំ យិន អ៊ីម និងគណៈប្រតិភូអ៊ីតាលីចំនួន៣នាក់ (ប្រុសទាំងអស់) សរុប ៥នាក់ ជិះយន្តហោះប្រភេទប៊ូអ៊ីង ចេញពីប៉េកាំងមកប្រទេសកម្ពុជាក្នុងរយៈពេល៥ម៉ោង។ ពេលមកដល់ទីក្រុងភ្នំពេញនៅម៉ោងប្រហែល១២ថ្ងៃត្រង់។ ពេលមកដល់ភ្នំពេញ ខ្ញុំត្រូវបានបញ្ជូនទៅ





យន្តហោះប្រដេញធុន Shenyang របស់ចិន ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្តាតអូ ឡាំពិកនៅជាមួយក្រុមអ្នកបើកយន្តហោះចម្បាំងដែលបានមកកាលពី១សប្តាហ៍មុនៗ គ្រូចិនបានមកបង្ហាត់បង្រៀនផ្នែកបច្ចេកទេស និងរបៀបហោះហើរនៅព្រលានយន្តហោះពោធិ៍ចិនតុងរយៈពេល៥០ម៉ោង ស្មើនឹងកន្លះឆ្នាំបន្ថែមទៀតៗ នៅខណៈពេលខ្មែរក្រហមកំពុងវាយប្រយុទ្ធនៅតាមព្រំដែនកម្ពុជា វៀតណាម ពួកខ្ញុំកំពុងហ្វឹកហាត់ហោះហើរនៅព្រលានយន្តហោះពោធិ៍ចិនតុងនៅឡើយៗ ចិនបញ្ជូនយន្តហោះចម្បាំងធុន៥ និងធុន៦ តាមកប៉ាល់ពីប្រទេសចិនមកកម្ពុជាសរុប១០គ្រឿងមកពោធិ៍ចិនតុង ដើម្បីឱ្យពួកខ្ញុំហាត់រៀនៗ ខ្ញុំហោះហើរហ្វឹកហ្វឺនពីព្រលានយន្តហោះពោធិ៍-ចិនតុងទៅមោងឫស្សី ទៅកំពង់ស្ពឺ ទៅតាខ្មៅ និងត្រឡប់មកព្រលានវិញ កាត់តាមតំបន់ពិសេសៗ ខ្ញុំអាចហោះហើរម្នាក់ឯង ខ្ញុំហោះហើរតាមដែនទីចេញពីពោធិ៍ចិនតុង ទៅមោងឫស្សី បន្តទៅកំពង់ស្ពឺរួចត្រឡប់ចូលព្រលានវិញក្នុងរយៈពេល១ម៉ោងកន្លះ ហោះហើរក្នុងកម្ពស់៦០០០ ចម្ងាយ៥០០គីឡូម៉ែត្រក្នុងមួយម៉ោងៗ យន្តហោះប្រដេញមួយគ្រឿងអាចផ្ទុកកាំភ្លើង៣ដើម ព្យួរគ្រាប់បែករួម ទាំងធុងសាំងបម្រុងសម្រាប់ការហោះហើរឆ្ងាយ ធុងសាំងបម្រុងមានចំណុះ៩០០លីត្រ បើកហោះហើររយៈពេល៣០នាទីបន្ថែមទៀតៗ យន្តហោះប្រដេញមួយគ្រឿងត្រូវចំណាយសាំងអស់១៨០០លីត្រក្នុងមួយម៉ោងៗ នៅដើមឆ្នាំ១៩៧៩ ក្នុងពេលវៀតណាមចូលមករំដោះ ពួកខ្ញុំមិនទាន់បានបញ្ចប់គ្រប់បច្ចេកទេសយន្តហោះនោះទេ ហើយមិនទាន់អាចបាញ់កាំភ្លើងបាននៅកំឡុងកំពុងបើកបរនៅឡើយៗ ក្រោយមកខ្មែរក្រហមបានដក ស៊ូ ចែម ដែលជាប្រធានក្រុមយន្តហោះចម្បាំងឱ្យទៅកាន់ជាប្រធានវរសេនាធំមួយក្នុងកងពល៧០៣វិញៗ បន្ទាប់មកដក យិនអ៊ីម ដែលជាអនុប្រធានក្រុមយន្តហោះចម្បាំងឱ្យទៅកាន់ព្រលានយន្តហោះកងកេងនៅកំពង់សោមៗ បន្ទាប់មក ខ្ញុំឡើងប្រធានក្រុមអ្នកបើកយន្តហោះចម្បាំងៗ នៅមុនកងទ័ពវៀតណាមចូលមកដល់ភ្នំពេញប្រហែល១សប្តាហ៍ ម្តាយរបស់ អៀង វុធ (អៀង ធីរិទ្ធ) បានប្រាប់ពួកខ្ញុំឱ្យត្រៀមឯកសារគ្រោងនឹងឱ្យត្រឡប់ទៅប្រទេសចិន ដើម្បីរៀនបន្ថែមទៀត ប៉ុន្តែនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពួកខ្ញុំត្រូវដិះឡានរត់ទៅបាត់ដំបង ដោយសារកងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជាលឿនពេក ទើបពួកខ្ញុំមិនបានត្រឡប់ទៅប្រទេសចិនវិញៗ ពួកខ្ញុំបានវាយជាមួយកងទ័ពវៀតណាម នៅភូមិឪម៉ាល់ ខេត្តបាត់ដំបង បានត្រូវគ្រាប់ចំជើង បាន លោក អៀង វុធ ជាអ្នកអៀវមករកទីតាំងសុវត្ថិភាពជិតដល់ភ្នំសំពៅ ទើបមានឡានដឹកទៅព្យាបាលនៅស្រុកសំឡូតៗ ខ្ញុំដេកនៅមន្ទីរពេទ្យអស់រយៈពេលជាច្រើនខែ ទម្រាំតែដើរបានៗ ក្រោយពេលចេញពីមន្ទីរពេទ្យខ្ញុំបានចូលសមរភូមិម្តងទៀតនៅក្នុងកងពល៥០២ វាយជាមួយកងទ័ពវៀតណាមរហូតដាច់ស្បៀង ក៏នាំគ្នាចូលសារភាពចុះចាញ់ជាមួយកងទ័ពវៀតណាមនៅភូមិម៉ុងរី ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ៗ កងទ័ពវៀតណាមបានចាប់ខ្ញុំយកទៅដាក់គុកនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ឃុំខ្លួនខ្ញុំរយៈពេលបីថ្ងៃរួចបំរុងដោះលែង ក្រោយពេលបានដឹងថា ខ្ញុំជាអ្នករៀនបើកបរយន្តហោះនៅស្រុកចិន ឃុំខ្លួនខ្ញុំនៅក្នុងគុកម្តងទៀតដោយធ្វើទារុណកម្មវាយដំខ្ញុំយ៉ាងដំណំរយៈពេល៧យប់៧ថ្ងៃ កងទ័ពវៀតណាមជាអ្នកវាយខ្ញុំផ្ទាល់ៗ ក្រោយមកបញ្ជូនខ្ញុំទៅស្រុកស្អាង ជាប់ឃុំនៅទីនោះអស់រយៈពេលមួយឆ្នាំទៀត នៅទីនោះវៀតណាមមិនធ្វើទារុណកម្មអ្វីទេ គ្រាន់តែប្រើឱ្យធ្វើការងារអាខស និង ដាំបន្លែៗ ក្រោយពេលចេញពីគុកខ្ញុំបានរៀបការ និងបាននាំប្រពន្ធទៅរស់នៅភ្នំតូចភ្នំធំនៅក្នុងខេត្តបន្ទាយមានជ័យប្រកបរបរលក់ដូរបន្តិចបន្តួចៗ មុនឆ្នាំបោះឆ្នោតរបស់អ៊ុនតាក់ ខ្ញុំបាននាំប្រពន្ធនិងកូនៗមករស់នៅខេត្តកំពង់ឆ្នាំង ដែលជាស្រុកកំណើតប្រពន្ធខ្ញុំវិញៗ ខ្ញុំរស់នៅជាមួយគ្នារយៈពេលប៉ុន្មានឆ្នាំក៏លែងលះគ្នាៗ នៅក្នុងឆ្នាំ២០១៣ ខ្ញុំមានប្រពន្ធមួយទៀត និងបានមករស់នៅក្នុងភូមិអង្ក្រង ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក៏ប្រកបរបរធ្វើចម្ការរហូតមកដល់បច្ចុប្បន្ននេះៗ

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំដំណើរ
## ទស្សនកិច្ចសិក្សាស្តីពី«សន្តិភាព និង សិទ្ធិមនុស្ស» ដល់សិស្សានុសិស្ស មកពីវិទ្យាល័យតេជោ សែន សំរោង

មេក ទិន



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រតំបន់អន្លង់វែងដល់សិស្សមកពីវិទ្យាល័យ តេជោ សែន សំរោង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីពី«សន្តិភាពនិងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន២៥នាក់ មកពីវិទ្យា-ល័យតេជោសែន សំរោង។ ទស្សនកិច្ចសិក្សានេះធ្វើឡើងក្នុងគោលបំណងឱ្យសិស្សានុសិស្ស បានចូលរួមទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រផ្ទាល់ដែលនៅមានសេសសល់ពីរបបខ្មែរក្រហម។

នៅវេលាម៉ោង៨នាទីព្រឹក សិស្សានុសិស្សបានធ្វើដំណើរមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅលើខ្នងភ្នំដងរែក ដែលជាអតីតផ្ទះប្រជុំរបស់តាម៉ុក។ បន្ទាប់ពីសិស្សានុសិស្ស គយគន់ទេសភាពនៅលើខ្នងភ្នំដងរែករួចហើយ ក៏បានធ្វើដំណើរសំដៅមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដោយមានក្រុមការងារចាំទទួលស្វាគមន៍។ ក្រុមការងារក៏មានការរៀបចំពិព័រណ៍រូបថត និងដឹកនាំសិស្សានុសិស្សទស្សនាពិព័រណ៍ស្តីពី «សង្គ្រាម និងអំពើប្រល័យពូជសាសន៍» នៅបរិវេណមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រួមទាំងក្រុមការងារ បានធ្វើការណែនាំខ្លួនដល់សិស្សានុសិស្ស និងធ្វើបទបង្ហាញ

ដល់សិស្សដោយផ្តោតសំខាន់លើកិច្ចការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ជាពិសេសលើកយកនូវបរិបទប្រវត្តិសាស្ត្រជុំវិញការកកើតរបបខ្មែរក្រហម សោកនាដកម្មក្រោមអំពើឃោរឃៅ និងការបិទបញ្ចប់នូវទំព័រប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ នៅពេលនោះក៏មានការបញ្ចាំងឯកសារស្តីពី «តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនៅក្នុងស្រុកអន្លង់វែង» ក្នុងគោលបំណងបង្ហាញដល់សិស្សានុសិស្សអំពីការចាប់ផ្តើមកកើតតំបន់អន្លង់វែង រហូតដល់ការចូលមករស់នៅតំបន់អន្លង់វែងរបស់ខ្មែរក្រហម។

គួររំឭកថា កាលពីខែកញ្ញា ឆ្នាំ១៩៨៩ វៀតណាមបានដកកងទ័ពរបស់ខ្លួនប្រមាណ២សែននាក់ ចេញពីប្រទេសកម្ពុជា។ ក្នុងឆ្នាំដដែល កងទ័ពខ្មែរក្រហមនៅលើភ្នំ១០០៣ និងខ្មែរក្រហមដែលកាន់កាប់តាមបណ្តោយព្រំដែនដទៃទៀត បានបើកយុទ្ធនាការទ្រង់ទ្រាយធំវាយដណ្តើមយកតំបន់មួយចំនួនក្នុងប្រទេសកម្ពុជាមកគ្រប់គ្រងវិញ។ ខ្មែរក្រហមបានចាប់ផ្តើមកេណ្ឌជនភៀសខ្លួនប្រមាណ៦ពាន់នាក់ ដើម្បីជួយដឹកជញ្ជូនគ្រឿងសព្វាវុធ និងស្បៀងអាហារទៅឱ្យកងទ័ពនៅសមរភូមិមុខៗ ដោយមានគ្រឿងសព្វាវុធនៅក្នុងឃ្លាំងគ្រប់គ្រាន់ កងទ័ពខ្មែរក្រហមក្រោមការដឹកនាំរបស់ តាម៉ុក នៅលើភ្នំ១០០៣ បានបើកការវាយប្រហារផ្តាច់ព្រ័ត្រនៅចុងឆ្នាំ១៩៨៩ ដើម្បីចូលកាន់កាប់តំបន់អន្លង់វែង។ ការវាយប្រហារត្រូវបានធ្វើឡើងនៅចំថ្ងៃបុណ្យភ្ជុំបិណ្ឌ។ ព្រឹត្តិការណ៍នេះបានកើតឡើងអស់រយៈពេល៣៥ឆ្នាំមកហើយ បើគិតមកដល់ខែកញ្ញា ឆ្នាំ២០២៤។ បន្ទាប់មកសិស្សានុសិស្សបានផ្តិតយករូបភាពស្រស់ស្អាតនៃធម្មជាតិលើខ្នងភ្នំដងរែកទុកជាអនុស្សាវរីយ៍។ ទន្ទឹមនឹងនេះ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏បានចែក «ទស្សនាវដ្តីស្វែងរកការពិត (លេខពិសេស)» ជូនសិស្សានុសិស្ស។ តមកទៀតសិស្សានុ-សិស្សបានធ្វើដំណើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួន ដូចជា ទីតាំងបូជាសព ប៉ុល ពត, ទីតាំងបូជាសព សុន សេន និងក្រុមគ្រួសារ, ចេតិយតាម៉ុក និងសារមន្ទីរតាម៉ុក។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចសិក្សា សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

១) ខ្ញុំឈ្មោះ **រិទ្ធ ស្រីពៅ** ភេទស្រី អាយុ១៨ឆ្នាំ។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តនៅពេលដែលបានទៅដល់ទីតាំងប្រវត្តិសាស្ត្រផ្ទាល់។ ពីមុនមកខ្ញុំធ្លាប់តែឮការនិយាយតៗគ្នាតែប៉ុណ្ណោះ។ ខ្ញុំយល់កាន់តែច្បាស់ពីសង្គ្រាមកើតមាននៅតំបន់អន្លង់វែង។ ខ្ញុំគិតថាការចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានេះ បានជួយខ្ញុំឱ្យយល់ដឹងបន្ថែមទៀតពីផលលំបាកនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩)។ ខ្ញុំចាប់អារម្មណ៍ទៅលើប្រធានបទការសម្លាប់ សុន សេន និងគ្រួសារ និងការស្លាប់របស់ ប៉ុល ពត។ ខ្ញុំចាប់អារម្មណ៍ទៅលើទីតាំងបូជាសព ប៉ុល ពត ផ្ទះលាក់ខ្លួនប៉ុល ពត និងទីតាំងសារមន្ទីរផ្ទះ តាម៉ុក។ ចំណែកទីតាំង ផ្ទះតាម៉ុក បានបន្សល់ទុកនូវប្រវត្តិសាស្ត្រជាច្រើនដល់ខ្ញុំបានសិក្សារៀនសូត្រ។ ចុងក្រោយ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឱ្យកើតមានម្តងទៀត យើងត្រូវប្រឆាំងអំពើណាដែលនាំឱ្យមានអំពើប្រល័យពូជសាសន៍។

២) ខ្ញុំឈ្មោះ **ពេជ្រ ខន្លា** ភេទប្រុស អាយុ១៨ឆ្នាំ។ ខ្ញុំបានឈ្វេងយល់ និងស្គាល់ពីទីតាំងប្រវត្តិ-សាស្ត្រផ្ទាល់។ កាពីមុនខ្ញុំធ្លាប់តែឮចាស់ៗនិយាយថា របបខ្មែរក្រហមគឺជារបបខ្មៅងងឹត ប្រើអំណាចកាប់សម្លាប់ធ្វើបាបប្រជាជន ហើយអ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម មិនចង់ឱ្យរបបនេះកើតមានទៀតទេ។ ជាក់ស្តែង ពេលខ្ញុំបានឃើញទីតាំងរួមទាំងស្លាកស្នាមខ្លះៗដែលបានបន្សល់ទុកពីរបបខ្មែរក្រហមធ្វើឱ្យខ្ញុំមានអារម្មណ៍សោកស្តាយ និងអាណិតទៅដល់ប្រជាជនខ្មែរដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបផ្តាច់ការនោះ។ ខ្ញុំក៏មិនចង់ឱ្យកើតមានរបបនេះនៅក្នុងប្រទេសកម្ពុជាយើងទេ។ ខ្ញុំគិតថាការសិក្សាពីប្រវត្តិសាស្ត្រមានសារសំខាន់ណាស់។ ខ្ញុំនឹងយកចំណេះដឹងរបស់ខ្ញុំទៅចែករំលែកដល់មិត្តភក្តិ និងបង្រៀនក្មេងជំនាន់ក្រោយពីរបបខ្មែរក្រហមថាជារបបផ្តាច់ការ និងសាហាវឃោរឃៅ។ ខ្ញុំគិតថា ប៉ុល ពត ជានាយករដ្ឋមន្ត្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែកន្លែងបូជាសពរបស់គាត់

មិនមែនជាកន្លែងបូជាសពមនុស្សនោះទេ ដូច្នេះ ខ្ញុំគិតថា ប៉ុល ពត ពិតជាមានកេរ្តិ៍ឈ្មោះអសោចៗ

៣) ខ្ញុំឈ្មោះ **ពេជ្រ ផាន់ន្នី** ភេទប្រុស អាយុ ២០ឆ្នាំ។ ខ្ញុំសប្បាយចិត្តដែលបានចូលរួមនៅក្នុងដំណើរទស្សនកិច្ចសិក្សាស្តីពី «សន្តិភាព និងសិទ្ធិមនុស្ស» ព្រោះខ្ញុំបានមកទស្សនាទីតាំងផ្ទាល់ និងបានថតយករូបភាពពីទីតាំងប្រវត្តិសាស្ត្រសំខាន់ៗ និងទេសភាពនៅលើខ្នងភ្នំដងរែក ដើម្បីទុកផ្សព្វផ្សាយបន្តដល់អ្នកដែលមិនបានចូលរួម និងអ្នកដែលរស់នៅឆ្ងាយពីតំបន់អន្លង់វែង។ ខ្ញុំចាប់អារម្មណ៍ទៅលើព្រឹត្តិការណ៍ រូបទង់បដិវត្តន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងរូបភាពការកាប់សម្លាប់ធ្វើទារុណកម្មទៅលើប្រជាជនខ្មែរនៅក្នុងរបបខ្មែរក្រហម។ ការធ្វើដំណើរទៅកាន់តំបន់ប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងស្រុកអន្លង់វែង បានធ្វើឱ្យខ្ញុំកាន់តែយល់ច្បាស់ពីការរស់នៅរបស់ខ្មែរក្រហម ខ្ញុំបានឈ្វេងយល់ពីកាលបរិច្ឆេទការស្លាប់របស់មេដឹកនាំធំៗនៅក្នុងរបបខ្មែរក្រហម ដូចជា ប៉ុល ពត សុន សេន និង តាម៉ុក។

៤) ខ្ញុំឈ្មោះ **ភួង នីកា** ភេទស្រី អាយុ១៦ឆ្នាំ។ ពីមុនខ្ញុំធ្លាប់តែរៀនតាមសៀវភៅនៅក្នុងថ្នាក់អំពីរបបខ្មែរក្រហម ដូច្នេះខ្ញុំមិនសូវជាចាប់អារម្មណ៍ទេ។ ពេលខ្ញុំធ្វើដំណើរមកកាន់ទីតាំងប្រវត្តិសាស្ត្រសំខាន់ៗដែលបានបន្សល់ទុកពីរបបខ្មែរក្រហមទើបខ្ញុំចាប់អារម្មណ៍។ ខ្ញុំចាប់អារម្មណ៍ជាងគេគឺទីតាំងផ្ទះតាម៉ុក ដែលបច្ចុប្បន្ននេះ គឺជាសារមន្ទីរផ្ទះ តាម៉ុក។ ខ្ញុំដឹងថាផ្ទះទាំងបួនរបស់ តាម៉ុក សុទ្ធតែមានតួនាទីផ្សេងៗពីគ្នា។ ជាក់ស្តែងដូចជាផ្ទះសម្រាប់ដាក់ ឡាន ផ្ទះសម្រាប់ស្នាក់នៅរបស់ តាម៉ុក កន្លែងទទួលភ្ញៀវរបស់ តាម៉ុក និងកន្លែងទុកវត្ថុបុរាណ និងរូបចម្លាក់។ ខ្ញុំយល់ថាការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាមានសារសំខាន់ណាស់សម្រាប់ខ្ញុំជាយុវជនជំនាន់ក្រោយ ដើម្បីឱ្យខ្ញុំបានយល់ដឹងពីការលំបាករបស់ប្រជាជនខ្មែរនៅក្នុងរបបនោះ។ ខ្ញុំបានឈ្វេងយល់ពីតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមនៅអន្លង់វែង។

ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ធ្វើបទបង្ហាញអំពីរូបភាពព្រឹត្តិការណ៍ទាក់ទងនឹងកាលប្បវត្តិរបស់ខ្មែរក្រហមប្រាប់ដល់សិស្សវិទ្យាល័យតេជោសែន សំរោង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាស្រាវជ្រាវស្តីអំពី «ជីវិតប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅជំរំជនភៀសខ្លួន»

សាំង ចិន្តា



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនប្រាប់សិស្សមកពីវិទ្យាល័យ ស្គន់ នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាស្រាវជ្រាវប្រចាំខែរបស់ខ្លួនស្តីពី «ជីវិតប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅជំរំជនភៀសខ្លួន»។ វេទិកាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីបង្កើនចំណេះដឹងរបស់យុវជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងយល់ដឹងអំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ វេទិកាស្រាវជ្រាវនេះ មានការចូលរួមពី គីម អាត អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអតីតជនភៀសខ្លួននៅជំរំជនភៀសខ្លួន សាយធូ ស្ថិតនៅជាប់ព្រំដែនកម្ពុជា-ថៃ និងយុវសិស្សដែលជាសិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុនសែន ស្គន់ នៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ របៀបវារៈនៃវេទិកាស្រាវជ្រាវនេះ គឺរួមមាន បទបង្ហាញស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ការបញ្ចាំងវីដេអូឯកសារ, កិច្ចសន្ទនាអន្តរជំនាន់រវាងអ្នក

រស់រានមានជីវិតពីរបបខ្មែរក្រហមអំពីជីវិតប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម និងបទពិសោធន៍រស់នៅជំរំជនភៀសខ្លួន និងការចុះទស្សនកិច្ចសិក្សាទៅកាន់ស្តូបរំឭកសម្រាប់សហគមន៍ដែលត្រូវបានសាងសង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

ពេលមកដល់បរិវេណខាងមុខមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម សិស្សានុសិស្សត្រូវបានទទួលស្វាគមន៍ និងណែនាំអំពីបេសកកម្មរបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ជាកិច្ចបន្ត លោក ស៊ាង ចិន្តា នាយកមណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើបទបង្ហាញដោយសង្ខេបអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយផ្តោតលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ មានដូចជា៖ រដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំ, ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម និងការសម្លាប់រង្គាលទៅលើប្រជាជន។ មុនពេលបញ្ចប់បទបង្ហាញរបស់ខ្លួន លោក ស៊ាង ចិន្តា បានចាក់បញ្ចាំងវីដេអូឯកសារដែលមានចំណងជើងថា ៖ «កុមារកម្ពុជា»។

គោលបំណងនៃការចាក់បញ្ចាំងវីដេអូឯកសារនេះ គឺដើម្បីឱ្យយុវជនជំនាន់ក្រោយយល់បន្ថែមទៀតអំពីផលលំបាក បន្សល់ទុកដោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ វីដេអូឯកសារនេះ បង្ហាញអំពីរបបប្រល័យពូជសាសន៍បានបំផ្លាញប្រទេស និងសម្លាប់ជីវិតប្រជាជនកម្ពុជា ដែលបន្សល់ទុកនូវទុក្ខវេទនាដល់កុមារកម្ពុជាដែលក្លាយជាក្មេងកំព្រា។ វីដេអូឯកសារនេះមិនត្រឹមតែបង្កើតនូវសេចក្តី អាណិតអាសូរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តុះស្មារតីទំនួលខុសត្រូវរួមចំពោះប្រទេសជាតិរបស់យុវជនជំនាន់ក្រោយ។

ដើម្បីបង្កើនការយល់ដឹងកាន់តែស៊ីជម្រៅរបស់សិស្សទាំងអស់អំពីជីវិតប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម ក៏ដូចជាផលប៉ះពាល់ក្រោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម គឺសិស្សមានឱកាសស្តាប់រឿងរ៉ាវរបស់ គឹម អាត ដែលជាអ្នករស់រានមានជីវិតពីខ្មែរក្រហម និងអតីតជនភៀសខ្លួននៅជំរំជនភៀសខ្លួន សាយធូ។ គឹម អាត ចាប់ផ្តើមចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនថា ៖ «ខ្ញុំជួបជាមួយកូនក្មួយនាពេលនេះ គឺខ្ញុំមានចិត្តសប្បាយរីករាយណាស់។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិបឹងកុក២ សង្កាត់បឹងកុក ក្រុងកំពង់ចាម។ កាលពីនៅក្មេង ខ្ញុំទៅរៀននៅសាលាបឋមសិក្សាខត្តរ រហូតដល់ថ្នាក់ទី៦ (ចាស់)។ នៅឆ្នាំ១៩៦៩ ខ្ញុំបានផ្លាស់ទៅរស់នៅជាមួយបងស្រីរបស់ខ្ញុំនៅខេត្តបាត់ដំបង។ បន្ទាប់ពីរដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០ ម្តាយរបស់ខ្ញុំទៅរកខ្ញុំនៅខេត្តបាត់ដំបង ដើម្បីយកមករស់នៅខេត្តកំពង់ចាមវិញ។ ប៉ុន្តែនៅពេលនោះ យើងមិនអាចធ្វើដំណើរតាមរថយន្តបានទេ ពីព្រោះកងទ័ពខ្មែរក្រហមចាប់ផ្តើមវាយរំដោះភូមិសាស្ត្រជាច្រើននៅខេត្តបាត់ដំបង ដូច្នេះ យើងអាចធ្វើដំណើរចេញពីខេត្តបាត់ដំបងបានគឺតាមយន្តហោះ។ បងស្រីខ្ញុំបានទៅទិញសំបុត្រយន្តហោះចំនួនពីរ។ ម្តាយ និងបងស្រីរបស់ខ្ញុំបានជិះយន្តហោះត្រឡប់មកខេត្តកំពង់ចាមមុន។ ខ្ញុំបន្តរស់នៅជាមួយបងថ្លៃ និងក្មួយប្រុសរបស់ខ្ញុំ។

នៅឆ្នាំ១៩៧៣ សង្គ្រាម រវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើងៗ។ ខ្ញុំ បងថ្លៃ និងក្មួយ បានបន្តរស់នៅ ទីរួមខេត្តបាត់ដំបង។ នៅពេលដែលកងទ័ពខ្មែរក្រហមវាយកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីរួមខេត្តបាត់ដំបងត្រូវបានរំដោះនៅចុងខែមេសា។ ខ្ញុំត្រូវបានបញ្ជូនទៅរស់នៅភូមិអន្លង់វិល ស្រុកសង្កែ។ ពីក្រុងបាត់ដំបងទៅដល់អន្លង់វិល ខ្ញុំត្រូវបានខ្មែរក្រហមសួរថា តើឪពុកម្តាយរបស់ខ្ញុំធ្វើការងារអ្វីក្នុងរបបមុន? ខ្ញុំបានឆ្លើយថា ជាកសិករ។ ខ្មែរក្រហមបានបន្តសួរខ្ញុំថា តើខ្ញុំមានឪពុកធ្វើទាហាន លន់ នល់ ដែរឬទេ? ខ្ញុំបានឆ្លើយថា មិនមានឪពុកធ្វើទាហានទេ។ ខ្ញុំប្រាប់ខ្មែរក្រហមថា ខ្ញុំគឺជាក្មេងកំព្រា។ នៅថ្ងៃបន្ទាប់ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើស្រែជាមួយអ្នកដទៃ។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានបញ្ជូនទៅប៉ៃលិន។

ខ្មែរក្រហមបានបង្ខំខ្ញុំឱ្យរៀបការជាមួយជនពិការនៅទីនោះ។ ខ្ញុំបានបដិសេធ និងសុំអង្វរខ្មែរក្រហម។ មិត្តប្រធានបានប្រាប់ខ្ញុំឱ្យជ្រើសរើសថា រៀបការ ឬទៅធ្វើការនៅចម្ការដំឡូង។ ខ្ញុំមិនប្រាកដថា តើខ្មែរក្រហមនឹងសម្លាប់ខ្ញុំនៅចម្ការដំឡូងនោះ ឬយ៉ាងណាទេ។ នៅព្រឹកបន្ទាប់ ខ្ញុំត្រូវបានដឹកទៅចម្ការដំឡូង ដើម្បីធ្វើការជាមួយមិត្តនារី៤នាក់ផ្សេងទៀតដែលបានបដិសេធមិនរៀបការដូចខ្ញុំដែរ។ យើងត្រូវបានខ្មែរក្រហមតាមដានគ្រប់ពេល។ ប្រសិនបើយើងប្រព្រឹត្តកំហុសណាមួយ យើងនឹងត្រូវបានចាប់យកទៅសម្លាប់មិនខាន។ ខ្ញុំរស់នៅក្នុងភាពភ័យខ្លាច។ នៅពេលយប់ ខ្ញុំតែងតែឃើញខ្មែរក្រហមបណ្ដើរមនុស្សយកទៅសម្លាប់។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានផ្លាស់មកច្រូតស្រូវ។ ខ្ញុំរស់នៅយ៉ាងលំបាក ដោយសារមានអ្នកចាំឃ្លាំមើលរាល់សកម្មភាពការងាររបស់ខ្ញុំ ពីព្រោះខ្ញុំជាប្រជាជនថ្មី (ប្រជាជន៧៥) មកពីទីរួមខេត្តបាត់ដំបង។ នៅឆ្នាំ១៩៧៨ ខ្ញុំ និងមិត្តនារីផ្សេងទៀត ត្រូវបានបញ្ជូនទៅលើទំនប់នៅតំបន់៥។ ខ្ញុំត្រូវក្រោកពីព្រលឹមទល់ព្រលប់ដើម្បីរែកដី។ នៅខែភ្លឺ ខ្ញុំត្រូវធ្វើការបន្ថែមទៀត គឺចាប់ពីម៉ោង៨យប់ដល់ម៉ោង១២ពាក់កណ្ដាលអធ្រាត្រ។ ខ្ញុំបន្តលើកទំនប់រហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមករំដោះ នៅដើមឆ្នាំ១៩៧៩។ នៅពេលនោះ ខ្ញុំមិនបានវិលត្រឡប់មកខេត្តកំពង់ចាមវិញទេ គឺខ្ញុំបានភៀសខ្លួនទៅរស់នៅតាមជួរភ្នំដងរែក។ ក្រោយមកទៀត ខ្ញុំត្រូវបានបញ្ជូនឱ្យទៅរស់នៅជំរំជនភៀសខ្លួន សាយធូ ស្ថិតនៅព្រំដែនខ្មែរ-ថៃ។ ខ្ញុំរស់នៅទីនោះជាច្រើនខែ ហើយក្រោយមកខ្ញុំបានដឹងថា បងថ្លៃ និងក្មួយរបស់ខ្ញុំត្រូវបានទទួលយកទៅរស់នៅប្រទេសទីបី។ ឈ្មោះរបស់ខ្ញុំក៏ស្ថិតក្នុងបញ្ជីផងដែរ ប៉ុន្តែដោយបារម្ភពីគ្រួសារខ្ញុំនៅខេត្តកំពង់ចាម ខ្ញុំក៏សម្រេចចិត្តមិនចេញទៅរស់នៅក្រៅប្រទេស និងវិលត្រឡប់ទៅជួបជុំឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំវិញ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនមានទំនាក់ទំនងជាមួយបងថ្លៃ និងក្មួយដែលចេញទៅរស់នៅក្រៅប្រទេសនោះទេ។ សារចុងក្រោយរបស់ខ្ញុំទៅកាន់កូនក្មួយ ទាំងអស់គ្នានាពេលនេះ គឺខ្ញុំឆ្អែតនឹងសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្ញុំឆ្អែតនឹងការរត់គេចគ្រាប់, ដឹកប្រឡាយ និងលើកទំនប់។ ខ្ញុំបាក់ស្បាតចំពោះការងារ



សិស្សមកពីវិទ្យាល័យ ស្គន់ ទស្សនកិច្ចស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទាំងអស់នេះ។ ខ្ញុំមិនចង់ឱ្យរឿងទាំងអស់នេះកើតឡើងទៀតទេ។ ខ្ញុំនៅរស់ជីវិតម្តងទៀតបន្ទាប់ពីរំដោះឆ្នាំ១៩៧៩»។

បន្ទាប់ពីវាគ្មិនចែករំលែកបទពិសោធន៍រួច សិស្សបានចូលរួមកិច្ចពិភាក្សាដោយលើកជាសំណួរដូចខាងក្រោម ៖

**សំណួរទី ១៖** ហេតុអ្វីបានជាមានកុមារកំព្រានៅកម្ពុជាច្រើន បន្ទាប់ពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមដួលរលំ?

**សំណួរទី ២៖** តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?

**សំណួរទី ៣៖** តើជីវិតរស់នៅក្នុងជំរំជនភៀសខ្លួនយ៉ាងដូចម្តេច?

**សំណួរទី ៤៖** តើប្រទេសណាខ្លះទទួលយកជនភៀសខ្លួនកម្ពុជា?

**សំណួរទី ៥៖** តើអ៊ំស្រី គឹម សាត បានបាត់បង់សមាជិកគ្រួសារដែរឬទេ?

នៅចុងបញ្ចប់នៃវេទិកាស្រាវជ្រាវនេះ សិស្សបន្តចុះទស្សនកិច្ចសិក្សាទៅកាន់ស្តូបរំឭកសម្រាប់សហគមន៍ នៅកោះសូទិន និងស្រុកកំពង់សៀម។ ស្តូបរំឭកសម្រាប់សហគមន៍ ផ្តល់ជាវេទិកាផ្ទាល់ និងជានិមិត្តរូបសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងអ្នកដែលមានពិការភាពដើម្បីផ្សារភ្ជាប់ ប្រាស្រ័យទាក់ទង និងចែករំលែកបញ្ហាប្រឈមដែលតែងជួបប្រទះ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងជាទូទៅដើម្បីដោះស្រាយ។ គោលបំណងនៃទស្សនកិច្ចសិក្សានេះ គឺផ្តល់ឱកាសឱ្យសិស្សបញ្ចេញមតិ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបទពិសោធន៍បញ្ហាប្រឈម និងការជម្នះរាល់ឧបសគ្គរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងអ្នកមានពិការភាព តាមរយៈការប្រាស្រ័យទាក់ទង និងចែករំលែកបទពិសោធន៍ពីអតីតកាល។

នៅក្នុងឱកាសនេះដែរ សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

**ឌ័ន ស្រីណា** សិស្សថ្នាក់ទី១១ នៃវិទ្យាល័យហ៊ុន សែន ស្តុន់ នៅស្រុកជើងព្រៃ លើកឡើងថា «ខ្ញុំទទួលបានចំណេះដឹងថ្មីៗជាច្រើនពីវេទិកាស្រាវជ្រាវនេះ។ ពីមុនខ្ញុំមិនដឹងថា ប្រជាជនកម្ពុជាទៅរស់នៅតាមបណ្តាប្រទេសផ្សេងដោយសារមូលហេតុអ្វីទេ គឺខ្ញុំទើបតែដឹងថាដោយសារតែសង្គ្រាម និងអំពើប្រល័យពូជសាសន៍។ លើសពីនេះ ខ្ញុំស្តាប់សាច់រឿងផ្ទាល់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលអាចឱ្យខ្ញុំដឹងពីដំណើរជីវិតរបស់គាត់ទាំងស្រុង។ ខ្ញុំធ្លាប់តែឮយាយតាប្រាប់ខ្ញុំ។ អ្វីដែលខ្ញុំទទួលបាននៅថ្ងៃនេះ ខ្ញុំនឹងយកទៅចែករំលែកជាមួយគ្រួសាររបស់ខ្ញុំនៅផ្ទះ និងមិត្តភក្តិនៅសាលា។ ខ្ញុំនឹងសួរតាយាយរបស់ខ្ញុំថា តើគាត់បានរត់ទៅដល់ជំរំជនភៀសខ្លួនដែរឬទេ»។

**ឡឿន សុវណ្ណារី** សិស្សថ្នាក់ទី ១១នៃវិទ្យាល័យហ៊ុន សែន ស្តុន់ នៅស្រុកជើងព្រៃ រៀបរាប់ថា ៖ «ខ្ញុំទទួលបានចំណេះដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងយល់ដឹងពីបទពិសោធន៍លំបាករបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បើទោះបីជារបបខ្មែរក្រហមដួលរលំនៅថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ ក៏ដោយ ប្រជាជនកម្ពុជានៅតែប្រឈមនឹងបញ្ហាលំបាកជាច្រើន មានដូចជា កុមារកំព្រា ការបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់ និងជំងឺ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ក្នុងកិច្ចសន្ទនាជាមួយអ៊ំ គឹម អាត នោះគឺបទពិសោធន៍របស់គាត់នៅជំរំជនភៀសខ្លួននៅព្រំដែនខ្មែរថៃ។ អ៊ំស្រី គឹម សាត មានឱកាសទៅរស់នៅក្នុងជីវិតដ៏ល្អប្រសើរនៅប្រទេសផ្សេង ប៉ុន្តែអ៊ំស្រីបានជ្រើសរើសវិលត្រឡប់មកជួបជុំជាមួយគ្រួសារក្នុងប្រទេសវិញ។ ខ្ញុំក៏មានឱកាសចុះទស្សនកិច្ចទៅកាន់ស្តូបរំឭកសម្រាប់សហគមន៍ ដែលខ្ញុំអាចឈ្វេងយល់អំពីប្រវត្តិសាស្ត្រដែលបានកើតឡើងនៅក្នុងភូមិដែរ»។

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកា ថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ភ្នំជីសូរ

**សន ឌីនីន**



លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ភ្នំជីសូរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនមួយ ដើម្បីពិភាក្សាពីចម្ងល់ផ្សេងៗ ទាក់ទងនឹងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សថ្នាក់ទី១២ ចំនួន៣០នាក់មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ភ្នំជីសូរ។ គោលបំណងនៃការបង្កើតវេទិកាពិភាក្សានេះដើម្បីដោះស្រាយចម្ងល់ផ្សេងៗរបស់សិស្សានុសិស្ស ទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងផ្តល់នូវចំណេះដឹងថ្មីៗអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

បន្ទាប់ពីសិស្សានុសិស្សធ្វើដំណើរមកដល់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក៏មានការទទួលស្វាគមន៍ពីបុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តតាកែវយ៉ាងរាក់ទាក់។ បន្តមកទៀត ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវក៏បង្ហាញផ្ទាំងរូបភាពដែលដាក់តាំងបង្ហាញនៅ ខាងមុខ និង ខាងក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដល់សិស្ស។ នៅឱកាសនោះដែរ សិស្សអានសៀវភៅដែលតម្កល់នៅបណ្ណាល័យមានចំណងជើងថា «រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម» ដែលទើបតែបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និង

សៀវភៅអប់រំអំពីសុខភាព ដែលបោះពុម្ពដោយគម្រោង «ការលើកកម្ពស់សិទ្ធិនិងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ ក្រោយពីអានសៀវភៅ និងទស្សនារូបភាពព្យួរនៅតាមជញ្ជាំង សិស្សនាំគ្នាចូលទៅអង្គុយនៅក្នុងថ្នាក់រៀន ដោយសិស្សទទួលទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ លេខពិសេស ឆ្នាំ២០២៤ ម្នាក់មួយក្បាល ទុកសម្រាប់អាន។

ខណៈនោះ លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចាប់ផ្តើមណែនាំខ្លួនទៅកាន់សិស្សានុសិស្ស និងបានសួរសំណួរទៅកាន់សិស្សានុសិស្សទាក់ទងរបស់ខ្មែរក្រហម (១៩៧៥-១៩៧៩)។ បន្ទាប់មក លោក ផេង ពង្សរ៉ាស៊ី លើកយកចំណុចខ្វះខាតដែលសិស្សពុំបានដឹងពីមុនមកធ្វើការបកស្រាយពន្យល់នៅក្នុងកម្មវិធីវេទិកាពិភាក្សានេះ និងលើកយកដំណើរការកាត់ទោសមេដឹកនាំខ្មែរនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហមប្រាប់ដល់សិស្ស និងលើកឡើងអំពីយុត្តិធម៌សម្រាប់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

នៅចុងបញ្ចប់វេទិកាថ្នាក់រៀន លោក ផេង ពង្សរ៉ាស៊ី ប្រាប់ពីពាក្យគន្លឹះទាក់ទងនឹងប្រវត្តិសាស្ត្រដល់សិស្សានុសិស្ស ដើម្បីទទួលបានជោគជ័យក្នុងសម័យប្រឡងបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិនាពេលខាងមុខ។

បន្ទាប់មក សិស្សដែលបានចូលរួមវេទិកាថ្នាក់រៀនបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ **ប៊ុន សុគន្ធ** ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ភ្នំជីសូរ។ បន្ទាប់ពីខ្ញុំចូលរួមវេទិកាថ្នាក់រៀនរួចមក ខ្ញុំមានអារម្មណ៍សប្បាយរីករាយព្រោះខ្ញុំមានឱកាសទទួលបានចំណេះដឹងថ្មីៗដែលមិនធ្លាប់ទទួលបានដឹងពីមុន។ ខ្ញុំយល់កាន់តែច្បាស់ពីប្រវត្តិសាស្ត្រខ្មែរក្រហម។ វេទិកាថ្នាក់រៀននេះពិតជាមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ការប្រឡងបាក់ឌុបនាពេលខាងមុខ។ មួយវិញទៀត យុវជនជំនាន់ក្រោយគួរតែចងចាំពីប្រវត្តិសាស្ត្ររបស់ជាតិ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរយ៉ាងខ្លាំងដល់លោកយាយលោកតាដែលឆ្លងកាត់ និងស្លាប់ក្នុងរបបខ្មែរក្រហម។

ខ្ញុំឈ្មោះ **គុង នីតា** ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនភ្នំជីសូរ។ វេទិកាថ្នាក់រៀននេះ ធ្វើឱ្យខ្ញុំទទួលបានចំណេះដឹងជាងមុនទាក់ទងនឹងប្រវត្តិសាស្ត្ររបបខ្មែរក្រហមដែលប្រើឱ្យប្រជាជនធ្វើការងារហួសកម្លាំង និងរស់នៅក្រោមការគៀបសង្កត់។ ខ្ញុំបានដឹងតាមរយៈលោកតា ដែលឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ ខ្ញុំនៅចាំបានខ្លះៗពេលលោកតានិយាយប្រាប់ខ្ញុំថា ខ្មែរក្រហមបានជម្លៀសគាត់ចេញពីទីក្រុងភ្នំពេញបង្ខំគាត់ឱ្យធ្វើការងារហួសកម្លាំង។ ពេលនោះ យាយខ្ញុំ និងបងប្អូនរបស់លោកតាខ្ញុំ ត្រូវស្លាប់ក្នុងរបបខ្មែរក្រហម។ ដើម្បីទប់ស្កាត់របបខ្មែរក្រហម ខ្ញុំគិតថាគួរតែបណ្តុះបណ្តាលធនធានមនុស្សឱ្យបានច្រើន ហើយយុវជនទាំងអស់ត្រូវខិតខំសិក្សារៀនសូត្រឱ្យបានចេះដឹង។ យើងត្រូវលុបបំបាត់អំពើហិង្សា និងអសន្តិសុខក្នុងសង្គម។

ខ្ញុំឈ្មោះ **ចក់ ប៊ុនថុង** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ភ្នំជីសូរ។ ខ្ញុំទទួលបានចំណេះដឹងអំពីការកើតឡើងនៃរបបខ្មែរក្រហម និងការសម្លាប់ប្រជាជន ការធ្វើទារុណកម្ម ការបង្ខំឱ្យធ្វើការងារហួសកម្លាំង និងការបំបិទសិទ្ធិសេរីភាពក្នុងការរស់នៅក្នុងរបបខ្មែរក្រហម។ នៅក្នុងរបបខ្មែរក្រហម កុមារមិនទទួលបានការអប់រំ ព្រោះមិនមានសាលារៀន ចំណែកវត្តអារាម និងមន្ទីរពេទ្យត្រូវបានបំផ្លាញស្ទើរទាំងអស់។ ខ្មែរក្រហមបង្ខំឱ្យប្រជាជន និងក្មេងៗធ្វើការងារហួសកម្លាំង។ សម្រាប់ខ្ញុំដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឱ្យកើតឡើងម្តងទៀត យើងត្រូវផ្សព្វផ្សាយអំពីផលប៉ះពាល់នៃសង្គ្រាមដើម្បីឱ្យប្រជាជនបានដឹង។

ខ្ញុំឈ្មោះ **សែត ចាន់ដារ៉ា** ភេទប្រុស អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ភ្នំដីសូរ។ ការចូលរួមវេទិកាថ្នាក់រៀន ធ្វើឱ្យខ្ញុំយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ការចូលរួមវេទិកាថ្នាក់រៀនពិតជាមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ខ្ញុំ និងមិត្តភក្តិផ្សេងទៀត ដើម្បីបានយល់ដឹងពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាបានកាន់តែច្បាស់។ ខ្ញុំចង់ឱ្យមានវេទិកាថ្នាក់រៀន ឬសកម្មភាពបែបនេះនៅលើកក្រោយៗទៀត ដើម្បីបង្ហាញឱ្យយុវជនជំនាន់ក្រោយយល់ដឹងពីប្រវត្តិសាស្ត្រក្នុងប្រទេសកម្ពុជាបានកាន់ទូលំទូលាយជាងមុន។

ខ្ញុំឈ្មោះ **ធេព សីហា** ភេទប្រុស អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ភ្នំដីសូរ។ ពីមុនខ្ញុំមិនសូវជាចាប់អារម្មណ៍ប្រវត្តិសាស្ត្រប៉ុន្មានទេ ពេលដែលរៀនប្រវត្តិសាស្ត្រដែលស្មុគស្មាញច្រើន ប៉ុន្តែពេលខ្ញុំមកទីនេះ និងបានរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមធ្វើឱ្យខ្ញុំចាប់ចិត្តរៀនបន្ត។ យើងត្រូវតែយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីទទួលបានចំណេះដឹង។

ខ្ញុំឈ្មោះ **ស្រៀន ចាន់នីត** ភេទប្រុស អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ភ្នំដីសូរ។ ក្រោយពេលខ្ញុំបានចូលរួមវេទិកាថ្នាក់រៀន ធ្វើឱ្យខ្ញុំបានដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលមានភាពជូរចត់យ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំមិនចង់ឱ្យរបបខ្មែរក្រហមនេះកើតឡើងម្តងទៀតទេ ព្រោះរបបនេះបានធ្វើបាបប្រជាជន។



សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ភ្នំដីសូរ ទស្សនកិច្ចសិក្សានៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកា ថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សវិទ្យាល័យស្រែណូយ

**សួត វិចិត្រ**



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដល់សិស្សមកពីវិទ្យាល័យ ស្រែណូយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដោយផ្តោតលើប្រធានបទ «ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម» ដល់សិស្សចំនួន២៥នាក់ មកពីវិទ្យាល័យស្រែណូយ។

វេទិកាថ្នាក់រៀននេះមានគោលបំណងលើកកម្ពស់ការយល់ដឹងដល់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត តាមរយៈការមិនគាំទ្រអំពើហិង្សា ការមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជនជាតិ ជាតិពន្ធ និងនិន្នាការនយោបាយ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានតួនាទីរំឭក និងចងក្រងឯកសារប្រវត្តិសាស្ត្រខ្មែរក្រហម។ រយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើកិច្ចការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធដល់យុវជនក្នុងស្រុកអន្លង់វែង នៃខេត្តឧត្តរមានជ័យ អំពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មនានាដែលកើតឡើងក្នុងខ្មែររបបក្រហម។

នៅក្នុងឱកាសនោះ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញលើប្រធានបទ «ជីវភាពរស់នៅប្រចាំថ្ងៃក្នុងរបប

កម្ពុជាប្រជាធិបតេយ្យ»។ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម ត្រូវបានរំលេចតាមរយៈរឿងរ៉ាវតូចៗរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងបរិបទសង្គមមួយដ៏តក់ស្លុត និងនឹកស្មានមិនដល់។ នៅចន្លោញឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ តំបន់រំដោះខ្មែរក្រហមមួយចំនួនត្រូវបានរៀបចំឱ្យមាន «ក្រុមប្រវាស់ដៃ» ដែលជាក្រុមឈានទៅរកការលុបបំបាត់វណ្ណៈ កម្មសិទ្ធិឯកជន និងការរស់នៅបែបសមូហភាពដែលខ្មែរក្រហមគ្រោងទុកក្នុងរយៈពេលដ៏ខ្លី។ ក្រុមនេះមានសមាជិកចន្លោះពី១០ទៅ៣០គ្រួសារ ដោយផ្តោតសំខាន់ទៅលើការបង្កបង្កើនផល។ ក្រុមប្រវាស់ដៃត្រូវបានវិវត្តន៍ទៅជាសហករណ៍កម្រិតទាប និងសហករណ៍កម្រិតខ្ពស់រវាងពីឆ្នាំ១៩៧៣ រហូតក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្តរហូតដល់ឆ្នាំ១៩៧៧។ សហករណ៍កម្រិតទាប មានសមាជិកចន្លោះពី៣០០ ទៅ៤០០គ្រួសារ ឬភូមិទាំងមូល។ ចំណែកឯសហករណ៍កម្រិតខ្ពស់ មានសមាជិករហូតដល់១ពាន់គ្រួសារ ឬឃុំទាំងមូល។ អំឡុងពេលនោះ ប្រជាជនរស់នៅរងទុក្ខវេទនា និងស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់។ សាលាក្តីខ្មែរក្រហមបានរកឃើញថាខ្មែរក្រហមបានបង្ខំមនុស្សឱ្យធ្វើការងាររហូសកម្លាំង ការរៀបការដោយបង្ខំ ការរំលោភសិទ្ធិ និងពលកម្មកុមារ ការហូបចុកមិនគ្រប់គ្រាន់ ការសម្លាប់រង្គាលទៅលើក្រុមគោលដៅជាក់លាក់ ជនជាតិចាម ជនជាតិវៀតណាម អ្នកកាន់ព្រះពុទ្ធសាសនា និងអតីតមន្ត្រីរដ្ឋការ លន់ នល់។ ការធ្វើឱ្យមនុស្សទៅជាទាសករ ការនិរទេស ឬផ្លាស់ប្តូរទីលំនៅដោយបង្ខំ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញក្រោមហេតុផលនយោបាយ សាសនា និងពូជសាសន៍ និងការប្រព្រឹត្តអំពើអមនុស្សធម៌ដទៃទៀតប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

ស្ត្រីម្នាក់មានអាយុជាង៧០ឆ្នាំ នៅក្នុងស្រុកអន្លង់វែង បានបង្ហាញពីអារម្មណ៍ពិតរបស់ខ្លួនថា «គ្មានអ្នកណាស្អប់ខ្មែរក្រហមជាងខ្ញុំទៀតនោះទេ។ ខ្ញុំមិនធ្លាប់និយាយពាក្យនេះទៅកាន់នរណាម្នាក់ទេ។ ក្រុមគ្រួសាររបស់ខ្ញុំទទួលរងទុក្ខវេទនា និងស្លាប់នៅក្នុងជំនាន់ខ្មែរក្រហម»។ បទបង្ហាញក៏បានជម្រាបភ្ជាប់ទៅនឹងទិដ្ឋភាពផ្លូវច្បាប់លើកេរដំណែលសាលាក្តីខ្មែរក្រហមទៅលើឧក្រិដ្ឋកម្មធំៗដែលកើតមាននៅក្នុងរបបខ្មែរក្រហម ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការរំលោភបំពានយ៉ាងធ្ងន់



សិស្សវិទ្យាល័យ ស្រែណូយ ទស្សនកិច្ចសិក្សានៅសារមន្ទីរផ្ទះ តាម៉ុក ក្នុងស្រុកអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លើសន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងក្នុងសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនទៀត នៅក្នុងពេលសវនការជាង១ទសវត្សរ៍ (២០០៧-២០២២)។ សាលាក្តីខ្មែរក្រហមបានប្រើប្រាស់ប្រព័ន្ធច្បាប់ចំនួន២ គឺច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិ។ ទីតាំងវាលពិឃាតចំនួន៣៩០កន្លែង ស្មើនឹង១៩០០០រណ្តៅ, គុកចំនួន១៩៧កន្លែង និងបូជនីយស្ថានសាងសង់ឡើងក្រោយរបបខ្មែរក្រហមត្រូវបានរកឃើញ និងគូរផែនទីដោយមជ្ឈ-មណ្ឌលឯកសារកម្ពុជា។ ក្នុងនោះគុកទួលស្លែង គឺជាទីតាំងឧក្រិដ្ឋដ៏ឃោរឃៅបំផុតរបស់ខ្មែរក្រហមដែលបានធ្វើទារុណកម្មអ្នកទោសយ៉ាងព្រៃផ្សៃ។ ការិយាល័យសហព្រះរាជអាជ្ញានៃសាលាក្តីខ្មែរក្រហមបានឱ្យដឹងកាលពីឆ្នាំ២០២០ ថា អ្នកទោសប្រមាណ១៨,០៦៣នាក់ បានឆ្លងកាត់ការធ្វើទារុណកម្មនៅ ទីនេះ។

នៅផ្នែកបន្ទាប់ សិស្សបានទស្សនាភាពយន្តឯកសារ «ខ្មែរបាត់បង់តន្ត្រីរ៉ក់»។ ខ្សែភាពយន្តនេះផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយចំណាយពេលវេលាជាង១០ឆ្នាំ ដើម្បីបង្ហាញអំពីដួងព្រលឹងសិល្បៈខ្មែរមិនចេះសាបសូន្យទោះស្ថិតក្នុងសម័យកាលណាក៏ដោយ។ នៅផ្នែកចុងក្រោយនៃវេទិកាថ្នាក់រៀនសិស្សរៀនពីវិធីសាស្រ្តទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។ នៅក្នុងផ្នែកនេះក៏រួមបញ្ចូលនូវការស្ទាបស្ទង់ចំណេះដឹងក្រោយវេទិកា និងចែករបាយការណ៍ស្តីពីស្រ្តីនៅក្នុងស្រុកអន្លង់វែង និងទស្សនាវដ្តីស្វែងរកការពិត (លេខពិសេស) ទៅកាន់សិស្សម្នាក់ៗសិក្សាបន្ថែម។

បន្ទាប់មក សិស្សានុសិស្សដែលចូលរួមលើវេទិកាថ្នាក់រៀននេះ ឡើងបង្ហាញចំណាប់អារម្មណ៍ ដូចខាងក្រោម៖

១) ខ្ញុំឈ្មោះ **ច្រឹក ចាន់នី** ភេទស្រី អាយុ១៨ឆ្នាំ។ ខ្ញុំពិតជារំភើបដែលបានចូលរួមវេទិកាថ្នាក់រៀនពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំបានដឹងពីប្រវត្តិសាស្រ្តរបស់ខ្មែរ និងបានដឹងពីការរស់នៅរបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម ក៏ដូចជាដឹងអំពីទីតាំងផ្ទះរបស់ តាម៉ុក។ បន្ថែមពីនេះ ខ្ញុំបានដឹងអំពីទុក្ខលំបាកប្រជាជនខ្មែរនៅក្នុងរបប៣ឆ្នាំ ការរស់នៅក្នុងសហករណ៍ ការហូបរួម ការធ្វើការងាររួម និងមិនមានទ្រព្យសម្បត្តិឯកជន។ ចំពោះការចាក់បញ្ចាំងភាពយន្ត«ខ្មែរបាត់បង់តន្ត្រីរ៉ក់» ខ្ញុំចាប់អារម្មណ៍ទៅលើក្រុមតន្ត្រីករកាលពីជំនាន់សង្គមរាស្ត្រនិយមដែលមានភាពល្បីល្បាញ សំនៀងពិរោះរណ្តំ ធ្វើឱ្យអ្នកស្តាប់ទាំងក្មេង ទាំងចាស់ មានភាពសប្បាយរីករាយ។ ជាពិសេស លោក ស៊ីន ស៊ីសាមុត និង អ្នកនាង រស់ សេរីសុទ្ធា ដែលមានសំឡេងទឹកដមពីរោះល្បីរន្ទឺក្នុងនិងក្រៅប្រទេស។ ដើម្បីទប់ស្កាត់កុំឱ្យរបបផ្តាច់ការខ្មែរក្រហមកើតឡើងម្តងទៀត ក្នុងនាមខ្ញុំជាសិស្សត្រូវខិតខំប្រឹងប្រែងរៀនសូត្រដើម្បីឱ្យក្លាយទៅជាយុវជនល្អ និងជួយអភិវឌ្ឍន៍ប្រទេសជាតិ។



សិស្សវិទ្យាល័យ ស្រែណូយ ទស្សនកិច្ចសិក្សា នៅសារមន្ទីរផ្ទះ តាម៉ុក ក្នុងស្រុកអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

២) ខ្ញុំឈ្មោះ **សឿន ស៊ីវនត** ភេទស្រី អាយុ១៩ឆ្នាំ។ ខ្ញុំពិតជាសប្បាយចិត្តណាស់នៅពេលបានចូលរួមវេទិកាថ្នាក់រៀននេះ ដោយសារពីមុនខ្ញុំតែងតែឃើញសិស្សច្បងបានចូលរួមជាមួយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំមិនធ្លាប់មានឱកាសចូលរួមសិក្សារៀនសូត្រអំពីប្រវត្តិរបស់ខ្មែរក្រហមទេ។ ការបង្រៀនអំពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) ខ្ញុំចាប់អារម្មណ៍ទៅលើរបៀបរបបរស់នៅរបស់ប្រជាជនខ្មែរ និងការ

ដឹកនាំដោយរបបកុម្មុយនីស្ត។ ពីមុនមកខ្ញុំធ្លាប់តែឮឪពុកម្តាយ ជីដូនជីតារបស់ខ្ញុំនិយាយប្រាប់ពីទុក្ខលំបាករបស់គាត់ក្នុងរបបខ្មែរក្រហម ប៉ុន្តែនៅថ្ងៃនេះខ្ញុំបានសិក្សាពីប្រវត្តិសាស្ត្របន្ថែម រួមទាំងបានឃើញទិដ្ឋភាពនៃការរស់នៅក្នុងរបបខ្មែរក្រហមតាមរយៈវីដេអូ «ខ្មែរបាត់បង់តន្ត្រីរ៉ក់»។ ខ្ញុំពិតជាមានការតក់ស្លុត និងអាណិតទៅដល់ប្រជាជនដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។

៣) ខ្ញុំឈ្មោះ **អឿន ណារ៉ូម៉ី** ភេទស្រី អាយុ ១៨ឆ្នាំ។ ខ្ញុំយល់ឃើញថាការរៀនប្រវត្តិសាស្ត្រពិតជាល្អ ដែលអាចឱ្យយើងមើលឃើញទិដ្ឋភាពនៃសម័យកាលមុនៗ។ ក្នុងនាមខ្ញុំជាយុវជន ដើម្បីកុំឱ្យរបបខ្មែរក្រហមវិលត្រ ឡប់មកវិញ ខ្ញុំត្រូវខិតខំសិក្សារៀនសូត្រ និងជួយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។ ខ្ញុំសំណូមពរឱ្យកូនខ្មែរជំនាន់ក្រោយបានរៀនពីប្រវត្តិសាស្ត្រឱ្យបានច្រើន មានការថែរក្សាវប្បធម៌ និងសម្បត្តិសិល្បៈដែលខ្មែរជំនាន់មុនបានរក្សាទុក។

៤) ខ្ញុំឈ្មោះ **វើ ចំរើន** ភេទប្រុស អាយុ១៨ឆ្នាំ។ សម្រាប់វេទិកាសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងថ្ងៃនេះ បានធ្វើឱ្យខ្ញុំ និងមិត្តភក្តិជាច្រើននាក់ទៀតទទួលបានឱកាសដើម្បីរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរ។ ខ្ញុំចាប់អារម្មណ៍ទៅលើរបបកម្ពុជាប្រជាធិប-តេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ដោយសាររបបនេះបានបង្ហាញឱ្យយើងឃើញពីអំពើសាហាវឃោរឃៅ និងការឈឺចាប់របស់ប្រជាជនពីសំណាក់ខ្មែរក្រហម។ ខ្មែរក្រហមបានបង្ខំឱ្យប្រជាជនធ្វើអ្វីដែលមិនចង់ធ្វើ ជាពិសេស គឺការបំបិទសិទ្ធិ និងសេរីភាព។ ខ្ញុំពិតជាសង្វេគពេលបានយល់ដឹងប្រវត្តិ-សាស្ត្របែបនេះ ដោយសារតែពីមុនមកខ្មែរធ្លាប់តែមានប្រវត្តិសាស្ត្រថ្កុំថ្កើង។ ខ្ញុំសរសើរអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលខិតខំស៊ូរស់មកដល់បច្ចុប្បន្ន។ ក្នុងនាមខ្ញុំជាយុវជនដើម្បីទប់ស្កាត់របបខ្មែរក្រហមកុំឱ្យវិលត្រឡប់មកវិញ គឺខ្ញុំផ្សព្វផ្សាយប្រវត្តិសាស្ត្រនេះទៅកាន់មនុស្សជុំវិញខ្លួន។

៥) ខ្ញុំឈ្មោះ រិទ្ធ សុវណ្ណារដ្ឋ ភេទស្រី អាយុ ១៦ឆ្នាំ។ ខ្ញុំយល់ថា ការចូលរួមក្នុងវេទិកាថ្នាក់រៀនធ្វើឱ្យខ្ញុំបានដឹងពីប្រវត្តិសាស្ត្ររបស់ខ្មែរច្រើន និងច្បាស់លាស់ជាងមុន។ ខ្ញុំចាប់អារម្មណ៍ខ្លាំងទៅលើក្រុមសិល្បៈខ្មែរនៅជំនាន់សង្គមរាស្ត្រនិយម ពីព្រោះខ្ញុំមើលឃើញពីភាពអស្ចារ្យ និងទេពកោសល្យនៃការច្រៀងរបស់គាត់ដែលមានភាពទាក់ទាញអ្នកស្តាប់។



សិស្សវិទ្យាល័យ ស្រែណូយ ចូលរួមវេទិកាអប់រំស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យព័ត៌មានសាធារណៈ









«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!










# ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)

ហង្ស ឆាំឆាន

នឹងព្រឹត្តិការណ៍ចាប់ខ្លួនប្រជាជន និងអ្នកទោសទៅសម្លាប់ជាច្រើនតាំងពីក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកជាពិសេសថ្មីៗដែលសន្តិសុខផ្ទះមេស្រុកស្ទួងចាប់អ្នក ១៧ មេសា ទៅកម្ទេចចោលកាលពីឆ្នាំទៅ។ អង្គមីទ្ទីញចាប់ផ្តើម ការហៅឈ្មោះម្នាក់ម្តងៗ ឡើងក្រោកឈរបង្ហាញមុខប្រធានសន្តិសុខបានប្រកាសរបៀបវារៈ មីទ្ទីញមាន ៨ ខគឺទី១ ប្រកាសហេតុ ទី២ ប្រកាសគណៈអធិបតី ទី៣ របាយការណ៍ប្រធានសន្តិសុខស្រុក ទី៤ ការហៅឈ្មោះអ្នកត្រូវលើកលែងទោស ទី៥ មតិណែនាំរបស់សមមិត្តប្រធានគណៈស្រុកកោះដ័យ ទី៦ ការចាប់អារម្មណ៍របស់តំណាងអ្នកត្រូវដោះលែង ទី៧ ប្រកាសរំសាយ ទី៨ ការចាត់តាំងកម្លាំងជូនអ្នកដោះលែងទៅតាមមូលដ្ឋាន។ មីទ្ទីញចាប់ផ្តើមប្រកាសហេតុគឺ ហេតុដែលនាំឲ្យមានអង្គមីទ្ទីញថ្ងៃនេះគឺអង្គការមានមនោសញ្ចេតនាលើកលែងទោសពិរុទ្ធជន ៣២នាក់ឲ្យត្រឡប់ទៅជួបជុំគ្រួសារវិញអ្នកទាំងនោះកំពុងមានវត្តមាននៅទីនេះស្រាប់។

### ៤.២៥. ការដោះលែងឲ្យជួយហៅអ្នកទៅជាមួយ សោ ភឹម មកវិញ

បន្ទាប់ពីរបាយការណ៍ប្រធានសន្តិសុខមក សមមិត្តប្រធានគណៈស្រុកមានមតិណែនាំថា តើបងប្អូនដឹងទេថាតើហេតុអ្វី បានជាអង្គការលើកលែងទោសបងប្អូនឲ្យរួចថ្ងៃនេះ? មូលហេតុគឺមានបងប្អូនមួយចំនួនវង្វេងផ្លូវរត់ចេញពីសង្គមជាតិដ៏ល្អបរិសុទ្ធទៅចូលខ្មាំងមកបំផ្លាញជាតិឯងដូចជាឈ្មោះ សោ ភឹម និងបក្ខពួកជាច្រើនដូច្នេះ ក្រោយពេលអង្គការដោះលែងហើយបើបងប្អូនណាមានសាច់ញាតិដែលរត់ទៅតាមពួកនោះសូមអំពាវនាវឲ្យគាត់មកវិញ អង្គការមិនយកទោសពៃអ៊ីទេ។ មីទ្ទីញចប់អង្គការប្រគល់លិខិតដោះលែងម្នាក់មួយៗ ដើម្បីយកទៅឲ្យប្រធានសហ-ករណ៍ ក្រុមយើងខ្ញុំមានគ្នា៥នាក់ ជូនដំណើរដោយមិត្ត អុល ជាសន្តិសុខប្រចាំគុកទួលស្វែងសំរិត ពេលត្រឡប់មកផ្ទះវិញពុំមានទូកជូនដំណើរឲ្យតោងដូចពេលទៅទេ ពួកយើងត្រូវម្ចាស់ការខ្លួនឯង ហែលទឹកដោយតោងបណ្តែតជាមួយកេះ គ្រាប់កាំភ្លើងនៅកន្លែងជ្រៅ ដើរទៅមិនរួចៗ ម៉ោង១០យប់ ខ្ញុំបានទៅដល់ផ្ទះលោកមានគុណទាំងពីរ និងបងប្អូនជាច្រើនរង់ចាំនៅផ្ទះ ព្រោះពីម្សិលមិញលោកឪពុកបាត់ខ្ញុំយូរពេក គាត់ក៏បានអុំទូកធ្វើជាទៅរកក្របី ទៅរកមើលខ្ញុំនៅ ហ្វូងក្របីគេប្រាប់ត័ត៌មាននេះ។

### ៤.២៦. ភារកិច្ចថ្មីនៅពេលទៅដល់ភូមិកំណើត

ព្រឹកឡើងខ្ញុំបានយកសំបុត្រដោះលែងទៅជូនមិត្ត ដៃ ប្រធានសហករណ៍បឹងដោល និងទទួលការណែនាំ។ បងដៃ ជាបងជីដូនមួយខាង



ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃ។ (ហង្ស ឆាំឆាន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្តាយខ្ញុំគាត់អរណាស់ពេលឃើញខ្ញុំបានមកវិញព្រោះពេលគេចាប់ខ្ញុំដាក់គាត់មិនទាន់មានតួនាទីក្នុងជួរសង្កាត់ទេ។ មិត្ត ដៃ ទទួលសំបុត្រហើយមិននិយាយអ្វីទេ។ តែមិត្ត ម៉េង និយាយថា ឆាន ឯងឈប់គិតថានឹងវិលត្រឡប់ទៅរកប្រពន្ធវិញ ប្រយ័ត្នគ្រោះថ្នាក់ណា។ រយៈពេល៣ថ្ងៃក្រោយមក អនុប្រធានក្រុម គឺមិត្ត គី មកប្រាប់ឲ្យទៅសែងខ្មោច និង អ្នករបួសនៅភូមិព្រៃរុន។ ស្ថិតនៅចម្ងាយ៣គីឡូម៉ែត្រពីផ្ទះខ្ញុំ គឺសពនិងអ្នករបួសយុទ្ធជនមកពីសមរភូមិព្រំដែនយកទៅព្យាបាលនៅពេទ្យកំពង់ត្របែក និងបញ្ចុះនៅវិមានសាកសពព្រែកប្បាស។ ខ្ញុំវេចបង្វិចទៅដេកចាំជាមួយអ្នកផ្សេងទៀតដែលខ្ញុំមិនធ្លាប់ស្គាល់

ចាំរយៈពេល២យប់ដំបូងមិនមានអ្វីទេ ដល់យប់ទី៣ មានសព២នាក់មកដល់ យប់ទី៤សពមក៣នាក់ទៀត និងយប់ទី៦ ម្ដងនេះមានដល់ទៅ៥នាក់ ក៏ដល់ពេលដូរវេនខ្ញុំមានអ្នកថ្មីមកជំនួសខ្ញុំត្រូវទៅផ្ទះវិញ។ រយៈពេល៣ថ្ងៃក្រោយមមិត្តម៉េងបានមកប្រាប់ឲ្យទៅលីស្រូវពូជ នៅស្ពានកំពង់ត្របែករយៈពេល១០ថ្ងៃ ត្រូវចែវទូកទៅលីស្រូវពីឃ្លាំងដាក់ទូក និងចែវមកដាក់នៅសហករណ៍មួយថ្ងៃទៅមួយថ្ងៃមក។ ការងារអស់ទាំងនេះ ទោះបីធ្ងន់ធ្ងរលំបាកយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចធ្វើបានទាំងអស់ ខ្ញុំទ្រាំ ខ្ញុំអត់ធ្មត់គ្រប់ពេលវេលាទោះបីជាមានពាក្យសំដី ឬ អំពើណាមួយដែលអ្នកខ្លះបានធ្វើ និងមើលងាយខ្ញុំ និងក្រុមគ្រួសារក៏ដោយ ធ្វើយ៉ាងណាឲ្យតែខ្លួនបានសុខនិងរស់ជាមួយក្រុមគ្រួសារ។

## ៤.២៧. ក្រុមគ្រួសារខ្ញុំត្រូវនិរទេសទៅដីខ្លាញ់

ការងារដឹកជញ្ជូនស្រូវពូជបានប្រព្រឹត្តទៅជាធម្មតារហូតដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ក្រុមគ្រួសារខ្ញុំបានទទួលដំណឹងដ៏សែនរន្ធត់មួយគឺត្រូវទៅនៅដីខ្លាញ់តំបន់២៤។ ខ្ញុំឆ្ងល់ថា តើគ្រួសារខ្ញុំមានកំហុសអ្វី? បានជាសុខៗឲ្យក្រុមគ្រួសារខ្ញុំចុះចេញពីផ្ទះទ្រនំខ្ពស់ដែលយើងខំរកស៊ី និងរស់នៅរាប់សិបឆ្នាំ ហើយនិងឲ្យយើងខ្ញុំទៅនៅកន្លែងថ្មីដែលយើងខ្ញុំមិនដែលស្គាល់សោះ? នេះមិនខុសពីរឿងព្រេងដែលគេនិយាយថានិរទេសនោះទេ។ ពួកកម្មាភិបាលខ្មែរក្រហមបានហៅក្រុមគ្រួសារអ្នកដែលត្រូវនិរទេសទៅប្រជុំនិងខំពន្យល់ជាច្រើនដងថា «មូលហេតុដែលអង្គការបញ្ជូនបងប្អូនទៅនៅដីខ្លាញ់ព្រោះកន្លែងនោះសម្បូរដោយភោគផលដំណាំជាងកន្លែងយើងរស់នៅសព្វថ្ងៃនេះ»។ យើងនាំគ្នាពិចារណាថា បើដីនោះខ្លាញ់មែនគួរណាតែឲ្យក្រុមគ្រួសារកម្មាភិបាលដែលបានតស៊ូរំដោះជាតិ ហេតុអ្វីឲ្យពួកយើងទៅ? អ្នកដែលត្រូវទៅភាគច្រើនជាប្រជាជនថ្មី និងអ្នកដែលមានវិបត្តដូចជាខ្ញុំកន្លងមក។

## ៤.២៨. ការរង់ចាំពេលចេញដំណើរទៅដីខ្លាញ់

ក្រោយពីការហៅប្រជុំជាច្រើនលើកឲ្យយើងត្រៀមខ្លួន រហូតដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧ ទើបគេដើរប្រមូលឲ្យយើងចេញដំណើរអ្នកណាមានឈ្មោះហើយមិនទៅគឺត្រូវមានទោស។ ម៉ោង១២ថ្ងៃត្រង់ ពួកយើងចាកចេញពីផ្ទះកំណើតម្នាក់ៗទឹកភ្នែករហាម និងមិនសង្ឃឹមថាមានវាសនាមកទីនេះទៀតទេ។ ល្ងាចម៉ោង៤÷០០ ពួកយើងធ្វើដំណើរដល់ភូមិស្នាយបាក់ សង្កាត់សេនារាជឧត្ដម ចម្ងាយជាង១០គីឡូម៉ែត្រ ខាងជើងផ្ទះកំណើត។ ក្រុមយើងមាន២គ្រួសារ គឺក្រុមគ្រួសារខ្ញុំ១១នាក់ និងគ្រួសារជន្ទងលោកឪពុក២០នាក់ រួមទាំងកូនខ្ចី ត្រូវដេកហាលសន្សើមមួយយប់ជាមួយគ្នា ព្រឹកឡើងទើបបន្តដំណើរទៅដល់អ្នកលឿងម៉ោង៣ល្ងាច ត្រូវរង់ចាំចុះកប៉ាល់នៅក្បាលសាឡាងអ្នកលឿង៤ថ្ងៃ។

## ៤.២៩. ខ្ញុំសម្រេចចិត្តទៅជួបជុំប្រពន្ធវិញ

មកដល់អ្នកលឿងល្ងាច ឃើញគេចាប់ដង្រំផ្គុំកូនស្រី ប្រុសជាច្រើនគូមុនចុះកប៉ាល់។ លោកឪពុកមើលមកខ្ញុំ ទាំងទឹកមុខស្រងូតស្រងាត់អាណិតដល់ខ្ញុំ និងជន្ទងគាត់ក៏នាំគ្នាជាច្រើនមកនិយាយថា «ទៅនៅជាមួយប្រពន្ធវិញទៅកូន ខ្ញុំឆ្លើយថា ប្ដីប្រពន្ធខ្ញុំស្រឡាញ់គ្នាណាស់ ឪពុកម្ដាយក្មេកក៏ពេញចិត្តខ្ញុំដែរ តែខ្ញុំមិនអាចទៅ គឺខ្ញុំខ្លាចគេសម្លាប់ ខ្ញុំរាងហើយនៅក្នុងគុកជិត២ឆ្នាំនេះ» និយាយបានប៉ុណ្ណឹង ខ្ញុំចូលទៅដេកបាត់ទៅ ដោយមិនមានគិតពីរឿងប្រពន្ធកូនអីទៀតទេ។ ព្រឹកឡើងលោកពូ សំ អ៊ុំពៅ ប្រធានគណៈកម្មាធិការបញ្ជូនប្រជាជនទៅដីខ្លាញ់មកឃើញយើងខ្ញុំ ក៏សួរឪពុកខ្ញុំថា ឯណាលោកក្មួយ ឆានមកទេ? លោកឪពុកអរណាស់ក៏ប្រាប់ថា លោកកូនមកទៅជាមួយខ្ញុំដែរ។ ខ្ញុំពុំដែលស្គាល់គាត់ទេ ឮមាត់ដូច្នេះ ក៏ក្រោកឈរបង្ហាញមុខដល់ដឹងថា លោកពូពៅ ក៏សំពះសួរគួរសមនឹងអរគុណគាត់ដែលបានជួយសង្គ្រោះជីវិតខ្ញុំ លោកពូក៏សួរថា លោកក្មួយទៅតាមលោកបងដែរ? ខ្ញុំឆ្លើយថា បាទលោកពូ ចុះប្រពន្ធគិតយ៉ាងម៉េចក្មួយឯងមិនអាណិតគ្នាទេឬ? ខ្ញុំបន្តថាអាណិតណាស់ពូ តែខ្ញុំកង្វល់ថា តើទៅដោយវិធីណា? បើអញ្ចឹងកុំព្រួយក្មួយ ពូធ្វើលិខិតឲ្យ ហើយទៅជួបប្រពន្ធនៅរួមសុខទុក្ខជាមួយគ្នារហូតទៅក្មួយ អាណិតគ្នា ពិសេសម៉ែក្មេកមេម៉ាយ ពូនៅតែតាមមើលក្មួយរហូត។ លោកឪពុកអ្នកម្ដាយធំ បងប្អូនខ្ញុំអរណាស់ ក៏ទៅជាមួយខ្ញុំយកសំបុត្រ និងចេញដំណើររួមទាំងបងប្អូនប្រុសខ្ញុំ៤នាក់ ទៅជួបពូជាប្រធានសង្កាត់រួមទៅជួបប្រពន្ធសម្លាញ់ ម៉ែក្មេក លោកឪពុក និងប្អូនក៏ត្រឡប់មកអ្នកលឿងវិញទាំងល្ងាចនោះ។

## ៤.៣០. ព័ត៌មាន២ដ៏ព្រឺព្រួចសម្រាប់ខ្ញុំ

ក្រោយបានជួបប្រពន្ធជាទីស្រឡាញ់ហើយ ប្រធានក្រុមភ្ជួរដីបានមកហៅខ្ញុំឲ្យរៀបខ្លួនភ្ជួរដីចម្ការ

រដូវប្រាំង នៅពេលកំពុងព្យួរហើយ ឆ្លៀតពេលសម្រាកមានអ្នកនិយាយខ្សឹបខ្សៀវថា ប្រជាជនដែលបញ្ជូនទៅតាមកប៉ាល់ទៅដីខ្មាញ់ទាំងប៉ុន្មាន គេពន្លិចកប៉ាល់សម្លាប់ចោល ទាំងអស់។ ឮដូច្នេះ ខ្ញុំសែនតក់ស្លុតរកអ្វីមកប្រៀបពុំបាន តែមិនជឿទាំងស្រុងទេ ព្រោះនេះគ្រាន់តែជាពាក្យចចាមអារ៉ាម។ ៥ថ្ងៃក្រោយមក ប្រពន្ធខ្ញុំក៏ត្រូវគេចាត់ឲ្យចល័តស្ទូងនៅបឹងបាត់ឪ បែកពីខ្ញុំរយៈពេលមួយមិនមានកំណត់។ ពេលប្រពន្ធទៅបាត់ ប្រធានសង្កាត់ថ្មី ពីនិរតីមកដូរលោកពូ ឡេ ឲ្យទៅជាកម្មាភិបាលស្រុកពាមជរ។ មនុស្សថ្មីដែលមកជាមួយប្រធានសង្កាត់ឫកពារសំដីរបស់គេហាក់ដូចជាសាហាវណាស់ គេបានដើរមើលតាមផ្ទះនិងសួររកអ្នកដែលធ្លាប់ជាប់គុកពីមុនមានប៉ុន្មាននាក់ និងគ្រោងឲ្យសរសេរប្រវត្តិរូបឡើងវិញរួចត្រូវហៅប្រជុំនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ ខាងមុខនេះ។ ដំណឹងនេះបានខ្សឹបខ្សៀវបន្តគ្នា ខ្លះសម្ងំមករកខ្ញុំហាក់ដូចជាដឹងរឿងអ្វីមួយ ឮដូច្នេះ ខ្ញុំពុំមានចាប់អារម្មណ៍ទេ ចេះតែខំធ្វើការនឹងគេទៅ និងចាំថ្ងៃដែលគេឲ្យសរសេរប្រវត្តិរូបថ្ងៃណា។ ការព្រួយបារម្ភរបស់ខ្ញុំជាប់ជាប្រចាំពីជីវិតដូចកាលខ្ញុំនៅក្នុងគុកដែរ ការភ្ជួរដីចម្ការនៅកន្លែងនេះមិនលំបាកមានដើមមន និងផ្សងព្រេងក្នុងវាលគ្រាប់មីនដូចនៅភូមិឧត្តមទេ នេះគឺជាភូមិឧត្តុង្គស្ថិតនៅខាងត្បូងជាប់ភូមិឧត្តម។ កំពុងតែព្រួយបារម្ភផងភ្ជួរផង ម៉ោង៨៖០០ ស្រាប់តែឮសូរយន្តហោះបានហោះមកពីលើពួកយើងបាចខិត្តប័ណ្ណ និងស្នូរកាំភ្លើងយន្តបាញ់ផ្ទួនៗពីចម្ងាយ ទន្ទឹមនោះក៏មានប្រជាជនរត់ចេញពីស្រុកកោះជ័យមកយ៉ាងច្រើនបន្តគ្នា។ ម៉ោង៩ព្រឹក យន្តហោះក៏ទម្លាក់គ្រាប់បែកនៅចំណុចកំពង់សីង និងស្ទឹងស្លូត ឃើញដូច្នេះមិត្ត យ៉ាន ប្រធានក្រុមមិនហ៊ាននិយាយអ្វីទេ ក៏បរនង្គ័លឡើងទៅផ្ទះយ៉ាងលឿនបាត់ទៅ ពួកយើងក៏មិនហ៊ានថាម៉េច ឡើងទៅផ្ទះដូចគេដែរ។ ឃើញខិត្តបណ្ណធ្លាក់ចូលព្រៃ ខ្ញុំក៏លួចយកមើលម្នាក់ឯងក្នុងព្រៃ ព្រោះអ្នកភ្ជួរទាំងអស់ខ្ញុំមិនដែលស្គាល់គេទេ តែគេស្គាល់ខ្ញុំ ម្ល៉ោះហើយត្រូវតែមានការប្រុងប្រយ័ត្នជានិច្ច មើលដឹងហើយពីគោលនយោបាយ៨ខ និង១១ខ របស់រណសិរ្សរួបរួមជាតិខ្មែរ ខ្ញុំក៏អរយ៉ាងរំភើប។ តែនៅនឹកមមៃទៅប្រពន្ធសម្លាញ់ដែលបែកគ្នានៅឯក្រុមចល័តបឹង បាត់ឪ តើយ៉ាងម៉េចទេ? ទៅដល់ផ្ទះម៉ែក្មេករៀបចំអីវ៉ាន់រួចជាស្រេច តាមអង្គការប្រាប់ឲ្យឆ្លងទន្លេកៀសខ្លួនទៅទិសខាងលិចជាមួយអង្គការ បើអ្នកណាមិនទៅគឺជាខ្មាំងយួន។

### ៤.៣១. ទ័ពខ្មែរក្រហមឆ្លងទន្លេនៅក្បែរផ្ទះខ្ញុំ

ការរង់ចាំប្រពន្ធរហូតដល់ម៉ោង៨៖០០យប់ ទើបជួបគ្នា ក៏នាំគ្នាប្រញាប់ប្រញាល់ឡើងលើទូកឆ្លងនឹងគេ។ នៅលើទូកកាណូតម៉ាស៊ីនចំណុះប្រហែលជា១០០តោន២គ្រឿង មានទាហានខ្មែរក្រហមរាប់រយនាក់កាន់កាំភ្លើងជាប់ខ្លួនឡើងជិះបានកន្លះទូកនីមួយៗ គេចាំចម្លងរហូតដល់ម៉ោង៩ គេបានដើរដេញប្រជាជនតាមផ្ទះ និងអ្នកដែលទើបនឹងមកពីស្រុកកោះជ័យឲ្យឡើងទូក។ ស្រាប់តែស្នូរផ្ទុះគ្រាប់នៅឃ្លាំងដាក់គ្រាប់របស់ខ្មែរក្រហម ភូមិព្រែកខ្សាយ ស្រុកពាមរក៍ ធ្វើឲ្យលាន់ញ័រដី និងភ្លឺជាងថ្ងៃមកលើកាណូត ពួកទ័ពក៏បញ្ឈប់ឲ្យកាណូតចេញ កាណូតមួយនោះចេញទីបាត់ ឯការណូតពួកខ្ញុំជិះបានកើលប្រាំងទន្លេមិនអាចថយបាន ពួកទាហានឃើញគ្រាប់ផ្ទុះខ្លាំងក៏លោតចុះពីកាណូតបែកផ្លូវគ្នាអស់ទៅ ឯក្រុមគ្រួសារយើងខ្ញុំក៏រត់ដូចគេដែរ តែរត់មកផ្ទះវិញបាត់អីវ៉ាន់នៅលើទូកទាំងអស់ ព្រោះប្រញាប់ផងភ័យផង។ ដល់ពេលទៀបភ្លឺ គេបានដើរចេញម្តងទៀត គ្រួសារខ្ញុំខ្លាចក៏ចុះទូកទៅតាមគេ រត់រហូតដល់វត្តស្វែង ស្រុកស្អាង ក៏ឮវិទ្យុប្រកាសថាបែកភ្នំពេញហើយ ទើបត្រឡប់មកផ្ទះវិញ។

### ៤.៣២. ខ្ញុំស្ទើរ ឡប់សតិដោយបាត់លោកអ្នកមានគុណនិងប្អូនៗ

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំត្រូវគេចាត់តាំងឲ្យធ្វើប្រធានភូមិឧត្តុង្គ និងបន្ទាប់មកជាអនុប្រធានឃុំព្រែកក្របៅ ស្រុកពាមជរ រហូតដល់ខែមេសា បានជួបបង ជាម យៀប មកពីវៀតណាម ៣នាក់គឺលោក ម៉ៅ វុឌ្ឍី និង លោក ប៉ូ សាវុធ ពួកគាត់នឹកស្មានថាខ្ញុំស្លាប់ក្នុងគុកបាត់ទៅហើយ ព្រោះពុំដែលមានអ្នកណាជាប់គុកហើយនៅរស់ទេពេលនោះ។ គាត់បានព័ត៌មានតាមរយៈឪពុកគាត់ ពេលខ្ញុំនាំប្រពន្ធខ្ញុំទៅសួរនាំពីកូនចៅគាត់ លោកអ៊ំឆ្លើយថាអស់រលីងហើយ ក្មួយអើយ៤៩នាក់ទាំងកូន ទាំងចៅ កូនយៀបក៏គ្មានដំណឹងដែរ។ បង ជាម យៀប លោក ម៉ៅ វុឌ្ឍី និង លោក ប៉ូ សាវុធ សុទ្ធតែមានឪពុកម្តាយប្រពន្ធកូនបងប្អូនទៅដីខ្មាញ់ទាំងអស់។ យើងទាំងអស់គ្នាទន្ទឹងរង់ចាំស្តាប់ព័ត៌មានជាច្រើនខែ។ ខ្ញុំបានព័ត៌មានមិនពិតជាច្រើនតាមពាក្យចចាមអារ៉ាមធ្វើឲ្យរូបខ្ញុំគិតច្រើនពេកទៅ ចង់ក្លាយទៅជាមនុស្សឡប់សតិ

(តនៅលេខក្រោយ)

រូបក្របមុខ ៖
រូបថតកងទ័ពខ្មែរក្រហមដែលបានហ្វឹកហាត់បើកយន្តហោះចម្បាំងចំនួន៣០នាក់ អ្នកបកប្រែភាសាខ្មែរ-ចិន គ្រូបង្រៀនជនជាតិចិន និងកម្មាភិបាលជនជាតិចិន ធ្វើដំណើរទស្សនកិច្ចនៅស្រុកតាចាយ ខេត្តហ៊ឺប៉ី ក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖
រូបថតកងទ័ពខ្មែរក្រហម ហ្វឹកហាត់បើកយន្តហោះចម្បាំងនិងគ្រូជនជាតិចិនឈរថតរូបនៅពីមុខសាលារៀន ទីក្រុងហ៊ូណាន ខេត្តហ៊ឺប៉ី ។ រូបថតនេះបានថតនៅអំឡុងខែតុលា ឆ្នាំ១៩៧៦ ក្នុងពេលកំពុងហ្វឹកហ្វឺនបើកយន្តហោះ (Shenyang J-5) បន្ទាប់ពីបានបញ្ចប់ការហ្វឹកហាត់បើកយន្តហោះវគ្គដំបូងស្រុកស៊ឺចាជួង ខេត្តហ៊ឺប៉ី។ រូបនេះបានថតរួមគ្នាមានចំនួន១២នាក់ រាប់ពីឆ្វេងទៅស្តាំ៖ ទី១) ឈ្មោះ ជា អ្នកបកប្រែជនជាតិខ្មែរ, ទី២) អ្នកបកប្រែជនជាតិចិន (មិនចាំឈ្មោះ), ទី៣) មិនចាំឈ្មោះ, ទី៤) ជនជាតិចិន (មិនចាំឈ្មោះ), ទី៥) ឈ្មោះ អ៊ឹម អនុប្រធានក្រុមអ្នកបើកបរយន្តហោះប្រដេញ, ទី៦) ឈ្មោះ ឡោ គួ (ជនជាតិចិន) ជាប្រធាននិងជាគ្រូបង្រៀនផ្នែកបើកបរយន្តហោះប្រដេញ, ទី៧) ឈ្មោះ ចិន បឿន, ទី៨) ឈ្មោះ អៀង វុធ (កូនប្រុសរបស់ អៀង សារី), ទី៩) ឈ្មោះ ឆែម ទី១០) ជនជាតិចិន (មិនចាំឈ្មោះ), ទី១១) ប្រពន្ធរបស់ ជា (អ្នកបកប្រែជនជាតិខ្មែរ), ទី១២) ជនជាតិចិន (មិនចាំឈ្មោះ)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 297, September 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.